**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការវិវត្តនៃការលែងលះនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ណុប យសធីតា**

លោក **អ៊ុច ប៊ុណ្ណារ៉ាត**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយបណ្ឌិត **ព្រុំ រិទ្ធី**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

ស្នាដៃសារណានេះ លេចចេញជារូបរាងឡើងបានដោយមានការចូលរួមដ៏ធំធេញពី លោក លោកស្រី សាស្ត្រាចារ្យ បណ្ឌិត សិស្សច្បង និងមិត្តភក្តិ ដែលបានផ្តល់ជាមតិយោបល់ និងជួយណែនាំទាំងចំណេះដឹង និង ឯកសារ។ ការរួមចំណែកទាំងផ្នែកគំនិត ស្មារតី ថវិកា និងបច្ចេកទេសទាំងអស់នេះ ពិតជាវិភាគទានដ៏ថ្លៃថ្លា សម្រាប់ជួយឱ្យការស្រាវជ្រាវ និងការរៀបចំសារណានេះប្រព្រឹត្តទៅទទួលបានលទ្ធផលល្អ។

សូមគោរពថ្លែងអំណរគុណចំពោះ៖

លោកឪពុក និងអ្នកម្តាយ ដែលជាទូទៅបានលះបង់កម្លាំងកាយ និងចិត្តពុះពារគ្រប់ការលំបាក ចិញ្ចឹម បីបាច់ថែរក្សា ជាពិសេសផ្គត់ផ្គង់ការសិក្សារហូតមក តាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា ប្រកបដោយ សុភវិនិច្ឆ័យ ដើម្បីបុព្វហេតុជាតិមាតុភូមិ ក៏ដូចជាការចូលរួមចំណែកអភិវឌ្ឍជាតិ។

ជាពិសេសឯកឧត្តមបណ្ឌិត **ព្រុំ រិទ្ធី** ដែលជាសាស្ត្រាចារ្យជំនួយ ព្រមទាំងជាអនុប្រធានដេប៉ាតឺម៉ង់ ទំនាក់ទំនងអន្តរជាតិនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលឯកឧត្តមបណ្ឌិតបាន ចំណាយពេលវេលាដ៏មានតម្លៃដឹកនាំការសរសេរសារណាបញ្ចប់ការសិក្សា ជាមួយនឹងមតិយោបល់ល្អៗ ប្រកបដោយសុភវិនិច្ឆ័យខ្ពស់ ដើម្បីចូលរួមអភិវឌ្ឍវិស័យច្បាប់ និងយុត្តិធម៌នៅកម្ពុជា ជាពិសេសធ្វើឱ្យសារណា នេះមានការរីកចម្រើន និងបញ្ចប់ដោយជោគជ័យ។

**ក្រសួងយុត្តិធម៌ អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី និងសាលាដំបូងខេត្តកណ្តាល** ដែលបានផ្តល់ ឱកាសឱ្យយើងខ្ញុំបានចុះស្រាវជ្រាវឯកសារ និងបានស្វែងយល់ពីនីតិវិធី ដើម្បីធ្វើឱ្យកិច្ចការស្រាវជ្រាវនេះមាន ភាពរីកចម្រើន មានទិន្នន័យគ្រប់គ្រាន់ និងច្បាស់លាស់។

ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ និងសាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច ដែលបានលះបង់ខ្ពស់ក្នុងការដឹកនាំ និងបង្រៀន ក៏ដូចជាជួយគាំទ្រការសិក្សារបស់និស្សិតគ្រប់រូបតាម រយៈការនិពន្ធសៀវភៅ និងឯកសារពាក់ព័ន្ធនានា ដើម្បីបង្កើនភាពងាយស្រួលក្នុងការអាន និងស្រាវជ្រាវរបស់ និស្សិត។ លើសពីនេះ លោក លោកស្រីសាស្ត្រាចារ្យ បានផ្តល់នូវកិច្ចការស្រាវជ្រាវ ការសម្តែងតួក្នុងថ្នាក់រៀនទៅ លើករណីសិក្សា និងសកម្មភាពក្នុងថ្នាក់រៀនជាច្រើនទៀត ដើម្បីពង្រឹងចំណេះដឹង និងទទួលបាននូវបទពិសោធន៍ សម្រាប់ប្រើប្រាស់នៅថ្ងៃអនាគត ក៏ដូចជាឱ្យស្របតាមការរីកចម្រើននៃវិស័យអប់រំនៅកម្ពុជា និងចក្ខុវិស័យដែល ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញ។

# អារម្ភកថា

ក្រោយពីទទួលបានការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេល ៤ឆ្នាំកន្លងមក និងបានសិក្សាលើមុខវិជ្ជាជាច្រើនទាំងផ្នែកនីតិឯកជន និងនីតិសាធារណៈ ព្រមទាំងបានចុះទៅស្រាវជ្រាវឯកសារនៅឯសាលាដំបូងខេត្តកណ្ដាលកន្លងមក យើងខ្ញុំទាំងពីរបានទទួលចំណេះដឹងយ៉ាងទូលំទូលាយ ក៏ដូចជាអនុសាសន៍ល្អៗពីអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី និងក្រោមការខិតខំប្រឹងប្រែងយកចិត្តទុកដាក់បង្ហាត់បង្រៀនពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់មកដល់យើងខ្ញុំ។ ដោយការជ្រោមជ្រែងនិងការយកចិត្តទុកដាក់ខ្ពស់ក្នុងការបង្ហាត់បង្រៀនអស់ពីកម្លាំងកាយចិត្តទាំងអស់នេះហើយ ទើបធ្វើឱ្យយើងឈានមកដល់ការចងក្រងសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជំនាន់ទី២៣ និងដើម្បីចូលរួមចំណែកក្នុងសង្គម។ ការសរសេរសារណាត្រូវតម្រូវឱ្យយើងមាន សមត្ថភាព និងចំណេះដឹងខ្ពស់ក្នុងការចងក្រងវាឡើងមក ព្រោះថាការចងក្រងសារណាមួយឡើងមក ត្រូវជួបប្រទះនូវបញ្ហា និងការលំបាកជាច្រើន ទើបយើងអាចទទួលបាននូវលទ្ធផលល្អ។

ក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយដែលទាក់ទងទៅនឹងផ្នែកឯកជនដែលមានចំណងជើងថា (ការវិវត្តនៃការលែងលះនៅកម្ពុជា)។ ការជ្រើសរើសប្រធានបទនេះឡើងមក គឺដើម្បីឱ្យបុគ្គលគ្រប់រូបយល់ដឹងកាន់តែច្បាស់អំពីបែបបទនៃការលែងលះពីសម័យមុនរហូតដល់បច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាដែលមានលក្ខណៈស្របទៅតាមច្បាប់ដែលបានកំណត់ មិនតែប៉ុណ្ណោះគឺឱ្យតែបុគ្គលគ្រប់រូបដែលមានបញ្ហាចំណងអាពាហ៍ពិពាហ៍ ការរកាំរកូស និងភាពមិនចុះសម្រុងជាមួយគ្រួសារហើយចង់ផ្ដាច់ចំណងអាពាហ៍ពិពាហ៍នោះ ត្រូវយល់ឱ្យច្បាស់ពីនីតិវិធីនៃការលែងលះ ការបែងចែកទ្រព្យសម្បត្តិការបែងចែកអំណាចមេបាជាដើម។ ទាក់ទងទៅនឹងការវិវត្តនៃការលែងលះ យើងខ្ញុំបានលើកយកក្រមរដ្ឋប្បវេណីដូចជាក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ និងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក៏ដូចជាច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ និងច្បាប់នានាដែលពាក់ព័ន្ធ។

យើងខ្ញុំសង្ឃឹមថា សារណានេះនឹងអាចជាជំនួយដល់ការសិក្សាស្រាវជ្រាវរបស់សិស្សនិស្សិត និងប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលចង់ស្វែងយល់បន្ថែមទាក់ទងទៅនឹងការលែងលះ ហើយនឹងទុកជាស្នាដៃសម្រាប់អ្នកសិក្សាជំនាន់ក្រោយ ដើម្បីសិក្សាបន្ថែមឱ្យកាន់តែច្បាស់អំពីនីតិវិធីនៃការលែងលះក្នុងព្រះរាជាណាចក្រកម្ពុជា។

យើងខ្ញុំសូមអភ័យទោសទុកជាមុននូវរាល់ចំណុចខ្វះខាតមួយចំនួនដូចជាពាក្យពេចន៍ខ្លឹមសារអត្ថន័យឬអក្ខរាវិរុទ្ធទាំងឡាយដែលមាននៅក្នុងកិច្ចស្រាវជ្រាវមួយនេះដោយអចេតនា ហើយក្រុមយើងខ្ញុំនឹងទទួលស្វាគមន៍ជានិច្ចរាល់ការរិះគន់ក្នុងអត្ថន័យស្ថាបនាជាមួយ និងគំនិតល្អៗរបស់មិត្តអ្នកអានទាំងអស់ ដើម្បីធ្វើការកែលម្អ និងធ្វើឱ្យល្អប្រសើរជាងមុន។

# មាតិកា

**ទំព័រ**

**មាតិកា** ............ i

**សេចក្តីផ្តើម** ............ ១

**ជំពូកទី១ ប្រភេទនៃការលែងលះ** ............ ៤

**ផ្នែកទី១ ការលែងលះដោយមានការព្រមព្រៀង** ............ ៤

**១. លក្ខខណ្ឌនៃការលែងលះដោយមានការព្រមព្រៀង** ............ ៤

**២. នីតិវិធីនៃការលែងលះដោយការព្រមព្រៀង** ............ ៦

២.១ ការដាក់ពាក្យសុំ ............ ៦

២.២ តុលាការមានសមត្ថកិច្ច ............ ៧

២.៣ ការវិនិច្ឆ័យ ............ ៧

២.៤ ការផ្សះផ្សា ............ ៨

២.៥ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ............ ៨

២.៦ សេចក្តីសម្រេចក្នុងរឿងលែងលះ ............ ៨

២.៧ បណ្តឹងឧបាស្រ័យ ............ ៩

**ផ្នែកទី២ ការលែងលះដែលមានកំហុស ឬ ដោយពុំមានការព្រមព្រៀង** ............ ៩

**១. មូលហេតុនៃការលែងលះ** ............ ៩

១.១ បានប្រព្រឹត្តអំពើផិត ទៅលើសហព័ទ្ធ ............ ១០

១.២ បានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ ............ ១១

១.៣ សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង១ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ ............ ១៤

១.៤ មិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាង ១ ឆ្នាំ ............ ១៦

១.៥ ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទាន ............ ១៦

១.៥.១ ការប្រើប្រាស់អំពើហិង្សា ............ ១៧

១.៥.២ ករណីដែលចរិយាប្រាសចាកពីសីលធម៌ ............ ១៩
១.៥.៣ ប្តីដេញខ្លួនឱ្យចុះចេញពីលំនៅសង្វាសដោយឥតហេតុដ៏គួរ ............ ១៩
១.៥.៤ មូលហេតុដែលប្តីមិនបានចិញ្ចឹមបីបាច់រក្សាប្រពន្ធកូនឱ្យគួរសមតាមកាតព្វកិច្ចនៃខ្លួនជាប្តី ២០
១.៦ មូលហេតុដែលពុំមានចែងក្នុងក្រមរដ្ឋប្បវេណី ............ ២១
១.៧ មូលហេតុដែលមិនអាចលែងលះបាន ............ ២២
**២. នីតិវិធីនៃការលែងលះដោយមានមូលហេតុ ឬ ដោយពុំមានការព្រមព្រៀង** ..... ២២
២.១ ការដាក់ពាក្យបណ្តឹង ............ ២៣
២.២ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ............ ២៤
២.៣ ការទាញហេតុផលផ្ទាល់មាត់ ............ ២៥
២.៤ ការប្រកាសសាលក្រម ............ ២៥
**ជំពូកទី២ អានុភាព និងសេចក្តីសម្រេច** ............ ២៦
**១. ចំណងអាពាហ៍ពិពាហ៍** ............ ២៦
**២. ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ** ............ ២៧
២.១ ការបែងចែកទ្រព្យដោយការព្រមព្រៀងគ្នា ............ ២៨
២.១.១ ការបែងចែកតាមកិច្ចសន្យា ............ ២៨
២.១.២ ការពិភាក្សាបែងចែកទ្រព្យសម្បត្តិរបស់ភាគី ............ ២៨
២.២ ការបែងចែកទ្រព្យសម្បត្តិដោយតុលាការ ............ ២៩
២.២.១ ទ្រព្យដោយឡែក ............ ៣០
២.២.២ ទ្រព្យរួម ............ ៣១
**៣. ការបែងចែកកាតព្វកិច្ចក្រោយពេលលែងលះ** ............ ៣៣
៣.១ ការបែងចែកតាមការព្រមព្រៀងរបស់ភាគី ............ ៣៣
៣.២ ការចាត់ប្រភេទបំណុល ............ ៣៤
៣.២.១ បំណុលផ្ទាល់ខ្លួន ............ ៣៤
៣.២.២ បំណុលរួម ............ ៣៤

**៤. នាមត្រកូលសហព័ទ្ធ** ........ ៣៥
**៥. អំណាចមេបា** ........ ៣៦
៥.១ ការបែងចែកអំណាចមេបា ........ ៣៦
៥.១.១ ការបែងចែកអំណាចមេបាដោយការព្រមព្រៀង ........ ៣៦
៥.១.២ ការបែងចែកអំណាចមេបាដោយតុលាការ ........ ៣៧
៥.២ ការព្យួរ ការដកហូត និងការផ្លាស់ប្តូរអំណាចមេបា ........ ៣៩
**៦. អាហារភាតព្វកិច្ច** ........ ៤១
៦.១ ការផ្គត់ផ្គង់សហព័ទ្ធ ........ ៤១
៦.២ ការផ្គត់ផ្គង់កូន ........ ៤៣
**សេចក្តីសន្និដ្ឋាន** ........ ៤៥
**អនុសាសន៍** ........ ៤៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

អាពាហ៍ពិពាហ៍ប្រៀបបានដូចជាកិច្ចសន្យាដ៏ឱឡារិកមួយដែលកើតចេញពីបុរសម្នាក់ និងស្ត្រីម្នាក់ ដែលជាការព្រមព្រៀងព្រមព្រៀងប្តេជ្ញារបស់ភាគីសាមីខ្លួនថានឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ដែលមិនអាចរំលាយ ឬ ផ្តាច់ទៅវិញពេលគឺការលែងលះទៅតាមទំនើងចិត្តបានឡើយ។ ប៉ុន្តែក្នុងករណីដែលចំណង អាពាហ៍ពិពាហ៍មួយត្រូវបានប្រែមកជាល្អក់កករ ដោយសារការរស់នៅមិនចុះសម្រុងនឹងគ្នាតាមរយៈហេតុផលជាច្រើនយ៉ាងដូចជា ទាស់ទែងខ្វែងគំនិតគ្នា ការប្រើប្រាស់អំពើហិង្សា ការជេរប្រមាថធ្ងន់ធ្ងរ ការចាកចេញដោយគ្មានកំហុស ការផិតក្បត់ជាដើម ដែលជាហេតុបណ្តាលឱ្យអាពាហ៍ពិពាហ៍មួយ ត្រូវឈានដល់ការចែកផ្លូវគ្នាតាមរយៈការលែងលះ។ ការលែងលះ ដែលមានអនុភាព គឺត្រូវគោរពតាមលក្ខខណ្ឌនៃច្បាប់ដែលបានកំណត់។

នីតិវិធីនៃការលែងលះគឺត្រូវធ្វើឡើងតាមស្មារតីច្បាប់របស់ប្រទេសជាតិនីមួយៗ។ ចំណែកចំណុចដែលគួរឱ្យកត់សម្គាល់គឺ ប្រទេសកម្ពុជាបានផ្លាស់ប្តូរបញ្ញត្តិច្បាប់ជាច្រើន ដោយសារការផ្លាស់ប្តូរបរិបទសង្គមដែលបណ្តាលមកពីបញ្ហាសង្គម ដោយហេតុថាបរិបទសង្គមគឺត្រូវបានផ្លាស់ប្តូរទៅតាមការដឹកនាំរបស់អ្នកកាន់អំណាចនៃសម័យកាលនីមួយៗ។

តាមដំណើររឿងព្រេងខ្មែរ បានបង្ហាញថាព្រះរាជាណាចក្រកម្ពុជាជាប្រទេសមួយដែលមានការគោរពតាមច្បាប់ទំនៀមទម្លាប់ប្រពៃណី ក៏ប៉ុន្តែតាំងពីបុរាណកាលមកច្បាប់ទំនៀមទម្លាប់ទាំងអស់នោះបានធ្វើឱ្យមានការគៀបសង្កត់ទៅលើស្ត្រីភេទជាខ្លាំង ហើយច្បាប់នេះដែរបានបន្តអនុម័តរហូតដល់ក្នុងរជ្ជកាលរបស់ព្រះបាទនរោត្តម។

ក្រោយមកប្រទេសកម្ពុជាក៏បានធ្លាក់ចុះដោយសារសង្គ្រាមផ្ទៃក្នុង និងការលុកលុយពីប្រទេសជិតខាងផង ក្រោមស្ថានភាពបែបនេះប្រទេសកម្ពុជា បានធ្វើការសុំពឹងពាក់ពីប្រទេសបារាំងដែលជាប្រទេសដ៏មានឥទ្ធិពលនាសម័យកាលនោះ ធ្វើជាអាណាព្យាបាលដើម្បីការពារប្រទេសឱ្យគេចផុតពីភ្លើងសង្គ្រាម បន្ទាប់មកបារាំងក៏បានប្រែពីអាណាព្យាបាលទៅជាអាណានិគមវិញ។ ក្រោយការដាក់អាណានិគមរបស់បារាំង បារាំងបានព្យាយាមផ្សព្វផ្សាយវប្បធម៌ និងផ្នត់គំនិតរបស់លោកខាងលិចតាមគ្រប់មធ្យោបាយ ដូចជាការបង្ខំឱ្យពលរដ្ឋខ្មែរសិក្សាភាសាបារាំង និងការកែប្រែច្បាប់ក្នុងប្រទេសកម្ពុជា ដែលបានបង្កប់នូវផ្នត់គំនិតរបស់បារាំង ក្រោយមកក៏បានចងក្រងក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ ដែលប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០ ។

ក្រោយមកទៀត ពោលគឺនៅអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលជារបបផ្តាច់ការមានន័យថាប្រជាជនគ្រប់រូបត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការ ក្នុងគោលបំណងដើម្បីលុបបំបាត់ការបែកចែកវណ្ណៈអ្នកមាន និងអ្នកក្រ លុបបំបាត់នូវទ្រព្យ

សម្បត្តិឯកជន រស់នៅស្មើភាពគ្នា ដោយតម្រូវឱ្យប្រជាជនគ្រប់រូបស្តាប់តាមការបង្គប់បញ្ជាគោរពគោលការណ៍គ្រប់យ៉ាងគឺមានអង្គការជាអ្នកសម្រេច រួមទាំងរឿងបុគ្គល ការចាប់បង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ជាដើម ដែលជាបញ្ហាសិទ្ធិមនុស្សធ្ងន់ធ្ងរ។

បន្ទាប់មកក្រោយរបបផ្តាច់ការនោះត្រូវបានដួលរលំ ក្នុងការស្តារប្រទេសជាតិឡើងវិញ ក្រោយឆ្នាំ ១៩៧៩ ក៏មានការតាក់តែងច្បាប់ឡើងវិញ ក្នុងការកំណត់អំពីទ្រព្យសម្បត្តិ ( ទីលំនៅ ដី ផ្ទះ ) និងកំណត់ចំនួនមនុស្សក្នុងគ្រួសារ (ដើម្បីស្វែងរកថ្នាក់ញាតិ) ក្នុងគោលបំណងបែបនេះ ទើបបង្កើតឱ្យមាននូវច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ និងច្បាប់ភូមិបាលចាស់ជាដើម។

លុះដល់ពេលដែលប្រទេសចាប់ផ្តើមមានស្ថេរភាពឡើងវិញ អ្នកសិក្សាផ្នែកច្បាប់កម្ពុជាបានធ្វើការកែសម្រួលច្បាប់នៅកម្ពុជាឱ្យមានភាពល្អប្រសើរ។ គួរបញ្ជាក់ផងដែរថាក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាត្រូវបានតាក់តែងសេចក្តីព្រាងក្រម ដោយបានបែងចែកក្រុមការងារជាពីរ គឺទីមួយក្រុមការងារក្នុងប្រទេសជប៉ុន ដែលទទួលបន្ទុកក្នុងការរៀបចំសេចក្តីព្រាងដំបូងសម្រាប់ជាមូលដ្ឋានគ្រឹះ សម្រាប់យកមកពិភាក្សាជាមួយនឹងក្រុមការងារប្រទេសកម្ពុជា ដែលជាក្រុមផ្តល់ព័ត៌មានពាក់ព័ន្ធនានាក្នុងស្រុក។ គោលការណ៍បែងចែកជាពីរក្រុម គឺដើម្បីតាក់តែងច្បាស់ឱ្យសមស្របតាមបរិបទរបស់ប្រទេសកម្ពុជា និងដើម្បីទទួលបានច្បាប់មួយដែលមានប្រសិទ្ធិភាព ដោយបង្កប់នូវស្មារតីគោរពសិទ្ធិមនុស្សជាធំ និងការពារផលប្រយោជន៍របស់បុគ្គល។

ការផ្លាស់ប្តូរច្បាប់ពីមួយសម័យកាលទៅមួយសម័យកាល បានធ្វើឱ្យចំណេះដឹងរបស់ប្រជាជនកម្ពុជាមានការរីកចម្រើន និងបានផ្លាស់ប្តូរនូវការយល់ដឹងរបស់ប្រជាពលរដ្ឋឱ្យមានការបើកចិត្តបើកគំនិតធំទូលាយជាងសម័យបុរាណ។ ហើយទទួលយកនូវអ្វីល្អៗ ដែលទទួលបានពីផ្នត់គំនិតបរទេស ដូចជាការឱ្យតម្លៃគ្នា ការគោរពសិទ្ធិអ្នកដទៃ ការគោរពនូវការសម្រេចចិត្តរបស់ភាគីជាដើម។ ការវិវត្តនោះក៏បានធ្វើឱ្យសិទ្ធិរបស់ស្ត្រីនៅកម្ពុជាមានការវិវត្តផងដែរ ដោយការវិវត្តរបស់សិទ្ធិស្ត្រីក៏ជាកត្តាមួយ ដែលធ្វើឱ្យការលែងលះនៅកម្ពុជាមានការវិវត្តដូចគ្នា។ យោងតាមឯកសារសម័យបុរាណជាច្រើនដូចជា ច្បាប់ស្ត្រី រឿងព្រេងខ្មែរជាដើម ដែលបង្ហាញឱ្យឃើញថាសម័យកាលមុនពុំបានផ្តល់សិទ្ធិគ្រប់គ្រាន់ដល់ស្ត្រីឡើយ និងមានការគៀបសង្កត់លើស្ត្រី ដូចជានៅពេលរស់នៅជាមួយឪពុកម្តាយ(មុនរៀបអាពាហ៍ពិពាហ៍) ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយ រាល់កិច្ចការ គឺមានឪពុកម្តាយជាអ្នកសម្រេច បន្ទាប់មកនៅពេលរស់នៅជាមួយស្វាមី (ក្រោយរៀបអាពាហ៍ពិពាហ៍) គឺត្រូវគោរពប្រត្តិបត្តិស្វាមី រាល់ការសម្រេចត្រូវមានការឯកភាពពីស្វាមី លើសពីនេះទៅទៀតក៏បានធ្វើឱ្យមានការជាន់ឈ្លីដល់ទឹកចិត្តស្មោះសរបស់ស្ត្រីដូចគ្នា ដោយច្បាប់ក្នុងរជ្ជការព្រះបាទនរោត្តម និងក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ បានចែងថា បុរសអាចយកប្រពន្ធច្រើនបាន តែស្ត្រីអាចយកប្តីបានតែមួយទេ។ ទោះបីជាយ៉ាងណាក៏

ដោយប្រសិនបើក្រឡេកមកមើលសង្គមបច្ចុប្បន្នវិញហាក់បីមានភាពខុសស្រឡះពីគ្នាទាំងស្រុង ដោយស្ត្រីមានសិទ្ធិស្មើគ្នាជាមួយនឹងបុរសផងដែរ។ ផ្អែកតាមសមភាពនៃយេនឌ័រ ស្ត្រីមានសិទ្ធិស្មើនឹងបុរស ដូចស្ត្រីបច្ចុប្បន្នមានសិទ្ធិអាចទទួលនូវការសិក្សាបានខ្ពង់ខ្ពស់ មានសិទ្ធិអាចគ្រប់គ្រងទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ខ្លួន មួយវិញទៀតស្ត្រីក៏អាចជ្រើសរើសគូស្រករបស់ខ្លួនតាមចិត្ត។

តាមមតិរបស់សង្គមមួយចំនួនយល់ថា ច្បាប់មានការវិវត្តទើបសង្គមជាតិមានការអភិវឌ្ឍ នេះជាចំណុចល្អសម្រាប់សង្គម។ រីឯមតិមួយចំនួនទៀតបានលើកឡើងថា ការវិវត្តនៃច្បាប់បានផ្តល់ឱ្យស្ត្រីនូវចំណេះដឹង មានឱកាសរកប្រាក់ចំណូលដោយខ្លួនឯង ដែលមិនចាំបាច់ពឹងលើការទំនុកបម្រុងពីដៃគូដើម្បីរស់ ដូចកាលសម័យមុនដែលសេដ្ឋកិច្ចទាំងស្រុងគឺប្តីជាអ្នកផ្គត់ផ្គង់ ជាពិសេសការវិវត្តនៃច្បាប់នៃការលែងលះបានធ្វើឱ្យសហព័ទ្ធមានភាពងាយស្រួលក្នុងការលែងលះ។ តាមរយៈរបាយការណ៍របស់ CEIC ករណីទាំងអស់នេះបានធ្វើឱ្យការលែងលះនៅកម្ពុជាមានការកើនឡើងជារៀងរាល់ឆ្នាំ។ ជាក់ស្តែងអាត្រានៃការលែងលះនៅឆ្នាំ ២០២១ មានចំនួន ១,៨០០% បើធៀបនឹងអាត្រានៃការលែងលះក្នុងឆ្នាំ២០២០ មានតែចំនួន ១,៧០០% ដែលចំនួន 0,១០០% សម្រាប់ប្រទេសកម្ពុជាជាចំនួនមួយដែលច្រើន ព្រោះនៅប្រទេសកម្ពុជាមានចំនួនប្រជាជនតិច រីឯអាត្រាប្រជាជនដែលបានរៀបអាពាហ៍ពិពាហ៍បែរជាមានការធ្លាក់ចុះទៅវិញ។[1] តើការកើនឡើងនៃលែងលះនៅកម្ពុជាពិតជាបណ្តាលមកពីការវិវត្តនៃច្បាប់ដែរឬទេ? តើការវិវត្តនៃការលែងលះនៅកម្ពុជាមានលក្ខណៈខុសគ្នាអ្វីខ្លះ? ហើយតើការវិវត្តនៃការលែងលះនេះ បានផ្តល់ផលប៉ះពាល់ដល់សង្គមដែរឬទេ?

ទាំងនេះគ្រាន់តែជាការប្រៀបធៀបអំពីសង្គមចាស់ និង សង្គមបច្ចុប្បន្នដើម្បីឱ្យមានភាពប្រទាក់ក្រឡាគ្នាទៅនឹងប្រធានបទសារណានេះ ដោយសារណាបញ្ចប់ការសិក្សានេះផ្តោតសំខាន់ទៅលើការវិវត្តនៃការលែងលះនៅកម្ពុជា ដែលនឹងធ្វើការបកស្រាយពាក់ព័ន្ធនឹងចំណុចជាច្រើនដូចជា ជំពូកទី១ សិក្សាអំពីប្រភេទនៃការលែងលះ និងនីតិវិធីនៃការលែងលះ។ រីឯជំពូកទី២ ពិភាក្សាអំពីអនុភាព និងសេចក្តីសម្រេចរបស់តុលាការ។

[1] CEIC | Cambodia Population Distribution : Divorced | Economic Indicators ( ២០២១ ) https://www.ceicdata.com/en/cambodia/population-cambodia-socioeconomic-survey-cses/population-distribution-divorced ( ថ្ងៃចូលមើល ១១/០៧/២០២៣ )

# ជំពូកទី១ ប្រភេទនៃការលែងលះ

តាមរយៈផ្លូវច្បាប់ ដែលគោរពលើស្មារតីរបស់សហព័ទ្ធបានបែងចែកការលែងលះជាពីរប្រភេទផ្សេងគ្នាក្នុងគោលបំណងគាំទ្រលើការសម្រេចចិត្តរបស់សាមីភាគី។ ដោយហេតុថាក្នុងលក្ខខណ្ឌអាពាហ៍ពិពាហ៍មួយកើតមានឡើងដោយសារការស្រឡាញ់រវាងចិត្តនឹងចិត្តរបស់មនុស្សប្រុសស្រីពីរនាក់ដោយគ្មានការបង្ខិតបង្ខំ តែប្រសិនបើការស្រឡាញ់នោះត្រូវបានសាបរលាប នោះច្បាប់ក៏ដូចជាភាគីណាមួយមិនអាចបង្ខំឱ្យបន្តការរួមរស់ជាមួយដោយគ្មានមនោសញ្ចេតនាបានឡើយ។ ក្នុងស្មារតីច្បាប់ការលែងលះតាមផ្លូវតុលាការអាចធ្វើឡើងក្រោមរូបភាពពីរ គឺការលែងលះដោយការដាក់ពាក្យបណ្ដឹងពីភាគីប្ដី ឬ ប្រពន្ធ និងការលែងលះដោយការព្រមព្រៀងរបស់ប្ដីប្រពន្ធទាំងពីរ។ ហើយការលែងលះដែលអាចប្រព្រឹត្តិទៅតាមច្បាប់ក៏ត្រូវគោរពលើអត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍ដែលមានដូចជា លក្ខខណ្ឌភេទ អាយុ នៅលីវ ឬ ភាពនៅទំនេរជាដើម។ ហើយអាពាហ៍ពិពាហ៍ត្រូវចាត់ទុកស្របតាមច្បាប់ លុះត្រាណាតែបុរស និងនារីបានចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅ ឃុំ សង្កាត់ ដែលបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍នោះ។[2]

## ផ្នែកទី១ ការលែងលះដោយមានការព្រមព្រៀង

### ១. លក្ខខណ្ឌនៃការលែងលះដោយមានការព្រមព្រៀង

ការលែងលះដោយការព្រមព្រៀង មានន័យថារវាងសហព័ន្ធបានឯកភាពគ្នាដោយស្ម័គ្រចិត្តក្នុងការរំលាយនូវចំណងអាពាហ៍ពិពាហ៍ ដោយពុំចាំបាច់តម្រូវឱ្យមាននូវមូលហេតុអ្វីស្មុគស្មាញឡើយ ពោលឱ្យតែសហព័ទ្ធទាំងសងខាងបង្ហាញឆន្ទៈក្នុងការព្រមព្រៀងលែងលះគ្នា។ ការលែងលះដោយការព្រមព្រៀងប្រៀបបានដូចជាការចុះកិច្ចសន្យាផងដែរ ដោយហេតុថាកិច្ចសន្យាមានអានុភាពដោយសារសំណើ និងស្វីការត្រូវគ្នា។[3] ក្នុងន័យនេះ មានន័យថាការលែងលះដោយការព្រមព្រៀងនោះមិនត្រូវមានវិការៈឡើយ ដូចជាមានការគំរាមកំហែង ការឆបោក ឬ ការឆ្លៀតឱកាសដើម។

ភាគីអាចដាក់ពាក្យសុំលែងលះដោយព្រមព្រៀងគ្នាទៅកាន់តុលាការបាន ប៉ុន្តែតុលាការអាចសម្រេចលែងលះ ឬ លើកចោលដោយឆន្ទានុសិទ្ធិបាន ក្រោយពីពិនិត្យ និងយល់ឃើញថាភាគីសងខាងមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។ តាមន័យនេះ ដើម្បីផ្ដល់ភាពងាយស្រួលដល់ការសម្រេចរបស់តុលាការ ក៏ដូចជាជៀសវាងទទួលបានការលើចោលរបស់តុលាការ ការបង្ហាញឆន្ទៈ ព្រមព្រៀងភាគីគប្បីបង្ហាញឆន្ទៈមុនពេលដាក់ពាក្យសុំលែងលះ។

[2] ច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, លេខ នស/រកម/០៧២៣/ ០០៩, ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០២៣, មាត្រា៧០, កថាខណ្ឌទី១។

[3] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៣៣៦, កថាខណ្ឌទី ១។

ជាក់ស្តែង ករណីការលែងលះដែលមានការព្រមព្រៀងមួយ ភាគីបានធ្វើកិច្ចព្រមព្រៀងលែងលះ ដោយបានបញ្ជាក់ការឯកភាពគ្នាក្នុងខ្លឹមសារនៃកិច្ចសន្យា ដូចជាភាគីទាំងសងខាងព្រមព្រៀងលែងលះដោយស្ម័គ្រចិត្តពុំមានការបង្ខិតបង្ខំពីភាគីណាមួយទេ។ យោងតាមកិច្ចព្រមព្រៀងលែងលះនោះ តុលាការក៏បានសម្រេចលែងលះគ្នារវាងអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតតាមការព្រមព្រៀង។[4] ចំណុចដែលគួរឱ្យកត់សម្គាល់នៃករណីដែលមានកិច្ចព្រមព្រៀងលែងលះជាមុនបែបនេះបានជួយពន្លឿននីតិវិធីឱ្យបានលឿនជាងធម្មតា ជាក់ស្តែងចាប់តាំងពីថ្ងៃចុះកិច្ចព្រមព្រៀងលែងលះ ដល់ថ្ងៃដែលតុលាការចេញដីកាសម្រេច ប្រើរយៈពេលមិនដល់ ១០ថ្ងៃឡើយ។

ក៏ប៉ុន្តែពេលវេលានៃការបង្ហាញឆន្ទៈក្នុងការព្រមព្រៀងពុំមានការកំណត់ច្បាស់លាស់ឡើយ។ ដូចនេះការបង្ហាញឆន្ទៈព្រមព្រៀងដែលកើតឡើងក្រោយពេលដាក់ពាក្យបណ្តឹង បានធ្វើឱ្យមានផលប៉ះពាល់ដល់ការជ្រើសរើសនីតិវិធីដែលត្រឹមត្រូវក្នុងការសម្រេចសេចក្តី។ ករណីនេះតុលាការគប្បីណែនាំឱ្យភាគីដកពាក្យបណ្តឹង ប្តូរមកជាការដាក់ពាក្យសុំវិញ ដើម្បីឱ្យត្រឹមត្រូវតាមស្មារតីរបស់ច្បាប់ ក្នុងការដំណើរការដោះស្រាយរឿងក្តីដោយចេញដីកាសម្រេច។ តែតាមភាពជាក់ស្តែងទោះបីក្រោយពេលដាក់ពាក្យបណ្តឹង ភាគីបានបង្ហាញឆន្ទៈព្រមព្រៀងគ្នាក្នុងនីតិវិធីណាមួយក៏ដោយដំណើរការនីតិវិធីតាមពាក្យបណ្តឹងនៅតែបន្ត ហើយចេញសាលក្រមលើអង្គសេចក្តីធម្មតា។

ក្នុងករណីមួយដើមចោទបានដាក់ពាក្យបណ្តឹងសុំលែងលះ ក្រោយរយៈពេល ៥ខែ ដែលភាគីដើមចោទបានដាក់ពាក្យបណ្តឹងភាគីទាំងសងខាងក៏បានព្រមព្រៀងគ្នាក្នុងការចុះកិច្ចព្រមព្រៀងបែងចែកបំណុល។ ហើយនៅក្នុងអង្គហេតុដែលអះអាងដោយដើមចោទបានបញ្ជាក់ថា *ខ្លួន និងចុងចម្លើយបានសម្រេចចិត្តលែងលះគ្នាដោយស្ម័គ្រចិត្ត* ចំណែកឯ អង្គហេតុដែលអះអាងដោយចុងចម្លើយបានបញ្ជាក់ថា *ខ្លួនពិតជាព្រមព្រៀងលែងលះពីដើមចោទតាមការប្តឹងសុំរបស់ដើមចោទ* ។ ក្នុងសំអាងហេតុ តុលាការបានលើឡើងថា ដើមចោទបានប្តឹងទាមទារលែងលះពីចុងចម្លើយ ដោយសំអាងថារស់នៅមិនចុះសម្រុងនឹងគ្នា និងមិនអាចបន្តរស់នៅជាមួយគ្នាតទៅមុខទៀតបាន ហើយចុងចម្លើយក៏បានព្រមព្រៀងនឹងការប្តឹងសុំលែងលះរបស់ដើមចោទនេះដែរ។ ឆ្លងតាមការផ្សះផ្សាជាច្រើនលើកមកឃើញថា ភាគីពុំព្រមសះជានឹងគ្នាទេ ដែលជាករណីធ្វើឱ្យទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបែកបាក់ ហើយគ្មានសង្ឃឹមថាអាចបដិទានឡើងវិញបាន ដែលភាគីទាំងសងខាងមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។ ហេតុនេះ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគីតាមមាត្រា ៩៧៩ និងមាត្រា ៩៨៤ នៃក្រមរដ្ឋប្បវេណី។ ហើយក្នុងសេចក្តីសម្រេចបញ្ចប់នៃសាលក្រម តុលាការបង្គាប់ឱ្យដើមចោទលែងលះពីចុងចម្លើយ (តាមការព្រមព្រៀង)។[5]

---

[4] ដីកាសម្រេចសាលាដំបូងខេត្តបន្ទាយមានជ័យ, សំណុំរឿងរដ្ឋប្បវេណី, លេខ ៥៥០ ពស.មប “ ញ ”/២២, ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ ២០២២។

[5] សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ១៩១ “ ញ ”, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ ។

ក្នុងករណីខ្លះទៀតប្រសិនបើក្រោយពេលដាក់ពាក្យបណ្ដឹងភាគីបានព្រមព្រៀងគ្នាក្នុងការលែងលះវិញ ភាគីអាចដាក់លិខិតសំណូមពរ ស្នើសុំឱ្យតុលាការសម្រេចលែងលះតាមការព្រមព្រៀងវិញក៏បាន។

ជាក់ស្ដែងភាគីខាងដើមចោទបានដាក់ពាក្យបណ្ដឹងសុំប្ដឹងឈប់រស់នៅ និងផ្ដាច់អនីតិសង្វាស។ ក្រោយមកនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ភាគីទាំងសងខាងបានអះអាងថា បានឯកភាពគ្នាលែងលះ និងបានចុះកិច្ចសន្យាលែងលះគ្នាដោយពុំមានអ្នកណាបង្ខំអ្នកណាឡើយ។ ក្នុងសំអាងហេតុតុលាការបានទទួលលិខិតសំណូមពរ ដែលស្នើសុំឱ្យតុលាការសម្រេចលែងលះតាមការព្រមព្រៀងរបស់ភាគីមានលក្ខណៈត្រឹមត្រូវតាមច្បាប់។ ដូចនេះតុលាការបានសម្រេចឱ្យដើមចោទ ដាច់អនីតិសង្វាសពីចុងចម្លើយតាមការព្រមព្រៀងរបស់គូភាគីគិតពីថ្ងៃដីកាសម្រេចចូលជាស្ថាពរតទៅ។[6]

## ២. នីតិវិធីនៃការលែងលះដោយការព្រមព្រៀង

បើទោះបីជាការលែងលះដោយព្រមព្រៀងប្រៀបបានដូចជាកិច្ចសន្យាក៏ដោយ ប៉ុន្តែការព្រមព្រៀងគ្នារវាងភាគីក្នុងការលែងលះ ភាគីមិនអាចបង្កើតកិច្ចសន្យាក្រៅផ្លូវការ ឬ គ្រាន់តែប្រើវិធីដាក់លិខិតជូនដំណឹងទៅសាលាឃុំ - សង្កាត់បានទេ ចាំបាច់ត្រូវតែមានសេចក្ដីសម្រេចពីតុលាការ ទើបការលែងលះមានអានុភាពស្របតាមផ្លូវច្បាប់ ដោយភាពច្បាស់លាស់នៃចំណងគតិយុត្ត ដែលសំដៅដល់អត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍ និងការបង្ហាញឆន្ទៈពិតប្រាកដរបស់សហព័ទ្ធទាំងសងខាងក្នុងការបញ្ចប់ជីវិតជាប្ដីប្រពន្ធ។

ពាក់ព័ន្ធនឹងលក្ខខណ្ឌទម្រង់នេះដែរ គឺបច្ចុប្បន្ននៅប្រទេសកម្ពុជាដោះស្រាយតាមច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ក៏ប៉ុន្តែកាលពីមុនពុំទាន់មានច្បាប់នេះគឺដោះស្រាយតាមក្រមរដ្ឋប្បវេណីទាំងស្រុង។ យោងតាមច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងលក្ខខណ្ឌទម្រង់នៃការលែងលះដោយព្រមព្រៀងមានដូចជា៖

### ២.១ ការដាក់ពាក្យសុំ

ពាក្យសុំអាចធ្វើបានជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន។ ទម្រង់ជាលាយលក្ខណ៍អក្សរតាមការដាក់ពាក្យសុំលែងលះតែងតែភ្ជាប់មកជាមួយនូវកិច្ចព្រមព្រៀងលែងលះ ដោយក្នុងកិច្ចព្រមព្រៀងនោះបានបញ្ជាក់អំពីឆន្ទៈនៃការព្រមព្រៀង និងជាយថាហេតុ ព្រមទាំងការព្រមព្រៀងក្នុងការបែងចែកទ្រព្យសម្បត្តិកាតព្វកិច្ច ក៏ដូចជាអំណាចមេបាជាដើម។ ការដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើ នៅចំពោះមុខក្រឡាបញ្ជី ហើយក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និងចុះហត្ថលេខា ហើយកំណត់ហេតុនេះត្រូវចាត់ទុកថាជាពាក្យសុំ។[7] ពាក្យសុំត្រូវសរសេរនូវចំណុចដូចខាងក្រោម៖

[6] ដីកាសម្រេចសាលាដំបូងខេត្តកណ្ដាល, សំណុំរឿងរដ្ឋប្បវេណី, លេខ ១១៨ (ល), ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៣។

[7] ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង, លេខ នស/រកម/០៧១០/០១៣, ២៥ មិថុនា ២០១០, មាត្រា២៦, កថាខណ្ឌទី៣។

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ព្រមទាំងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ។

នៅក្នុងការដាក់ពាក្យសុំនេះ អ្នកដាក់ពាក្យសុំត្រូវបង់ប្រាក់ពន្ធនៃការដាក់ពាក្យសុំចំនួន ៥.០០០ (ប្រាំពាន់) រៀល។

**២.២ តុលាការមានសមត្ថកិច្ច**

សមត្ថកិច្ចនៃតុលាការ គឺជាការកំណត់ពីសម្បទារបស់ស្ថាប័នតុលាការក្នុងការទទួលដោះស្រាយ និងចេញដីកាសម្រេចលើរឿងក្តីដោយស្របច្បាប់។ ចំពោះរឿងក្តីលែងលះដោយការព្រមព្រៀង គឺតុលាការនៃលំនៅឋានរបស់ប្តី ឬ ប្រពន្ធ។[8] ហេតុនេះ តុលាការមានសមត្ថកិច្ចក្នុងរឿងក្តីលែងលះអាចជាតុលាការខាងលំនៅឋានរបស់អ្នកដាក់ពាក្យសុំក៏បាន ឬ ជាតុលាការខាងលំនៅឋានរបស់ភាគីម្ខាងទៀតក៏បាន។ ហើយសមត្ថកិច្ចនេះត្រូវកំណត់ដោយយកតាមពេលដាក់ពាក្យសុំ បើទោះបីជាភាគីប្តូរលំនៅឋានក៏ដោយ។[9]

**២.៣ ការវិនិច្ឆ័យ**

ការវិនិច្ឆ័យ គឺជាការបំពេញកិច្ចនីតិវិធីតាំងពីដំបូងដើម្បីឱ្យចៅក្រមដែលទទួលបន្ទុកអាចប្រមូលបាននូវមូលដ្ឋាននៃការពិចារណា ដែលមានភាពច្បាស់លាស់គ្រប់ជ្រុងជ្រោយ មុនឈានដល់ការសម្រេចសេចក្តីតាមផ្លូវច្បាប់។ ដំណាក់កាលនេះផ្តោតលើចំណុចសំខាន់២ គឺករណីយកិច្ច និងការទទួលខុសត្រូវរបស់ភាគី និងការដឹកនាំ និងការចាត់ចែងរបស់តុលាការ។

- ករណីយកិច្ច និងការទទួលខុសត្រូវរបស់ភាគី គួរបញ្ជាក់ផងដែរថា ក្នុងសំណុំរឿងរដ្ឋប្បវេណីតុលាការពុំអាចចាប់ផ្តើមដំណើរការនីតិវិធីដោយឆន្ទានុសិទ្ធិឡើយ នីតិវិធីអាចចាប់ផ្តើមបានលុះត្រាតែមានការដាក់ពាក្យបណ្តឹង ឬ ពាក្យសុំពីភាគី។ ហេតុដូចនេះ នៅពេលដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរភាគីត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីអត្តសញ្ញាណរបស់ភាគី និងអាសយដ្ឋានរបស់ភាគី ព្រមទាំងខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុជាមូលហេតុនៃការទាមទារ។[10] ចំណែកករណី ការដាក់ពាក្យសុំដោយផ្ទាល់មាត់ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខក្រឡាបញ្ជី។[11] ភាគីក៏មានករណីយកិច្ចក្នុងការបង្ហាញខ្លួននៅពេលដែលតុលាការកោះហៅផងដែរ។

[8] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ២៥ មិថុនា ២០១០, តារាងឧបសម្ព័ន្ធ, ផ្នែកទី៤, ចំណុចទី៥។

[9] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ២៥ មិថុនា ២០១០, មាត្រា ៤, កថាខណ្ឌទី២។

[10] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ២៥ មិថុនា ២០១០, មាត្រា ២៦។

[11] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ២៥ មិថុនា ២០១០, មាត្រា ២៦។

- ករណីយកិច្ចដឹកនាំ និងការចាត់ចែងរបស់តុលាការ នៅពេលទទួលបានពាក្យសុំ ចៅក្រមដែលទទួលបន្ទុកនឹងរៀបចំកំណត់កាលបរិច្ឆេទធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឬ សាកសួរដោយឆន្ទានុសិទ្ធិឱ្យបានយ៉ាងឆាប់រហ័ស។ តុលាការអាចធ្វើការស្រាវជ្រាវ ឬ ធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិផងដែរ ប្រសិនបើមានការចាំបាច់ តុលាការអាចជូនដំណឹងទៅតំណាងអយ្យការអំពីរឿងក្តី ឬ កោះហៅជនពាក់ព័ន្ធដែលមានផលប្រយោជន៍ឱ្យចូលរួម។

**២.៤ ការផ្សះផ្សា**

យោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៩៨៤ បានបញ្ញត្តថា ទោះបីជាភាគីម្ខាងទាមទារយ៉ាងខ្លាំងចំពោះការលែងលះគ្នាក៏ដោយ តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន។ [12] តាមន័យនេះ ទោះបីជាភាគីមានការព្រមព្រៀងគ្នាក៏ដោយក៏តុលាការអាចសាកល្បងព្យាយាមក្នុងការផ្សះផ្សា ដើម្បីទប់ស្កាត់ការលែងលះដែលធ្វើឡើងតាមទំនើងចិត្តរបស់ភាគី។ ដោយការផ្សះផ្សាម្តងៗ ចៅក្រមត្រូវបង្គាប់ឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុផ្សះផ្សាសម្រុះសម្រួល ទោះបីការផ្សះផ្សាបានការ ឬ មិនបានការក៏ដោយ។

**២.៥ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

ការអនុវត្តជាទូទៅ ចៅក្រមជ្រើសយកការធ្វើការសាកសួរភាគី មកដោះស្រាយចំពោះរឿងក្តីប្រភេទនេះពុំយកការធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់ទេ ពីព្រោះរឿងក្តីប្រភេទនេះជារឿងក្តីដែលមិនមានភាពស្មុគស្មាញហើយភាគីបានយល់ព្រមគ្នារួចរាល់។ [13] ក្នុងករណីខ្លះទៀតគឺ តុលាការមិនធ្វើនីតិវិធីអ្វីទាំងអស់ ប្រសិនបើក្រោយពិនិត្យពាក្យសុំលែងលះ និងយល់ថាពាក្យសុំលែងលះនោះមានទម្រង់ត្រឹមត្រូវតាមច្បាប់។ តុលាការក៏អាចធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ក្នុងករណីដែលការសង្ស័យចំពោះការព្រមព្រៀងនោះ ហើយជាពិសេសតុលាការអាចធ្វើការយកអង្គហេតុដែលមិនអះអាងដោយគូភាគី មកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបាន។

**២.៦ សេចក្តីសម្រេចក្នុងរឿងលែងលះ**

ក្រោយពីធ្វើការវិនិច្ឆ័យរួចហើយ តុលាការនឹងធ្វើការសម្រេចសេចក្តីដោយចេញជាដីកាសម្រេច។ ដីកាសម្រេច ដែលជាសេចក្តីសម្រេចលើអង្គសេចក្តីចំពោះការលែងលះដោយការព្រមព្រៀង ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវសរសេរសេចក្តីសម្រេចបញ្ចប់ ព្រមទាំងសំអាងហេតុ។ [14] ដីកាសម្រេច គឺជាការសម្រេចសេចក្តីដែលតុលាការ ឬ ចៅក្រមអាចធ្វើដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បាន ហើយមិនមែនជាសាលក្រម។[15]

[12] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៨៤ កថាខណ្ឌទី ១។

[13] អត្ថបទសាកល្បងស្តីពី លក្ខខណ្ឌនៃការលែងលះដោយការព្រមព្រៀង, រៀបរៀងដោយ លោក ផុន វណ្ណា, ទំព័រទី១២។

[14] ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ២៥ មិថុនា ២០១០, មាត្រា៣៥។

[15] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ១៧៩ កថាខណ្ឌទី ២។

គួរបញ្ជាក់ផងដែរថាចំពោះច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ក្រោយពីការអង្កេតស៊ើបសួរឃើញថាការលែងលះគ្នានោះ ធ្វើដោយគ្មានការបង្ខិតបង្ខំ និងស្ម័គ្រចិត្តពិតប្រាកដ តុលាការត្រូវសម្រេចឲ្យលែងលះគ្នាដោយពុំមានការបែងចែករវាងសាលក្រម ឬ ដីកាសម្រេចឡើយ ពោលគឺការលែងលះដោយមានការព្រមព្រៀងក៏តុលាការចេញជាសាលក្រមដូចគ្នា។ [16]

ក្នុងរឿងក្តីទូទៅដីកាសម្រេច កើតមានអានុភាពដោយការជូនដំណឹង ដោយឡែកដីកាសម្រេចចំពោះការលែងលះដោយការព្រមព្រៀង កើតមានអានុភាពដោយការចូលជាស្ថាពរ។ ដូច្នេះ បន្ទាប់ពីការចេញដីកាសម្រេចតុលាការត្រូវធ្វើការជូនដំណឹងដល់ប្តី និងប្រពន្ធដើម្បីអាចចាប់ផ្តើមគិតពេលកំណត់ដែលត្រូវចូលជាស្ថាពរបាន។

ការជូនដំណឹងនេះអាចធ្វើតាមរយៈការបញ្ជូន ឬ ផ្ញើឯកសារចម្លងនៃដីកាសម្រេច។ បន្ទាប់ពីទទួលបានការជូនដំណឹងអំពីដីកាសម្រេចក្នុងរយៈពេល ០២សប្តាហ៍។ [17] ប្រសិនបើគ្មានបណ្តឹងឧបាស្រ័យណាមួយឡើយទេ ដីកាសម្រេចលែងលះដោយការព្រមព្រៀងនឹងចូលជាស្ថាពរ ហើយអាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់ និងសារធាតុដូចករណីនៃសាលក្រមស្ថាពរក៏នឹងកើតឡើងដែរ។

### ២.៧ បណ្តឹងឧបាស្រ័យ

ក្នុងករណីដែលតុលាការសម្រេចលើកចោលពាក្យសុំ ភាគីអាចធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះដីកាសម្រេចនោះបាន។ ការធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះដីកាសម្រេចគឺ សំដៅដល់ការធ្វើបណ្តឹងជំទាស់ ហើយបណ្តឹងជំទាស់នេះអាចធ្វើបានទាល់តែមានចែងកំណត់ជាក់លាក់ជាមុន និងអាចធ្វើបានតែម្តងគត់។[18] តាមទ្រឹស្តីនីតិវិធីរដ្ឋប្បវេណីបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ជាបណ្តឹងដែលទាមទារដោយភាគី ដើម្បីសុំឱ្យតុលាការជាន់ខ្ពស់លុបចោល ឬ ផ្លាស់ប្តូរសេចក្តីសម្រេចដែលតុលាការជាន់ក្រោមបានចេញនៅមុនពេលដែលសេចក្តីសម្រេចនោះចូលជាស្ថាពរ។ រយៈពេលនៃការប្តឹងជំទាស់គឺមានរយៈពេល ០២សប្តាហ៍ ក្រោយថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេច។[19]

## ផ្នែកទី២ ការលែងលះដែលមានកំហុស ឬ ដោយពុំមានការព្រមព្រៀង

### ១. មូលហេតុនៃការលែងលះ

ការលែងលះដោយពុំមានការព្រមព្រៀង សំដៅលើការដាក់ពាក្យបណ្តឹងសុំលែងលះពីភាគីម្ខាងចូលទៅតុលាការ ដោយបានលើកឡើងនូវមូលហេតុនៃការលែងលះដែលច្បាប់កំណត់ និងត្រូវបញ្ជាក់អំពីការស្នើសុំ

---

[16] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៥៨។

[17] ច្បាប់ ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ២៥ មិថុនា ២០១០, មាត្រា៤០។

[18] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ២៥៩។

[19] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ២៥ មិថុនា ២០១០, មាត្រា ៤០។

ទាមទាររបស់ខ្លួន ដូចជាការបែងចែកទ្រព្យ ការបែងចែកបំណុល និងការកំណត់អំណាចមេបាជាដើម ហើយការដាក់ពាក្យបណ្តឹងនេះដែរ គឺត្រូវដាក់ពាក្យទៅកាន់តុលាការនៅខាងទីលំនៅជាក់ស្តែងរបស់ចុងចម្លើយ។ គួរបញ្ជាក់ផងដែរថា ការដាក់ពាក្យបណ្តឹងសុំលែងលះ គឺត្រូវតែបញ្ជាក់អំពីមូលហេតុកើតចេញពីទង្វើរបស់ភាគីម្ខាងទៀតបានប្រព្រឹត្តមកលើខ្លួន ដែលបណ្តាលឱ្យមិនអាចបន្តការរួមរស់ជាមួយគ្នាតទៅទៀត ដាច់ខាតត្រូវតែឱ្យតុលាការជាអ្នកកាត់សេចក្តីឱ្យបានច្បាស់លាស់ និងមានភាពសមរម្យទៅតាមការកំណត់នៃច្បាប់។ ហើយដំណើរការនៃនីតិវិធីដោះស្រាយត្រូវអនុវត្តតាមច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ [20] មូលហេតុដែលភាគីអាចធ្វើការដាក់ពាក្យបណ្តឹងមានដូចជាការប្រព្រឹត្តអំពើផិត ការបោះបង់ចោលសហព័ទ្ធ សហព័ទ្ធរស់នៅបែកគ្នាជាបន្តបន្ទាប់ជាង១ឆ្នាំ កាលបាត់ដំណឹងសហព័ទ្ធ ឬ ករណីផ្សេងៗទៀត ដែលបណ្តាលឱ្យអាពាហ៍ពិពាហ៍មិនអាចបដិទានបាន។

### ១.១ បានប្រព្រឹត្តអំពើផិត នៅលើសហព័ទ្ធ

យោងតាមច្បាប់ឯកពន្ធភាពនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់យ៉ាងច្បាស់ថា អំពើផិតក្បត់ គឺជាការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុន ដែលមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬ ជាការរួមសេវនកិច្ចរវាងស្ត្រី ដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន។ [21] ពាក់ព័ន្ធនឹងអំពើផិតក្បត់នេះ មានការលើកឡើងតាំងពីក្រមរដ្ឋប្បវេណីឆ្នាំ១៩២០មកម្លេះ ប៉ុន្តែដោយសារតែក្រមរដ្ឋប្បវេណីចាស់បានបែងចែកមូលហេតុនៃការសុំលែងលះរបស់ប្តី និងប្រពន្ធដាច់ដោយឡែកពីគ្នា ថែមទាំងមានការរឹតត្បិតតែភាគីប្រពន្ធនាសម័យនោះ ដូចនេះចំពោះអំពើផិតក្បត់ក្នុងក្រមរដ្ឋប្បវេណីចាស់បានបញ្ញត្តតែក្នុងចំណុចមូលហេតុនៃការសុំលែងលះរបស់ប្តីតែប៉ុណ្ណោះ។ មានន័យថា ក្នុងករណីដែលប្រពន្ធបានប្រព្រឹត្តអំពើផិតក្បត់ចំពោះប្តី ប្តីអាចធ្វើការសុំលែងលះពីប្រពន្ធបាន។ [22] ក៏ប៉ុន្តែក្នុងករណីដែលប្តីផិតក្បត់ប្រពន្ធ ប្រពន្ធពុំមានមូលហេតុក្នុងការសុំលែងលះប្តីឡើយ ដោយហេតុថាច្បាប់ពុំមានចែងចំណុចនេះក្នុងមូលហេតុនៃការសុំលែងលះរបស់ប្រពន្ធ ក៏ដោយសារតែនៅសម័យនោះ សង្គមខ្មែរនៅគោរពតាមច្បាប់ទំនៀមទម្លាប់នៅឡើយ ដោយចាស់បុរាណយល់ឃើញថា បុរសមានប្រពន្ធច្រើនជារឿងធម្មតា ហើយច្បាប់ក៏បានអនុញ្ញាតឱ្យបុរសអាចយកប្រពន្ធបានច្រើននាក់ថែមទៀត។[23]

នៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារត្រង់ចំណុចមូលហេតុនៃការលែងលះពុំមានការចែងអំពីអំពើផិតក្បត់ឡើយ តែឃើញមានពាក្យថាប្រព្រឹត្តអនាចារនៅក្នុងមូលហេតុនៃការលែងលះ តើពាក្យថាប្រព្រឹត្ត

[20] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ២០ ឧសភា ២០១០, មាត្រា៣។

[21] ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦, មាត្រា៧។

[22] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ២០៦។

[23] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ១៤១។

អនាចារគឺជាការប្រព្រឹត្តអំពើផិតក្បត់ដែលឬទេ? ការប្រព្រឹត្តអនាចារសំដៅទៅលើការប្រព្រឹត្តពុំសមគួរ ការប្រព្រឹត្តខុសបែបបទ ឥតមាយាទ ខុសសណ្ដាប់ធ្នាប់សង្គម ដូចជាលួចទៅមានប្រុសថ្មី ឬ ស្រីថ្មីច្រើន ឬ លួចមានសាហាយស្មន់ជាដើម។ យោងតាមការបកស្រាយអំពីពាក្យអនាចារ អាចសន្និដ្ឋានបានថាក្នុងករណីកើតមានអំពើផិត មិនថាភាគីណាឡើយឱ្យតែត្រូវបានសហព័ទ្ធផិតអាចយោងតាមចំណុចនេះក្នុងការប្ដឹងសុំលែងបាន ហើយតុលាការអាចផ្អែកតាមស្មារតីនៃបញ្ញត្តិនេះក្នុងការសម្រេចឱ្យលែងលះបាន។ ដោយហេតុថា អំពើផិតក្បត់បានបណ្ដាលឱ្យប៉ះពាល់ដល់មនោសញ្ចេតនាប្ដីប្រពន្ធ ថែមទាំងផ្ទុយពីគោលការណ៍អាពាហ៍ពិពាហ៍ ដែលតម្រូវឱ្យប្ដីប្រពន្ធត្រូវតែស្រឡាញ់គ្នាទៅវិញទៅមក។ ហើយទង្វើមួយដែលមានផលប៉ះពាល់ដល់សណ្ដាប់ធ្នាប់សង្គម ដូចជាមិនអាចបញ្ជាក់បានអំពីបុគ្គលភាពជាដើម ក្នុងករណីដែលការផិតក្បត់ឈានដល់មានការបង្កកំណើត។

ក្នុងក្រមរដ្ឋប្បវេណីបច្ចុប្បន្នបានបញ្ញត្តអំពើផិតក្បត់ជាមូលហេតុនៃការលែងលះ ដោយអំពើផិតក្នុងក្រមនេះសំដៅលើទំនាក់ទំនងផ្លូវភេទ។ យោងតាមច្បាប់ស្ដីពីឯកពន្ធភាព ក្នុងករណីរវាងប្ដី ឬ ប្រពន្ធនៅមានចំណងអាពាហ៍ពិពាហ៍ ហើយមិនទាន់លែងលះដាច់ស្រេច រួចរួមសេវនកិច្ចជាមួយជនទី៣ ក្រៅពីប្រពន្ធ ឬ ប្ដីរបស់ខ្លួន គឺត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទផិតក្បត់។[24] មិនថាភាគីខាងស្រី ឬ ខាងប្រុសបានប្រព្រឹត្តអំពើផិតនៅពេលត្រូវបានភាគីណាមួយតាមទាន់នោះ តាមផ្លូវច្បាប់ករណីផិតក្បត់គឺសុទ្ធតែខុសទាំងអស់ឱ្យតែអ្នកនោះបានប្រព្រឹត្តពិតប្រាកដ មានភស្តុតាងដូចជារូបភាព វីឌីអូ សកម្មភាពនានាដែលអាចបង្ហាញថាបានប្រព្រឹត្ត មានសាក្សីបង្ហាញថាមានអំពើផិត ដើម្បីឱ្យតុលាការសម្រេចលែងលះស្របតាមច្បាប់។ បើទោះបីជាពុំមាន ភស្តុតាងតុលាការនៅតែអាចសម្រេចឱ្យលែងលះគ្នាបានដែរ បើយល់ឃើញថាភាគីមិនអាចបន្តការរួមរស់ជាប្ដីប្រពន្ធតទៅទៀត ហើយអាចឈានដល់ការប្រើប្រាស់អំពើហិង្សា។ គួរបញ្ជាក់ផងដែរថា ចាប់តាំងពីច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារមកដល់បច្ចុប្បន្នក្នុងករណីដែលមានអំពើនេះកើតមានឡើង ទាំងប្ដីទាំងប្រពន្ធដែលត្រូវបានផិតមានសិទ្ធិយោងតាមមូលហេតុនេះ ក្នុងការប្ដឹងសុំលែងលះបាន។ ដោយសកម្មភាពផិតក្បត់នេះបានប្រាសចាកពីគោលការណ៍ស្ម័គ្រចិត្តប្ដីមួយប្រពន្ធមួយ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។[25]

### ១.២ បានបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ

ក្នុងក្រមរដ្ឋប្បវេណីបច្ចុប្បន្ន ពុំបានបញ្ជាក់ឱ្យបានច្បាស់លាស់ចំពោះពាក្យថាបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវនោះទេ ក៏ប៉ុន្តែចំពោះវិធានច្បាប់នៃប្រទេសដទៃការបោះបង់សហព័ទ្ធចោល ដោយគ្មានមូលហេតុត្រឹមត្រូវ កើតឡើងនៅពេលដែលសហព័ទ្ធម្ខាងចុះចោលលំនៅសង្វាស ដែលបានរួមរស់ជាមួយ

[24] ច្បាប់ស្ដីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦, មាត្រា៧។
[25] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣, មាត្រា ៤៥, កថាខណ្ឌទី៤។

សហព័ទ្ធរងគ្រោះ ហើយបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់។ ហេតុដូចនេះមូលហេតុនៃការលែងលះនេះ គឺមិនខុសពីករណីចុះចោលលំនៅសង្វាសឡើយ ដែលជាមូលហេតុនៃការលែងលះរបស់ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ព្រមទាំងក្រមរដ្ឋប្បវេណីចាស់ ការចុះចោលលំនៅសង្វាសប្រៀបបានដូចជាការបោះបង់សហព័ទ្ធដូចគ្នា។ ការបោះបង់សហព័ទ្ធចោលដោយឥតមូលហេតុបែបនេះ បានធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្តសហព័ទ្ធម្ខាងទៀតយ៉ាងខ្លាំង ហើយទង្វើនេះគឺផ្ទុយពីបញ្ញត្តិនៃច្បាប់ដែលបានចែងអំពីករណីយកិច្ចរបស់ប្តីប្រពន្ធ ដោយប្តីប្រពន្ធមានកាតព្វកិច្ចរួមរស់ជីវភាពជាមួយគ្នា សហការ និងសង្គ្រោះគ្នាទៅវិញទៅមក។[26]

បើទោះបីជាក្នុងក្រមរដ្ឋប្បវេណីចាស់ មានការបែងចែករវាងមូលហេតុនៃកាលែងលះរបស់ប្តីប្រពន្ធផ្សេងគ្នាក៏ពិតមែន ប៉ុន្តែចំពោះមូលហេតុមួយដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា គឺករណីដែលចុះចោលលំនៅឋាន។ ដោយមូលហេតុនៃការសុំលែងលះរបស់ប្តី បានលើកឡើងថាករណីដែលប្រពន្ធដើរចោលលំនៅសង្វាសរវាងមួយយប់ឥតហេតុអ្វីដ៏គួរសោះ។[27] ក្នុងន័យនេះសំដៅលើ ការដែលប្រពន្ធពុំត្រូវបានអនុញ្ញាតឱ្យដើរចោលផ្ទះ ឬ មិននៅផ្ទះដោយគ្មានមូលហេតុសូម្បីមួយយប់គឺជាមូលហេតុដែលប្តីអាចប្តឹងលែងលះប្រពន្ធ។ ដោយហេតុថា ក្នុងករណីដែលប្រពន្ធចាកចោលពីផ្ទះបាត់ ដោយពុំបានប្រាប់ពីមូលហេតុដល់គ្រួសារឱ្យបានដឹងជាមុន គេយល់ថាស្ត្រីពុំមានភាពស្មោះត្រង់ចំពោះប្តី និងក្រុមគ្រួសារ ហើយការបាត់ដំណឹងមួយយប់បែបនេះអាចនឹងប្រព្រឹត្តអំពើមិនគប្បីនឹងប្តី ដែលអាចនឹងឈានទៅដល់ការអស់មនោសញ្ចេតនារវាងប្តី និងប្រពន្ធ។ លើសពីនេះទៅទៀតគេយល់ថាស្ត្រីគួរតែនៅផ្ទះដើម្បីធ្វើកិច្ចការងារផ្ទះផ្សេងៗ មើលថែកូនចៅ គោរពប្រតិបត្តិប្តីស្មោះត្រង់នឹងគ្រួសារ និងផ្តល់ភាពកក់ក្តៅដល់គ្រួសារទាំងមូល។ ចំណែកឯមូលហេតុនៃការសុំលែងលះរបស់ប្រពន្ធក្នុងករណីចុះចោលលំនៅសង្វាសដែលជាចំណុចស្រដៀងគ្នានោះ គឺដោយសារប្តីនោះបានបោះបង់លំនៅសង្វាសលើសពីបីខែដោយឥតហេតុដ៏គួរហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ និងទំនុកបម្រុងកូនសោះ។[28] ការចាកចោលប្រពន្ធកូនដោយឥតមូលហេតុរយៈពេលយូរពេក បានធ្វើឱ្យបន្ទុកទាំងឡាយត្រូវធ្លាក់មកលើប្រពន្ធតែម្នាក់ ហើយកត្តានេះនឹងធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារទាំងមូល។ ដោយហេតុថាកិច្ចការទាំងពួង ដែលស្ត្រីមានប្តីធ្វើឥតអនុញ្ញាតពីប្តីនឹងត្រូវទុកជាមោឃៈ[29] នេះជាអ្វីដែលច្បាប់សម័យកាលនោះបានបញ្ញត្ត ហេតុដូច្នេះស្ត្រីមួយចំនួនធំនៅសម័យនោះពុំមានជំនួញផ្ទាល់ខ្លួន ដើម្បីរកប្រាក់ចំណូលដោយខ្លួនឯងបានឡើយ បើគ្មានការអនុញ្ញាតពីប្តី ដូចនេះក្នុងករណីដែលប្តីបោះបង់ប្រពន្ធកូនចោលនឹងធ្វើឱ្យប្រពន្ធកូនគ្មានទីពឹង។ ប៉ុន្តែក្នុងករណីដែលប្តីបានចុះចេញពីកូនប្រពន្ធក៏ពិតមែន តែបើប្តីនៅតែផ្គត់ផ្គង់ធនធានដល់កូនប្រពន្ធ

[26] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៦៦។

[27] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ២០៦។

[28] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ២០៧។

[29] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ១៩៨។

នោះ ប្រពន្ធពុំអាចផ្អែកលើមូលហេតុនៃការចុះចោលលំនៅសង្វាសមកសុំលែងលះឡើយ។ ត្រង់ចំណុចនេះ មូលហេតុនៃការសុំលែងលះ ដោយសារការចុះចោលផ្ទះដូចគ្នា ក៏ប៉ុន្តែមានការបែងចែកដែលមានលក្ខណៈលំអៀងទៅលើខាងប្តីជាធំ ដោយប្តីចុះចោលលំនៅសង្វាសរយៈពេល៣ខែ ក៏ពុំមែនជាមូលហេតុនៃការលែងលះដែរ ប្រសិនបើប្តីបានផ្តល់ប្រាក់ទំនុកបម្រុង រីឯប្រពន្ធវិញគ្រាន់តែបាត់ពីលំនៅសង្វាសតែ១យប់ ក៏ប្តីមានសិទ្ធិពេញលេញក្នុងការសុំលែងលះបានដែរ។

ក្រោយមក ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានធ្វើការផ្លាស់ប្តូរកែប្រែច្បាប់ទំនៀមទម្លាប់ មកជាការឈរលើស្មារតីស្មើភាពគ្នាវិញ ដូចនេះពុំបានបែងចែកអំពីមូលហេតុនៃការលែងលះ ដោយការចុះចោលលំនៅសង្វាសរបស់ប្តីប្រពន្ធផ្សេងគ្នាឡើយ ពោលគឺទាំងប្តីទាំងប្រពន្ធអាចលើកយកចំណុចនៃមូលហេតុនេះមកសុំលែងលះបាន ឱ្យតែក្នុងករណីដែលជាការចុះចោលលំនៅសង្វាស ដោយឥតមូលហេតុត្រឹមត្រូវ ហើយឥតមានផ្គត់ផ្គង់ស្បៀងអាហារ និងទំនុកបម្រុងកូនសោះ។[30] តាមបញ្ញត្តិច្បាប់បានលើកឡើងថា ប្តីប្រពន្ធមានករណីយកិច្ចកសាងគ្រួសារមួយមានសាមគ្គីភាព ក្នុងករណីចាកចេញដោយគ្មានមូលហេតុត្រឹមត្រូវថែមទាំងមិនបានជួយផ្គត់ផ្គង់ដល់គ្រួសារបែបនេះ បង្ហាញថាសហព័ទ្ធម្ខាងនោះ ពុំបានបំពេញកាតព្វកិច្ចក្នុងការកសាងគ្រួសារប្រកបដោយសាមគ្គីភាពឡើយ។[31] លើសពីនេះទៅទៀត ការចាកចោលគ្រួសារបែបនេះ បានធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារជាខ្លាំង ដោយហេតុថា បើទោះបីជាច្បាប់មានការកែប្រែឱ្យប្តីប្រពន្ធមានសិទ្ធិជ្រើសរើសដោយសេរីនូវវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ[32] ប៉ុន្តែតាមសង្គមជាក់ស្តែងក៏នៅតែប្រតិបត្តិតាមទំនៀមទម្លាប់បែបបុរាណដដែល ដោយប្តីមានតួនាទីរកប្រាប់ចំណូលដើម្បីផ្គត់ផ្គង់ដល់គ្រួសារទាំងមូល ចំណែកឯប្រពន្ធគឺមានតួនាទីធ្វើជាម្តាយល្អ និងភរិយាល្អ មានន័យថាប្រពន្ធនៅតែត្រូវនៅផ្ទះដើម្បីមើលថៃគ្រួសារ ដោយមិនបានទៅប្រកបមុខរបរអ្វីទាំងអស់។ ដូចនេះប្រសិនបើកើតមានករណីចាកចេញដោយគ្មានមូលហេតុបែបនេះនឹងធ្វើឱ្យគ្រួសារនោះជួបបញ្ហាសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ។

ការចុះចោលលំនៅសង្វាស គឺជាការដែលសហព័ទ្ធមិនរួមរស់ជីវភាពជាមួយគ្នា សហការគ្នាសង្គ្រោះគ្នាទៅវិញទៅមក អាចបង្ហាញថាភាគីលែងលះដោយពុំមានឆន្ទៈក្នុងការរួមរស់ជាមួយបន្តទៅទៀតឡើយ ដែលទង្វើនេះគឺពិតជាផ្ទុយពីគោលបំណងនៃអាពាហ៍ពិពាហ៍ ដូច្នេះចំណុចនេះត្រូវបានចាត់ចូលជាមូលហេតុមួយក្នុងការលែងលះបច្ចុប្បន្ន។

[30] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា ៣៩។
[31] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា ៣០។
[32] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា ៣១។

ប្រសិនបើជាករណីអនីតិសង្វាស ការដែលបោះបង់ចោលដៃគូដោយពុំមានមូលហេតុត្រឹមត្រូវ គឺត្រូវបានតុលាការធ្វើការលើកចោលនូវពាក្យបណ្តឹង។ ជាក់ស្តែង សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ បុរសជាប្តីបានចាកចេញពីផ្ទះជាង៣ឆ្នាំ តុលាការក៏បានសម្រេចលើកចោលពាក្យបណ្តឹង ដោយបញ្ជាក់ឱ្យភាគីមានសិទ្ធិពេញលេញនៅក្នុងការរៀបអាពាហ៍ពិពាហ៍តាមឆន្ទៈរបស់ខ្លួនរៀងៗខ្លួន ដោយមិនមានការជំទាស់ពីភាគីម្ខាងណាឡើយ។[33]

### ១.៣ សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង១ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍

ការបែកគ្នាអស់រយៈពេលជាង១ឆ្នាំ ក្នុងចំណុចនេះសំដៅទៅដល់ការដែលសហព័ទ្ធពុំបានរួមរស់ជាមួយគ្នាក្រោមដំបូលផ្ទះតែមួយ ដោយពុំមែនជាការរស់នៅផ្សេងគ្នាដែលបណ្តាលមកពីតម្រូវការនៃការងារឡើយ។ បើទោះបីជាសហព័ទ្ធនោះត្រឡប់មកផ្ទះម្តងម្កាលក៏ដោយ ក៏ត្រូវចាត់ទុកថាជាការរស់នៅបែកគ្នា ប្រសិនបើសហព័ទ្ធបានឈប់រួមដំណេកជាមួយគ្នា។ នៅថ្ងៃដែលសហព័ទ្ធម្ខាងណាបានចាកចេញពីផ្ទះ ដើម្បីទៅរស់នៅកន្លែងផ្សេងដែលពុំមែនជាតម្រូវការនៃការងារ សហព័ទ្ធដែលត្រូវបានសហព័ទ្ធម្ខាងទៀតបោះបង់នោះគប្បី ជូនដំណឹងទៅកាន់ក្រុមប្រឹក្សាឃុំសង្កាត់ដែលនៅលំនៅឋានរបស់ខ្លួន ដើម្បីរកដំណោះស្រាយ និងកំណត់ថ្ងៃដែលសហព័ទ្ធលែងរួមរស់ជាមួយគ្នា។

ចំពោះការដែលបែកគ្នាអស់រយៈពេលជាង១ឆ្នាំនេះ ពុំមានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ឡើយ។ ដោយហេតុថាករណីនេះជារឿងធម្មតាដែលអាចកើតឡើងនាសម័យនោះ ក៏ព្រោះតែច្បាប់បានអនុញ្ញាតឱ្យប្តីអាចមានប្រពន្ធច្រើន លើសពីនេះទៅទៀតច្បាប់ក៏បានចែងថាប្តីអាចបង្ខំប្រពន្ធចុងទាំងឡាយឱ្យទៅនៅលំនៅណាមួយដោយឡែកបាន។[34] ដូចនេះបើតាមមនោសញ្ចេតនារបស់ប្តីប្រពន្ធដែលទទួលបានក្តីស្រលាញ់ជាងគេនឹងត្រូវទទួលបានការយកចិត្តទុកដាក់ជាងគេ រីឯប្រពន្ធដែលពុំទទួលបានការស្រឡាញ់នឹងត្រូវទុកចោល។ ប៉ុន្តែប្រពន្ធនោះក៏ពុំអាចសុំលែងលះបានដែរ ប្រសិនបើប្តីនៅតែផ្គត់ផ្គង់ខ្លួន។ ជាការពិតណាស់ករណីនេះក៏ពុំអាចកើតឡើងលើប្រពន្ធដើមដែរ ដោយច្បាប់បានកំណត់ថាប្រពន្ធដើមត្រូវមានសិទ្ធិ និងករណីយកិច្ចបានលំនៅជាមួយប្តី។[35]

ចំពោះករណីនេះច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ព្រមទាំងក្រមរដ្ឋប្បវេណីបច្ចុប្បន្នបានលើកឡើងប្រហាក់ប្រហែលគ្នា ដោយច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានចែងថាការបែកគ្នារយៈពេលជាង១ឆ្នាំ។[36]

---

[33] សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩។

[34] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា១៩២។

[35] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា១៩១។

[36] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៣១។

វិញក្រមរដ្ឋប្បវេណីឆ្នាំ២០០៧វិញ បានចែងថាសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង១ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍។ [37] ករណីនេះគឺផ្ទុយពីនិយមន័យនៃអាពាហ៍ពិពាហ៍ ដោយអាពាហ៍ពិពាហ៍មួយកើតឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ប្ដេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នា ហើយការបែកគ្នារយៈពេលជាង១ឆ្នាំ ក៏ផ្ទុយអំពីករណីយកិច្ចរបស់សហព័ទ្ធ ដោយច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារបានចែងថា ប្ដីប្រពន្ធមានករណីយកិច្ចស្រលាញ់គ្នា ចំណែកឯក្រមបច្ចុប្បន្នបានចែងថា ប្ដីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា។ ហើយគេយល់ឃើញថា ការបែកគ្នាយូរទៅសហព័ទ្ធណាមួយអាចប្រព្រឹត្តទង្វើអ្វីដែលមិនគប្បីនឹងសហព័ទ្ធរបស់ខ្លួន ហើយការដែលមិនបានធ្វើការប្រាស្រ័យទាក់ទងគ្នាជាយូរ ក៏អាចធ្វើឱ្យអស់មនោសញ្ចេតនា ដូចពាក្យចាស់បានពោលថា *ឃ្លាតកាយណាយចិត្ត* ដូចនេះបើមានម្ខាងអស់មនោសញ្ចេតនាអាពាហ៍ពិពាហ៍នោះក៏មិនអាចបន្តបានឡើយ។ ការរស់នៅផ្សេងគ្នាបែបនេះ គឺបញ្ជាក់បានថាសហព័ទ្ធអស់មនោសញ្ចេតនានឹងគ្នាចង់បញ្ចប់ទំនាក់ទំនងរវាងប្ដីប្រពន្ធជារៀងរហូត។

យោងតាមករណីលែងលះដែលភាគីបានព្រមព្រៀងគ្នាមួយ ដើមចោទ និងចុងចម្លើយបានធ្វើសេចក្ដីថ្លែងការណ៍បញ្ជាក់ថា ពួកខ្លួនបានបែកលំនៅសង្វាសមួយរយៈមកហើយ។ កត្តានេះបង្ហាញឱ្យឃើញថា ដើមចោទ និងចុងចម្លើយពិតជាអស់មនោសញ្ចេតនាជាប្ដីប្រពន្ធពីគ្នាប្រាកដមែន ដែលអាចឱ្យតុលាការប្រកាសលែងលះគ្នាតាមមាត្រា ៣៩ ចំណុច ៥ និងមាត្រា ៤០ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។[38]

ចំពោះការលែងលះបច្ចុប្បន្ន ដែលជាការលែងលះដោយការដាក់ពាក្យបណ្ដឹងពីខាងប្រពន្ធ។ យោងតាមការថ្លែងការណ៍របស់ដើមចោទបានទាមទារលែងលះពីចុងចម្លើយ ដោយហេតុថាភាគីបានបែកលំនៅឋានពីគ្នាតាំងពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២១ ដែលជាថ្ងៃនៃការដាក់ពាក្យបណ្ដឹង ដោយសាររស់នៅជាមួយគ្នាតែងតែមានទំនាស់ឈ្លោះប្រកែកគ្នា មានការគំរាមកំហែង ការប្រើប្រាស់ហិង្សា ការជេរប្រមាថជារឿយៗធ្វើឱ្យអស់មនោសញ្ចេតនាជាប្ដីប្រពន្ធ។ តាមការអះអាងរបស់ដើមចោទមូលហេតុនៃការលែងលះ គឺមានភាពត្រឹមត្រូវតាមច្បាប់ ព្រោះភាគីបានបែកលំនៅឋានពីគ្នា ផ្ទុយពីគោលបំណងអាពាហ៍ពិពាហ៍ ដូចនេះទំនាក់ទំនងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយត្រូវបែកបាក់ គ្មានសង្ឃឹមថានឹងអាចធ្វើបដិទានវិញបានទេ។ ផ្អែកតាមមាត្រា ៩៧៨ ចំណុច ឃ និង ង នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ ដូចនេះតុលាការបានសម្រេចបញ្ចប់ឱ្យដើមចោទ លែងលះគ្នាពីចុងចម្លើយ។[39]

[37] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា៩៧៨។

[38] សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ៤៣ “ ញ ” ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០។

[39] សាលាក្រមសាលាដំបូងខេត្តបាត់ដំបង, សំណុំរឿងរដ្ឋប្បវេណី, លេខ ២៧ “ ញ ” ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២។

### ១.៤ មិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាង ១ ឆ្នាំ

ករណីនេះសំដៅទៅដល់កាលបើសហព័ទ្ធណាមួយបានចាកចេញ ឬចុះចោលសហព័ទ្ធម្ខាងទៀត ដោយបាត់ដំណឹងសូន្យ ពុំបានផ្តល់ដំណឹងឱ្យសហព័ទ្ធមួយទៀតឱ្យបានដឹង ហើយបានបាត់ដំណឹងជាង ១ឆ្នាំ សហព័ទ្ធនោះអាចដាក់ពាក្យសុំលែងលះបាន ដែលទង្វើនេះក៏ជាមូលហេតុមួយដែលអាពាហ៍ពិពាហ៍ត្រូវបានមោឃភាពផង។ ករណីនេះពុំឃើញមានចែងក្នុងក្រមរដ្ឋប្បវេណីចាស់ឡើយ ប៉ុន្តែក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ក្នុងករណីដែលសហព័ទ្ធណាមួយបាត់ខ្លួនកន្លងហួសពីមួយឆ្នាំ គិតពីថ្ងៃដែលបាត់ខ្លួននោះមក ដោយគ្មានដំណឹងអ្វីសោះហើយក៏គ្មាននរណាដឹងថា ជននោះស្លាប់ ឬ រស់ សហព័ទ្ធម្នាក់ទៀតអាចនឹងរៀបអាពាហ៍ពិពាហ៍ទៀតបាន បើផុតរយៈ ១៥ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រមដែលបញ្ជាក់ថា ជននោះបានបាត់ខ្លួនពិតមែន។ បច្ចុប្បន្ននៅពេលដែរបាត់ដំណឹងភ្លាមសហព័ន្ធនោះត្រូវអនុវត្តការដាក់ពាក្យសុំទៅកាន់តុលាការជាមុនស្តីអំពីការបាត់ខ្លួនរបស់សហព័ទ្ធដើម្បីប្រកាសពីការបាត់ខ្លួននោះតាមរយៈពាក្យសុំរបស់សហព័ទ្ធ ដែលគោរពតាមគោលការណ៍នៃមាត្រា៤១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ក្នុងករណីដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោល ក្រោយពេលសហព័ទ្ធរបស់បុគ្គលដែលត្រូវបានប្រកាសអំពីការបាត់ខ្លួននោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកផ្សេង ហើយអាពាហ៍ពិពាហ៍មុនត្រូវរលាយ ដោយសារអាពាហ៍ពិពាហ៍ក្រោយនោះ។

### ១.៥ ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទាន

ក្រៅពីចំណុចដែលបានលើកឡើងខាងលើ នៅមានចំណុចមួយចំនួនទៀតដែលក្រមរដ្ឋប្បវេណីបច្ចុប្បន្នពុំបានចែង ប៉ុន្តែមានចែងក្នុងច្បាប់ចាស់ ហើយតុលាការនៅតែធ្វើការសម្រេចឱ្យលែងលះ ដោយតុលាការយល់ឃើញថា អាពាហ៍ពិពាហ៍ត្រូវបែកបាក់គ្មានសង្ឃឹមថានឹងអាចបដិទាន តើពាក្យថាមិនអាចបដិទានសំដៅលើអ្វី? ការដែលអាពាហ៍ពិពាហ៍មួយមិនអាចបដិទានបានគឺ បណ្តាលមកពីកំហុសឆ្គង ដែលមានលក្ខណៈធ្ងន់ធ្ងរនាំឱ្យមានផលប៉ះពាល់ដល់ភាគីម្ខាងទៀត ដូចជាការប្រើអំពើហិង្សាទាំងផ្លូវកាយ និងផ្លូវចិត្ត ការជេរប្រមាថ សកម្មភាពអាកប្បកិរិយារបស់សហព័ទ្ធ ស្ថានភាពសេដ្ឋកិច្ចជាដើម ដែលបណ្តាលឱ្យសហព័ទ្ធអស់មនោសញ្ចេតនាជាប្តីប្រពន្ធ ហើយទាមទារឱ្យចៅក្រមធ្វើការពិនិត្យវិនិច្ឆ័យ និងវាយតម្លៃកំណត់ថាតើករណីទាំងនោះ ពិតជាធ្វើឱ្យអាពាហ៍ពិពាហ៍បានបែកបាក់ ហើយគ្មានសង្ឃឹមថាអាចនឹងត្រឡប់មករួមរស់ជាមួយគ្នាក្នុងនាមជាប្តីប្រពន្ធវិញឡើយ។ ក្នុងករណីជាក់ស្តែង ករណីនានាដែលពុំមានចែងក្នុងក្រមរដ្ឋប្បវេណី ហើយជាហេតុបណ្តាលឱ្យភាគីអស់មនោសញ្ចេតនាជាប្តីប្រពន្ធ តុលាការតែងតែចាត់ចូលក្នុងចំណុចករណីផ្សេងៗនេះក្នុងការសម្រេចលែងលះ ឬ ផ្តាច់អនីតិសង្វាសដល់គូភាគី។

### ១.៥.១ ការប្រើប្រាស់អំពើហិង្សា

ចំពោះករណីដែលកើតមានអំពើហិង្សា ក្រមរដ្ឋប្បវេណី ១៩២០ បានចែងក្នុងចំណុចនៃការសុំលែងលះរបស់ប្ដី ដោយផ្អែកលើចិត្តអាណិតអាសូររបស់ប្ដីទៅលើប្រពន្ធទៅវិញ។ ករណីប្រពន្ធចុងវាយដំច្រំធាក់ប្រពន្ធដើមដល់មានរបួស មានស្លាកស្នាម ឬ ធ្វើទុកជេប្រមាទជាទម្ងន់ មានន័យថាក្នុងករណីដែលមានអំពើហិង្សាកើតលើប្រពន្ធដើម ដែលប្រព្រឹត្តដោយប្រពន្ធចុង ប្រពន្ធដើមពុំមានសិទ្ធិក្នុងការសុំប្ដឹងលែងលះឡើយ លុះត្រាតែប្ដីជាអ្នកសុំលែងលះទើបអាចលែងលះបាន។[40] ក៏ព្រោះតែកាលពីសម័យដើម បានចែងថាបុរសអាចយកប្រពន្ធបានច្រើននាក់។[41] ដោយសារការច្រណែន ការប្រចណ្ឌ ឬមកពីការចែកក្ដីស្រឡាញ់មិនស្មើគ្នា ហើយដោយសារតែខាងបុរសផ្ដល់តម្លៃ និងការស្រឡាញ់បង់លចំពោះប្រពន្ធចុងជាងប្រពន្ធដើម ទើបបណ្ដោយឱ្យប្រពន្ធចុងធ្វើតាមអំពើចិត្ត តែប្រសិនបើប្ដីមានចិត្តអាណិតអាសូរចំពោះប្រពន្ធដើម ឬ ប្រពន្ធដែលទទួលរងនូវការធ្វើបាបសុំអង្វរប្ដីឱ្យដោះលែងនាង ប្ដីអាចសុំលែងប្រពន្ធដើម ដើម្បីដោះលែងនាងឱ្យមានសេរីភាព មិនទទួលនូវករណីហិង្សាទាំងនោះទៀតបាន។ ចំណែកឯក្នុងករណីដែលប្ដីប្រើប្រាស់អំពើហិង្សាលើប្រពន្ធ គឺក្រមរដ្ឋប្បវេណីចាស់ពុំបានលើកឡើងឡើយ ហេតុដូចនេះមានន័យថាការប្រើប្រាស់អំពើហិង្សារបស់ប្ដីទៅលើប្រពន្ធ ពុំមែនជាមូលហេតុនៃការលែងលះរបស់ស្ត្រីនាសម័យកាលនោះឡើយ។

ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានចាត់ទុកការប្រើប្រាស់អំពើហិង្សាជាមូលហេតុនៃការលែងលះដោយសហព័ទ្ធទាំងសងខាងមានសិទ្ធិស្មើគ្នាក្នុងការប្ដឹងលែងលះ ប្រសិនបើទទួលរងនូវការវាយដំឃោរឃៅ ធ្វើទុកបុកម្នេញប្រមាថមើលងាយធ្ងន់ធ្ងរចំពោះសហព័ទ្ធ រឺចំពោះបុព្វញាតិរបស់សហព័ទ្ធនេះ។[42] អាពាហ៍ពិពាហ៍ត្រូវបានកើតដោយការព្រមព្រៀងគ្នា ដោយស្ម័គ្រចិត្ត និងមនោសញ្ចេតនារវាងមនុស្សពីរនាក់ ព្រមទាំងបង្កើតទំនាក់ទំនងរវាងគ្រួសារទាំងសងខាងឱ្យក្លាយជាគ្រួសារតែមួយ។ ការវាយដំជាការប្រមាថមើលងាយមិនឱ្យតម្លៃលើ សហព័ទ្ធ និងញាតិរបស់សហព័ទ្ធផងដែរ។ ការវាយដំនេះក៏អាចបង្ហាញថាសហព័ទ្ធនោះបានអស់មនោសញ្ចេតនាទៅលើសហព័ទ្ធម្ខាងទៀត។ លើសពីនេះទៅទៀត ការវាយដំក្នុងករណីដែលពុំអាចទប់កំហឹងបាន គឺអាចឈានដល់ការបាត់បង់អាយុជីវិត ដែលវាជាបញ្ហាសិទ្ធិមនុស្ស ព្រោះជនគ្រប់រូបមានសិទ្ធិរស់រៀនមានជីវិតមានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន។[43] ការលែងលះដែលបណ្ដាលមកពីការប្រើប្រាស់អំពើហិង្សាតុលាការនឹងធ្វើការដាក់បន្ទុកលើអ្នកបង្ក ដូចជាបង្គាប់ឱ្យអ្នកបង្កទទួលបន្ទុកប្រាក់ប្រដាប់ក្ដីទាំងស្រុង និងការអនុញ្ញាតឱ្យភាគីមានសិទ្ធិស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតដែលបានបង្កើតកំហុសជាដើម។

[40] ក្រមនរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ២០៦, កថាខណ្ឌទី ៣។

[41] ក្រមនរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ១៤១។

[42] ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៣៩ ។

[43] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣២។

ក្នុងករណីដែលលែងលះដោយសារមានការប្រើប្រាស់អំពើហិង្សា ក្រោយការទាញហេតុផលផ្ទាល់មាត់ តុលាការយល់ឃើញថា ប្តីបានប្រើអំពើហិង្សា វាយប្រពន្ធ ចាក់សោរផ្ទះមិនឱ្យនៅទាំងនេះបញ្ជាក់ថាប្តីមានកំហុស។ ដូចនេះតុលាការបានសម្រេចឱ្យភាគីលែងលះតាមមាត្រា ៣៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដោយដាក់កំហុសលើប្តី។[44]

ក្នុងចំណុចមូលហេតុនៃការលែងលះរបស់ក្រមរដ្ឋប្បវេណី២០០៧ ពុំមានចែងពាក់ព័ន្ធនឹងការប្រើប្រាស់អំពើហិង្សាឡើយ។ ដោយហេតុថា បច្ចុប្បន្នអំពើហិង្សាក្នុងគ្រួសារទាំងឡាយណា ដែលចូលជាបទល្មើសព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដោយយោងតាមក្រមព្រហ្មទណ្ឌជាធរមាន គឺត្រូវអនុម័តតាមក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះជាគោលការណ៍ក្នុងការដោះស្រាយ។[45] ក៏ប៉ុន្តែករណីប្រើប្រាស់អំពើហិង្សានេះ នៅតែជាមូលហេតុមួយដែលតុលាការសម្រេចឱ្យលែងលះ បើទោះបីជាពុំមានចែងក្នុងចំណុចមូលហេតុនៃការលែងលះក៏ដោយ ដោយសារអំពើហិង្សាក្នុងគ្រួសារ គឺអាចធ្វើឱ្យភាគីអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាក្នុងនាមជាប្តីប្រពន្ធ។ ហើយករណីនេះទាមទារឱ្យមានការទប់ស្កាត់ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ហើយតម្រូវឱ្យចាត់វិធានការសមស្របបំផុត ដើម្បីការពារជនរងគ្រោះ ឬ ជនអាចនឹងរងគ្រោះ។ អំពើហិង្សារួមមាន៖ ការប៉ះពាល់ដល់ជីវិត ការប៉ះពាល់ដល់បូរណភាពរូបកាយ ការធ្វើទារុណកម្ម ឬការធ្វើអំពើឃោរឃៅ ការឈ្លានពានខាងផ្លូវភេទ។[46] តើក្នុងករណីនេះអាចចាត់ចូលក្នុងចំណុច “ ង ” នៃមាត្រា ៩៧៨ ក្នុងការសម្រេចលែងលះឱ្យភាគីដែរឬទេ ?

ចំពោះការលែងលះដោយសារការប្រើប្រាស់អំពើហិង្សាមួយ យោងតាមសំអាងហេតុរបស់តុលាការបានលើកឡើងថា ដើមចោទបានអះអាងថាអស់មនោសញ្ចេតនាជាប្តីប្រពន្ធជាមួយចុងចម្លើយ ដោយសារតែចុងចម្លើយតែងតែប្រើហិង្សាទៅលើខ្លួន និងឈ្លោះទាស់ទែងគ្នាញឹកញាប់ ដែលជាទង្វើមិនអាចទទួលយកបានឡើយ។ ដោយសារការអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត ទើបដើមចោទប្តឹងសុំទាមទារលែងលះពីចុងចម្លើយ តុលាការពិចារណាលើការទាមទាររបស់ដើមចោទ ដែលស្របតាមបញ្ញត្តិមាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុច “ ង ” នៃក្រមរដ្ឋប្បវេណី។ ដូចនេះតុលាការបានសម្រេចសេចក្តី លែងលះដើមចោទ និងចុងចម្លើយចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ។[47]

[44] សាលក្រមចំពោះមុខគូក្តី, លេខ ២២(ក), ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តតាកែវ។

[45] ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, លេខ នស/រកម/១០០៥/០៣១,ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០០៥, មាត្រា ៣៥។

[46] ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, លេខ នស/រកម/១០០៥/០៣១,ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០០៥, មាត្រា ៣។

[47] សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ៥៣ “ ង១ ”, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ២០២៣ ។

### ១.៥.២ ករណីដែលចរិយាប្រាសចាកពីសីលធម៌

ក្នុងមូលហេតុនៃការលែងលះរបស់ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានចែងថាប្តីប្រពន្ធអាចសុំលែងលះបានបើមានចរិយាផ្ទុយពីសីលធម៌ រឺប្រព្រឹត្តអនាចារ។ ករណីដែលចរិយាប្រាសចាកពីសីលធម៌ សំដៅលើការជេរប្រមាថ ម៉ាកងាយទៅលើសហព័ទ្ធម្ខាងទៀត ឬ សាច់ញាតិរបស់សហព័ទ្ធ ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់សហព័ទ្ធ ចំណែកឯការប្រព្រឹត្តជាការប្រព្រឹត្តពុំសមគួរ ឥតមារយាទ ខុសសណ្តាប់ធ្នាប់សង្គម ដូចជាលួចទៅមានប្រុសថ្មី ឬ ស្រីថ្មី ឬ លួចមានសាហាយស្មន់ លេងល្បែងស៊ីសងជាដើម គឺសុទ្ធសឹងតែជាមូលហេតុដែលធ្វើឱ្យសហព័ទ្ធអស់មនោសញ្ចេតនាពីគ្នា មិនអាចបន្តការរួមរស់ជាមួយគ្នា។ ទោះបីចំណុចនៃមូលហេតុមួយនេះមានចែងតែក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារក៏ដោយ ប៉ុន្តែតាមភាពជាក់ស្តែងបច្ចុប្បន្នបញ្ហាមួយនេះតុលាការតែងតែលើកយកចំណុច“ង”នៃក្រមរដ្ឋប្បវេណី ធ្វើជាគោលការណ៍ក្នុងការវិនិច្ឆ័យសម្រេចឱ្យលែងលះផងដែរ ដោយហេតុថាទង្វើទាំងនេះបានធ្វើឱ្យសហព័ទ្ធអស់មនោសញ្ចេតនាពីគ្នា លើសពីនេះទៅទៀតក៏អាចបណ្តាលឱ្យមានការផិតក្បត់ កើតមានជំលោះក្នុងគ្រួសារ ការប្រើប្រាស់អំពើហិង្សា ឬ កើតមានករណីឃាតកម្ម ជាដើម។

ក្នុងករណីលែងលះមួយ ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា រយៈពេល ៥ឆ្នាំ ដែលរស់នៅជាមួយគ្នា ចុងចម្លើយតែងតែជេរប្រមាថខ្លួន មិនឱ្យតម្លៃដើមចោទ អាងថាខ្លួនជាអ្នករកចំណូលចិញ្ចឹមគ្រួសារ។ លើសពីនេះទៅទៀតចុងចម្លើយ មិនគោរពឪពុកម្តាយក្មេកឡើយ ដោយប្រើពាក្យសម្តីមិនសមរម្យនៅពេល ដែលឪពុកម្តាយក្មេកចូលហាមឃាត់មិនឱ្យឈ្លោះគ្នា ដែលជាហេតុធ្វើឱ្យដើមចោទអស់មនោសញ្ចេតនា មិនអាចរស់នៅជាមួយគ្នាបន្តទៀតបាន។ ក្នុងសំអាងហេតុ តុលាការបានសម្រេចលើយកករណីនេះមកវិនិច្ឆ័យ ដោយផ្អែកតាមមាត្រា៩៧៨ ចំណុច “ ង ” មូលហេតុនៃការលែងលះនៃក្រមេដ្ឋប្បវេណី ដែលគប្បីឱ្យតុលាការពិចារណា និងសម្រេចតាមច្បាប់។ យោងតាមការវិនិច្ឆ័យ តុលាការបានសម្រេចផ្តាច់ចំណងអាពាហ៍ពិពាហ៍រវាងដើមចោទ និងចុងចម្លើយ។[48]

### ១.៥.៣ ប្តីដេញខ្លួនឱ្យចុះចេញពីលំនៅសង្វាសដោយឥតហេតុដ៏គួរ

ក្នុងករណីដែលប្តីដេញខ្លួនឱ្យចុះចេញពីលំនៅសង្វាសដោយឥតហេតុដ៏គួរ មូលហេតុនេះមានចែងតែក្នុងក្រមរដ្ឋប្បវេណីឆ្នាំ១៩២០តែប៉ុណ្ណោះ ដែលបានលើកឡើងធ្វើជាមូលហេតុនៃការសុំលែងលះរបស់ប្រពន្ធ។ ការដែលលើកយកចំណុចនេះកំណត់ជាមូលហេតុនៃការសុំលែងលះរបស់ប្រពន្ធ គឺក្នុងគោលបំណងការពារផលប្រយោជន៍របស់ប្រពន្ធទាំងឡាយនាសម័យនោះ ដោយហេតុថាក្នុងសម័យនោះច្បាប់បានចែងថា កិច្ចការទាំងពួងដែលស្ត្រីមានប្តីធ្វើឥតអនុញ្ញាតពីប្តីនឹងត្រូវទុកជាមោឃៈ ជាហេតុដែលស្ត្រីមានប្តីសម័យនោះពុំមាន

[48] សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ១០៤៣ “ ដ ”, ចុះថ្ងៃទី១៧ ខែ សីហា ឆ្នាំ២០១៨ ។

សិទ្ធិពេញលេញក្នុងការប្រកបមុខរបរវិជ្ជាជីវៈអ្វីឡើយ ដែលជាកត្តានាំឱ្យស្ត្រីពុំមានទ្រព្យសម្បត្តិផ្ទាល់ខ្លួនដើម្បីទំនុកបម្រុងខ្លួនឯង ប្រសិនបើត្រូវបាត់បង់ការទំនុកបម្រុងពីប្តីរបស់ខ្លួន។ ហើយក៏អាចបណ្តាលឱ្យកើតមានបញ្ហាជាច្រើនដូចជា សង្គមសម្បូរទៅដោយស្ត្រីមេម៉ាយ ជនអនាថា និងកូនៗត្រូវបាត់បង់ភាពកក់ក្តៅពីម្តាយ។ ហើយមួយវិញទៀត ក្នុងនាមជាប្តីប្រពន្ធត្រូវជួយសង្គ្រោះគ្នាទៅវិញទៅមក[49] មានន័យថា ទោះមានឧបសគ្គយ៉ាងណាក៏ដោយ ក៏ពុំគួរបោះបង់គ្នាឡើយ ការដែលបណ្តេញចេញដោយគ្មានមូលហេតុបែបនេះ គឺជាការមិនទទួលខុសត្រូវលើភរិយា ដែលបុរសជាស្វាមីពុំគួរធ្វើ ហើយទង្វើនេះគឺផ្ទុយពីច្បាប់ដែលបានចែងថា ប្តីត្រូវទំនុកបម្រុងលើប្រពន្ធទាំងឡាយ។[50]

ក្នុងសង្គមបច្ចុប្បន្នក៏មានករណីមួយនេះកើតឡើយផងដែរ តុលាការបានចាត់ករណីនេះ ចូលជាករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទាន។[51] តាមរយៈសំអាងហេតុ ក្នុងអំឡុងពេលរស់នៅជាមួយគ្នាដើមចោទ និងចុងចម្លើយតែងតែមានវិវាទរស់នៅមិនចុះសម្រុងគ្នា រហូតដល់ថ្ងៃមួយដើមចោទបានបណ្តេញចុងចម្លើយចេញពីផ្ទះ ហើយបានបន្តរស់នៅបែកគ្នារហូតដល់ថ្ងៃដាក់ពាក្យបណ្តឹង។ នៅក្នុងកាលបរិច្ឆេទនៃនីតិវិធីបណ្តឹងតុលាការបានព្យាយាមផ្សះផ្សាគូភាគីម្តងហើយម្តងទៀត ប៉ុន្តែគូភាគីនៅតែមិនមានឆន្ទៈចង់បន្តការរស់នៅជាមួយគ្នាទៀតឡើយ ដែលនេះស្តែងឱ្យឃើញថាទំនាក់ទំនងជីវភាពរស់នៅជាមួយគ្នារវាងដើមចោទ និងចុងចម្លើយត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទាន ដូចនេះតុលាការបានសម្រេចលើយកករណីនេះមកវិនិច្ឆ័យ តាមបញ្ញត្តិមាត្រា៩៧៨ កថាខណ្ឌ ១ ចំណុច “ ង ” ។ តុលាការបានសម្រេចសេចក្តី ដោយអនុញ្ញាតឱ្យដើមចោទឈប់រស់នៅជាអនីតិសង្វាសពីចុងចម្លើយចាប់ពីសាលក្រមចូលជាស្ថាពរ។[52]

### ១.៥.៤ មូលហេតុដែលប្តីមិនបានចិញ្ចឹមបីបាច់រក្សាប្រពន្ធកូនឱ្យគួរសមតាមភាតព្វកិច្ចនៃខ្លួនជាប្តី

ក្នុងក្រមរដ្ឋប្បវេណីចាស់បានចែងមូលហេតុនេះ ជាមូលហេតុដែលប្រពន្ធអាចសុំលែងលះប្តីដោយសារក្រមរដ្ឋប្បវេណីចាស់បានទទួលឥទ្ធិពលពីច្បាប់ទំនៀមទម្លាប់ និងបរិបទសង្គម ដែលគេយល់ថាការងារខាងក្រៅជាការងាររបស់បុរស រីឯការងារគេហកិច្ចជាការងាររបស់ស្ត្រី ច្បាប់ថែមទាំងបានចែងថាប្រពន្ធពុំមានសិទ្ធិពេញលេញក្នុងការប្រកបរបរផ្សេងៗបាន បើពុំមានការអនុញ្ញាតពីប្តី។ ដូច្នេះតម្រូវការចាយវាយរបស់ប្រពន្ធកូនទាំងអស់គឺពឹងផ្អែកលើប្តីទាំងស្រុង បើប្តីពុំផ្តល់ឱ្យប្រពន្ធកូនមុខជាជួបនូវបញ្ហាខ្វះខាតក្នុងការរស់នៅជាពុំខាន។

[49] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ១៨៧។

[50] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ១៨៨។

[51] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៧៨, ចំណុច ង។

[52] សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ២៧១២ “ ធ ”, ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧ ។

ទើបមានការដាក់បន្ទុកឱ្យប្តីត្រូវទំនុកបម្រុងប្រពន្ធទាំងឡាយ ក៏ដូចជាឱ្យចាយវាយតាមសមគួរដល់មុខរបរ និងធនធានដែលខ្លួនមាន ដូចនេះការចិញ្ចឹមបីបាច់រក្សាប្រពន្ធកូនជាតួនាទីរបស់ប្តី។ [53] ការដែលប្តីមិនអាចចិញ្ចឹមបីបាច់រក្សាប្រពន្ធកូនឱ្យសមគួរតាមកាតព្វកិច្ច ក្នុងករណីខ្លះក៏ព្រោះតែច្បាប់បានអនុញ្ញាតឱ្យប្តីមានប្រពន្ធបានច្រើន ទើបបណ្តាលឱ្យមានការលំបាកក្នុងការផ្គត់ផ្គង់គ្រួសារឱ្យបានសមគួរ ដូចនេះប្តីគួរតែមានទំនួលខុសត្រូវលើការសម្រេចចិត្តរបស់ខ្លួនក្នុងការរៀបការយកប្រពន្ធច្រើន អាចនិយាយបានថាការយកប្រពន្ធច្រើនបាន លុះត្រាតែបុរសជាប្តីនោះមានសមត្ថភាព មានទ្រព្យសម្បត្តិច្រើនក្នុងការទំនុកបម្រុងដល់គ្រួសារ។ តែក៏មានករណីផ្សេងៗទៀត ដែលបណ្តាលឱ្យប្តីពុំមានលទ្ធភាពក្នុងការចិញ្ចឹមប្រពន្ធកូន ដូចជាប្តីគិតតែពីលេងល្បែងស៊ីសង។ ចំពោះចំណុចនេះច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ព្រមទាំងក្រមរដ្ឋប្បវេណីបច្ចុប្បន្ន ពុំមានចែងចំណុចនេះក្នុងមូលហេតុនៃការលែងលះឡើយ។ តើករណីដែលប្តីមិនបានចិញ្ចឹមបីបាច់ប្រពន្ធកូននេះ អាចចាត់ចូលជាការបោះបង់សហព័ទ្ធចោលដែលជាចំណុចនៃមូលហេតុនៃការលែងលះក្នុងក្រមរដ្ឋប្បវេណីដែរឬទេ ?

បើទោះបីជាពុំមានចែងក្នុងក្រមរដ្ឋប្បវេណីបច្ចុប្បន្នក៏ដោយ ប៉ុន្តែមានករណីមួយដែលអាចចាត់ទុកថាជាករណីពាក់ព័ន្ធនឹងចំណុចដែលប្តីមិនមានទំនួលខុសត្រូវក្នុងការទំនុកបម្រុងចំពោះប្រពន្ធកូន។ ដើមចោទបានប្តឹងសុំលែងលះពីចុងចម្លើយ ដោយលើកហេតុផលថានៅពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ ចុងចម្លើយអត់មានទំនួលខុសត្រូវក្នុងគ្រួសារ យកល្បែងជាមុខរបរ តែងតែមានការខ្វែងគំនិតគ្នា និងរស់នៅមិនចុះសម្រុងគ្នា ទើបជាហេតុធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាពុំអាចរួមរស់ជាមួយគ្នាបានតទៅទៀត។ តាមរយៈនេះចុងចម្លើយក៏បានទទួលស្គាល់ចំពោះសេចក្តីថ្លែងការណ៍ និងសុខចិត្តលែងលះពីដើមចោទផងដែរ។ ដូច្នេះបញ្ជាក់បានថាទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ គឺជាមូលហេតុដែលអាចឱ្យគូភាគីលែងលះគ្នាបាន ស្របតាមបញ្ញត្តិមាត្រា ៩៧៨ កថាខណ្ឌ១ ចំណុច “ ង ” នៃក្រមរដ្ឋប្បវេណី។ ដូចនេះតុលាការបានសម្រេចសេចក្តីឱ្យដើមចោទ និងចុងចម្លើយលែងលះគ្នា។[54]

យោងតាមសាលក្រមខាងលើបានបង្ហាញថា ការដែលមិនបានជួយចិញ្ចឹមបីបាច់សហព័ទ្ធ ត្រូវបានតុលាការសម្រេចឱ្យលែងលះ បើយល់ឃើញថាករណីនេះបានបណ្តាលឱ្យសហព័ទ្ធអស់មនោសញ្ចេតនាពីគ្នា ។

### ១.៦ មូលហេតុដែលពុំមានចែងក្នុងក្រមរដ្ឋប្បវេណី

មូលហេតុមួយដែលពុំមានចែងទាំងក្នុងក្រមរដ្ឋប្បវេណីចាស់ និងក្រមរដ្ឋប្បវេណីបច្ចុប្បន្ន ហើយវាមានលក្ខណៈមិនសមគួរ គឺមូលហេតុអពលានុភាពនៃលិង្គ ដែលត្រូវបានច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានចាត់ទុកជាមូលហេតុនៃការលែងលះ។ ដោយច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានចែងថា ប្តីប្រពន្ធមាន

[53] ក្រមរដ្ឋប្បវេណី, ២៥ កុម្ភៈ ១៩២០, មាត្រា ១៩៣។

[54] សាលក្រមសាលាដំបូងខេត្តត្បូងឃ្មុំ, សំណុំរឿងរដ្ឋប្បវេណី, ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០។

ករណីយកិច្ចស្រលាញ់គ្នាទៅវិញទៅមក តែហេតុអ្វីបែរជាបញ្ហាមួយនេះត្រូវបានគេចាត់ចូលជាមូលហេតុនៃការលែងលះទៅវិញ? ទី១ ពាក់ព័ន្ធនឹងបញ្ហាសង្គម ព្រោះតែនាសម័យនោះគឺប្រទេសកម្ពុជាទើបតែបញ្ចប់ពីបញ្ហាសង្គ្រាមដែលធ្វើឱ្យកំណើនប្រជាជននៅកម្ពុជាមានការធ្លាក់ចុះ ជាហេតុដ៏ចាំបាច់មួយក្នុងការបង្កើននូវកំណើនប្រជាជនឡើងវិញ។ ព្រោះការអសមត្ថភាពខាងផ្លូវភេទ អាចធ្វើឱ្យប៉ះពាល់ដល់ការកសាងសង្គមមនុស្ស អាត្រានៃមនុស្សជាតិនឹងមានការធ្លាក់ចុះ ដែលជាកង្វល់របស់សង្គមជាតិមួយត្រូវពិចារណា គេជឿថាសង្គមជាតិមួយដែលមានចំនួនប្រជាជនច្រើន ធនធានមនុស្សក៏មានច្រើនដូចគ្នា ដែលធនធានមនុស្សទាំងអស់នឹងជួយដល់ការអភិវឌ្ឍសង្គមទាំងមូល។ បញ្ហាទី២ ជាបញ្ហាតម្រូវការផ្លូវភេទរបស់ភរិយាផងដែរ នៅពេលដែលបុរសម្នាក់មិនអាចមានសមត្ថភាពក្នុងការរួមដំណេកបាន មិនអាចកំដរតាមការចង់បានរបស់ភរិយា អាចក្លាយជាកត្តាមួយដែលនាំឱ្យសហព័ទ្ធអស់មនោសញ្ចេតនា ហើយឈានទៅដល់មានការផិតក្បត់ជាដើម។ សហព័ទ្ធអាចប្តឹងសុំលែងលះបានផ្អែកលើមូលហេតុមួយនេះ ឬ ករណីដែលមូលហេតុនេះបណ្តាលឱ្យភាគីអស់មនោសញ្ចេតនាជាប្តីប្រពន្ធបាន តុលាការនឹងសម្រេចឱ្យលែងលះ ដោយយល់ឃើញថា ការដែលមិនអាចបំពេញតាមតម្រូវការប្រពន្ធបាន នោះនឹងអាចកើតមានករណីផិតក្បត់ទៅលើប្តី ដើម្បីបំពេញតាមចំណង់របស់ខ្លួន ឬ មូលហេតុនេះពិតជាបណ្តាលឱ្យភាគីអស់មនោសញ្ចេតនារវាងគ្នាពិតប្រាកដមែន។

### ១.៧ មូលហេតុដែលមិនអាចលែងលះបាន

ទោះបីមានការទាមទារយ៉ាងខ្លាំងតុលាការក៏អាចច្រានចោលការទាមទារនៃការលែងលះ ដោយពិចារណាទៅលើស្ថានភាពទាំងឡាយ បើទោះបីមានមូលហេតុនៃការលែងលះ ដូចមានការកំណត់ខាងលើក៏ដោយ៖

ករណីដែលការលែងលះនោះនឹងបណ្តាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ និងកូនក្រលំបាកយ៉ាងខ្លាំង ឬមានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន ។

ករណីដែលការទាមទារនោះផ្ទុយនឹងភាពសុចរិត ដោយជនដែលបានទាមទារឱ្យលែងលះគ្នានោះធ្វេសប្រហែសយ៉ាងខ្លាំង ក្នុងការសហការ និងជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោលការទាមទារនោះដោយឆន្ទានុសិទ្ធិបាន។

## ២. នីតិវិធីនៃការលែងលះដោយមានមូលហេតុ ឬ ដោយពុំមានការព្រមព្រៀង

ដោយហេតុថាភាគីដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ត្រូវគោរពទៅតាមនីតិវិធីនៃការលែងលះ ពោលគឺទៅតាមវិធានចាត់ចែងការងាររបស់តុលាការ ចំពោះករណីការលែងលះនោះពុំមានការព្រមព្រៀង ត្រូវស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដើម្បីផ្តាច់សមគ្គសង្វាសពីគ្នា ដោយការពារផលប្រយោជន៍របស់សហព័ទ្ធ និងកូនៗឱ្យបានសមស្របទៅតាមស្ថានភាព។

## ២.១ ការដាក់ពាក្យបណ្តឹង

នៅក្នុងរឿងក្តីលែងលះ ដែលជាប្រភេទនៃសំណុំរឿងរដ្ឋប្បវេណី ការដាក់ពាក្យបណ្តឹងគឺជាដំណាក់កាលដ៏សំខាន់មួយ ដោយហេតុថាបណ្តឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន ដូចនេះមានការដាក់ពាក្យបណ្តឹងទើបមានការដោះស្រាយ មានន័យថាក្នុងរឿងក្តីរដ្ឋប្បវេណីតុលាការពុំមានសមត្ថភាពក្នុងការចាប់ផ្តើម ដោយឆន្ទានុសិទ្ធិឡើយ ទាល់តែមានការទាមទារ ដោយការដាក់ពាក្យបណ្តឹងពីភាគីទើបតុលាការអាចធ្វើការដោះស្រាយបាន។

ក្នុងការដាក់ពាក្យបណ្តឹងភាគីខាងដើមចោទត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយលិខិតនៃពាក្យបណ្តឹង ត្រូវបញ្ជាក់អំពីអត្តសញ្ញាណភាគី អាសយដ្ឋានភាគី ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងមូលហេតុនៃការទាមទារ ព្រមទាំងភ្ជាប់មកជាមួយនឹងសំបុត្រអាពាហ៍ពិពាហ៍ និងឯកសារនានាដូចជាទ្រព្យសម្បត្តិ ឬ បំណុលជាដើម ដើម្បីឱ្យតុលាការធ្វើការពិនិត្យ វិនិច្ឆ័យ និងសម្រេចសេចក្តី។ ការដាក់ពាក្យនេះដែរ ភាគីខាងដើមចោទត្រូវយកទៅដាក់នៅតុលាការដោយផ្ទាល់ ឬ នៅក្រុមប្រឹក្សាឃុំសង្កាត់ ខាងលំនៅឋានរបស់ភាគីខាងចុងចម្លើយ។[55] ចំពោះការដាក់ពាក្យបណ្តឹងលែងលះត្រឹមក្រុមប្រឹក្សាឃុំសង្កាត់ នោះក្រុមប្រឹក្សាឃុំសង្កាត់នឹងត្រូវព្យាយាមសម្របសម្រួល ឬបញ្ចុះបញ្ចូលផ្សះផ្សា ឱ្យភាគីជាសះនឹងគ្នាក្នុងរយៈពេល ១៥ថ្ងៃគិតចាប់ពីថ្ងៃដែលទទួលបានពាក្យបណ្តឹងនោះប្រសិនបើមិនអាចបញ្ចុះបញ្ចូលផ្សះផ្សាបានទេ ត្រូវចាត់ទុកថាមានពាក្យបណ្តឹងលែងលះគ្នា ហើយក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅកាន់តុលាការជាបន្ទាន់។[56] គួរបញ្ជាក់ផងដែរថាក្រុមប្រឹក្សាឃុំសង្កាត់ពុំមានសិទ្ធិសម្រេចឡើយ ការលែងលះត្រឹមឃុំសង្កាត់ពុំមានអានុភាពឡើយ។ សម្រាប់ការដាក់ពាក្យបណ្តឹងខាងលើនេះ ដើមចោទត្រូវបង់ពន្ធដាក់ពាក្យបណ្តឹងចំនួន ៥៥.០០០ (ប្រាំម៉ឺនប្រាំពាន់) រៀល។

ក្រោយទទួលបានពាក្យបណ្តឹង តុលាការដែលមានសមត្ថកិច្ចត្រូវធ្វើការពិនិត្យពាក្យបណ្តឹងជាមុន ដោយពិនិត្យទៅលើមូលហេតុនៃការទាមទារដែលជាចំណុចសំខាន់ មុនពេលសម្រេចចាប់ផ្តើមនីតិវិធី ក្នុងករណីដែលតុលាការយល់ឃើញថាពុំសមហេតុផល ឬ ពុំត្រឹមត្រូវ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឱ្យកែតម្រូវ បើពុំកែតម្រូវទេនោះតុលាការអាចលើកចោលពាក្យបណ្តឹងដោយដីកាសម្រេចបាន។ នៅពេលត្រួតពិនិត្យរួចរាល់តុលាការត្រូវកោះហៅដើមចោទឱ្យចូលមក ដើម្បីបញ្ចុះបញ្ចូលឱ្យឈប់ប្តឹង បន្ទាប់មកបើដើមចោទនៅតែរក្សាគោលគំនិតក្នុងការប្តឹងដដែល នោះតុលាការត្រូវបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយជាចាំបាច់។[57] ហើយក្នុងករណីដែលយល់ថាចាំបាច់តុលាការក៏អាចចាត់វិធានការបណ្តោះអាសន្នបាន ដូចជា

---

[55] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ២០ ឧសភា ២០១០, មាត្រា៥, កថាខណ្ឌ ១។

[56] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៨២។

[57] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា៧៩។

វិធានការឱ្យសហព័ទ្ធរស់នៅបែកគ្នាបណ្ដោះអាសន្ន វិធានការឱ្យសហព័ទ្ធណាមួយថែរក្សាកូនបណ្ដោះអាសន្ន វិធានការថែរក្សាទ្រព្យសម្បត្តិបណ្ដោះអាសន្ន វិធានការផ្ដល់អាហារកិច្ចបណ្ដោះអាសន្នចំពោះកូន និងសហព័ទ្ធ ឬ ដីកាហាមឃាត់សិទ្ធិមួយចំនួនរបស់ប្ដី ឬ ប្រពន្ធជាដើម។ ជាចុងក្រោយតុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើដំបូង។ រីឯក្នុងក្រមរដ្ឋប្បវេណីចាស់វិញ ក្រោមទទួលបានពាក្យបណ្ដឹងចាងហ្វាង ត្រូវហៅអ្នកប្ដឹងឱ្យចូលមក ហើយនិយាយរំឭកប្រដៅសម្រួលតាមដែលយល់ឃើញថាគួរដើម្បីនឹងបញ្ចូលចិត្តឱ្យឈប់ប្ដឹង ប្រសិនបើមិនអាចបញ្ចុះបញ្ចូលបានទើបច្បាប់ផ្ដើមនីតិវិធី។

### ២.២ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

បន្ទាប់ពីថ្ងៃដែលពាក្យបណ្ដឹងត្រូវបានដាក់ តុលាការត្រូវកំណត់កាលបរិច្ឆេទលើកដំបូងក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងរហ័ស និងកោះហៅគូភាគីក្នុងរយៈពេល ៣០ថ្ងៃ លើកលែងតែក្នុងករណីដែលមានមូលហេតុពិសេស។[58] នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីនៃការត្រៀមរៀបចំសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ដើម្បីលើកកំពស់ និងសម្រួលដល់ការជម្រះក្ដីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។[59] ក្នុងនីតិវិធីនេះដែលគឺមិនកំណត់អំឡុងពេលឡើយ តុលាការអាចកោះហៅប្ដីប្រពន្ធដើម្បីធ្វើការផ្សះផ្សា សាកសួរ ពិនិត្យភស្តុតាងបាន។ ក្នុងដំណាក់កាលនេះដែរ មេធាវីមិនត្រូវបានអនុញ្ញាតឱ្យចូលរួមស្ដាប់ឡើយ ហើយការកោះហៅក្នុងនីតិវិធីនេះអាចធ្វើឡើងបានច្រើនដង។

ចំពោះការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បងផ្សះផ្សាជាដំបូងសិន លើកលែងតែយល់ថាមិនសមរម្យ ។[60] ចំពោះការផ្សះផ្សាក្រមរដ្ឋប្បវេណីចាស់ និងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ បានចែងដូចគ្នាក្នុងករណីដែលភាគីម្ខាងមិនបានចូលតាមការកោះ ដោយពុំមានមូលហេតុត្រឹមត្រូវ តុលាការអាចធ្វើការកោះហៅជាលើកទី ២បាន។[61] ហើយក្នុងករណីដែលពុំបានចូលតាមការកោះហៅលើកទី២ទេ ចំពោះភាគីខាងដើមចោទត្រូវចាត់ទុកថាសុខចិត្តឈប់ប្ដឹង។[62] រីឯខាងចុងចម្លើយត្រូវទុកថាមិនព្រមសះជានឹងគ្នា។[63] ក្នុងករណីដែលមិនបានចូលម្នាក់ម្ដងតុលាការត្រូវធ្វើការកោះហៅជាលើកទី៣។ [64] ការផ្សះផ្សាម្ដងៗត្រូវឱ្យឃ្លាតពីគ្នា ១ខែយ៉ាងឆាប់ និង២ខែយ៉ាងយូរ និងត្រូវចុះក្នុងកំណត់ហេតុគ្រប់ពេល មិនថាការផ្សះផ្សាបានសម្រេច ឬ មិនបានសម្រេចទេ ឬ ករណីដែលភាគីមិនបានចូលរួម ក៏ត្រូវបញ្ជាក់ក្នុងកំណត់ហេតុ

[58] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា ៨០។
[59] សៀវភៅច្បាប់នីតិវិធីរដ្ឋប្បវេណី ផ្នែកទី១ នីតិវិធីបណ្ដឹង របស់មេធាវី កែវ វ៉ាន់នី។
[60] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា ១០៤។
[61] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ២១៨។
[62] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ២១៩។
[63] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ២២០។
[64] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ២២១។

ផងដែរ។ ក្នុងកំណត់ហេតុចៅក្រមទទួលបន្ទុក ក្រឡាបញ្ជី ព្រមទាំងភាគីមានវត្តមានត្រូវចុះហត្ថលេខា។ ដំណើរការរឿងក្តីត្រូវតែចាប់ផ្តើមកាលបើការផ្សះផ្សាមិនអាចធ្វើបានសម្រេច។

### ២.៣ ការទាញហេតុផលផ្ទាល់មាត់

បើការផ្សះផ្សាមិនបានសម្រេច តុលាការដែលមានសមត្ថកិច្ចត្រូវកោះហៅប្តីប្រពន្ធឱ្យចូលមកកាន់តុលាការដើម្បីជំនុំជម្រះក្តី។ ក្នុងរឿងក្តីលែងលះដែលជារឿងក្តីរដ្ឋប្បវេណីពុំមានសមាសភាពតំណាងអយ្យការឡើយ មានន័យថាតំណាងអយ្យការពុំមែនជាភាគី ដូចនេះតំណាងអយ្យការអាចចូលរួម និងបញ្ចេញយោបល់បាន លុះត្រាតែមានការកោះហៅពីចៅក្រមទទួលបន្ទុក នៅពេលដែលចៅក្រមយល់ថាចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ ឬ តំណាងអយ្យការខ្លួនឯងយល់ថាចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ អាចចូលរួមដោយមិនមានការកោះហៅបាន។

តុលាការត្រូវធ្វើការអង្កេតស៊ើបសួរ ប្រសិនបើចុងចម្លើយប្រកែកថា សេចក្តីដែលប្តឹងពីខ្លួននោះមិនពិត។ បើមានការត្រូវអង្កេត តុលាការត្រូវបង្គាប់ឱ្យគូភាគីផ្តល់ភស្តុតាង ឬកោះហៅសាក្សីដែលមានប្រយោជន៍ក្នុងរឿងក្តី។ ក្រោយពីអង្កេតស៊ើបសួរឃើញថា ស្ថានភាពប្តីប្រពន្ធមានភាពធ្ងន់ធ្ងរ ពិតជាមិនអាចបន្តការរួមរស់ជាមួយគ្នាបានទេ តុលាការត្រូវសម្រេចឱ្យលែងលះគ្នា ដោយចេញសាលក្រមលែងលះ។ ក្នុងដំណាក់កាលជំនុំជម្រះ ករណីដែលដើមចោទមិនបានបង្ហាញខ្លួនដោយឥតមូលហេតុ និងមិនបានដាក់ពាក្យសុំពន្យាពេលជំនុំជម្រះ ត្រូវចាត់ទុកថាសុខចិត្តឈប់ប្តឹង ហើយតុលាការត្រូវចេញសាលក្រមលុបរឿងក្តីចោល។ ចំណែកឯករណីដែលចុងចម្លើយមិនបានបង្ហាញខ្លួនដោយឥតមូលហេតុ និងមិនបានដាក់ពាក្យសុំពន្យាពេលជំនុំជម្រះវិញ បើតុលាការយល់ឃើញថាហេតុដែលដើមចោទប្តឹងនោះមានភស្តុតាងត្រឹមត្រូវពិតប្រាកដ តុលាការអាចសម្រេចសេចក្តីឱ្យលែងលះគ្នាបាន។

### ២.៤ ការប្រកាសសាលក្រម

ចំពោះការប្រកាសសាលក្រមនេះដែរ តុលាការត្រូវប្រកាសក្រោយធ្វើការទាញហេតុផលផ្ទាល់មាត់ចប់សព្វគ្រប់រយៈពេល ១ខែ។[65] ជាគោលការណ៍សាលក្រមលែងលះត្រូវតែជាសាលក្រមធម្មតា ដោយសម្រេចនៅចំពោះមុខគូក្តី។ ប្រសិនបើសាលក្រមជាសាលក្រមកំបាំងមុខ គូភាគីត្រូវធ្វើការប្តឹងទាស់ក្នុងរយៈពេល ១៥ ថ្ងៃគិតចាប់ថ្ងៃដែលបានឱ្យដំណឹងពីសាលក្រមកំបាំងមុខនោះដល់គូភាគី។ មិនដូច្នេះទេ សាលក្រមកំបាំងមុខនោះនឹងទៅជាសាលក្រមស្ថាពរ ឬក្នុងករណីដែលបានប្តឹងក្នុងរយៈពេលកំណត់ ប៉ុន្តែមិនបានចូលខ្លួនពេលជំនុំជម្រះ ដោយពុំមានមូលហេតុ នោះសាលក្រមកំបាំងមុខត្រូវតម្កល់ទុកជាបានការ។ ក្រោយពីទទួលបានបណ្តឹងទាស់ តុលាការត្រូវពិនិត្យ បើត្រឹមត្រូវតាមច្បាប់តុលាការត្រូវធ្វើការជំនុំជម្រះលើអង្គហេតុ និងអង្គច្បាប់សាជាថ្មី។

[65] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ៦ កក្កដា ២០០៦, មាត្រា ១៨៧, កថាខណ្ឌ១។

# ជំពូកទី២ អានុភាព និងសេចក្ដីសម្រេច

កាលពីសម័យបុរាណ មិនថាប្រទេសណាក៏ដោយស្ត្រីតែងតែត្រូវបានសង្កមរើសអើង មិនថាសង្គមការងារ ឬ សង្គមគ្រួសារឡើយ ដូចជាការដែលហាមឃាត់មិនឱ្យស្ត្រីចូលរួមក្នុងការបម្រើការងារមួយចំនួន ការមិនអនុញ្ញាតឱ្យស្ត្រីចុះកិច្ចសន្យាផ្សេងៗ កាលដែលប្ដីមិនអនុញ្ញាត មានន័យថាចំពោះទ្រព្យសម្បត្តិនានា ស្ត្រីជាប្រពន្ធអាចមានឈ្មោះជាម្ចាស់កម្មសិទ្ធិបានលុះត្រាតែប្ដីអនុញ្ញាត។ តាមន័យនេះអាចសន្និដ្ឋានថា សិទ្ធិលើទ្រព្យសម្បត្តិរបស់ស្ត្រីតិចជាងបុរស។ ក្រោយពីមានការរើបម្រាស់ពីសំណាក់ស្ត្រី ក៏មានការលុបបំបាត់លើការរើសអើងចំពោះស្ត្រី ស្ត្រីនិងបុរសទទួលបានសិទ្ធិលើទ្រព្យសម្បត្តិស្មើគ្នា ទាំងក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ និងទាំងក្រោយពេលលែងលះ។ ដូចនេះពេលមានករណីលែងលះ អានុភាពនៃអាពាហ៍ពិពាហ៍ត្រូវបានរំលាយ ដើម្បីឱ្យមានលក្ខណៈដាច់ស្រេចគ្រប់យ៉ាងដែលបានកើតឡើងអំឡុងពេលអាពាហ៍ពិពាហ៍ ត្រូវបែងចែកជាពីរ ដូចជាការបែងចែកទ្រព្យសម្បត្តិ ការបែងចែកកាតព្វកិច្ច អាហារកាតព្វកិច្ចជាដើម។

## ១. ចំណងអាពាហ៍ពិពាហ៍

គួរបញ្ជាក់ផងដែរថា មិនថាការលែងលះដោយការព្រមព្រៀង ឬ ការលែងលះដោយពុំមានការព្រមព្រៀងឡើយ ចំណុចសំខាន់ដែលតុលាការមិនអាចមើលរំលងក្នុងការលើកមកវិនិច្ឆ័យមួយទៀតនោះគឺ ការចុះសំបុត្រអាពាហ៍ពិពាហ៍ ករណីដែលភាគីពុំមានការចុះសំបុត្រអាពាហ៍ពិពាហ៍ ការដែលលើកយកសំណុំរឿងនោះមកដោះស្រាយ គឺត្រូវសម្រេចតាមឆន្ទានុសិទ្ធិរបស់តុលាការ។ ចំពោះករណីដែលមានសំបុត្រអាពាហ៍ពិពាហ៍ក៏ដោយ ក៏តុលាការអាចសម្រេចលើកចោលពាក្យបណ្ដឹងបានដែរ ករណីដែលការលែងលះនោះបណ្ដាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ និងកូនក្រលំបាកយ៉ាងខ្លាំង ឬ មានការឈឺចាប់ដែលពុំអាចទ្រាំទ្របាន ឬ ករណីដែលការទាមទារនោះផ្ទុយនឹងភាពសុចរិត ដោយជនដែលបានទាមទារឱ្យលែងលះគ្នានោះ ធ្វេសប្រហែសយ៉ាងខ្លាំង ក្នុងការសហប្រតិបត្តិ និងជួយសង្គ្រោះចំពោះសហព័ទ្ធ តុលាការអាចច្រានចោលការទាមទារនោះដោយឆន្ទានុសិទ្ធិបាន។[66] ការដែលសម្រេចលើកចោល ឬ ដោះស្រាយនេះក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ពុំបានបែងចែកឡើយថា តុលាការមានសិទ្ធិលើកចោល ឬ លើកយកមកវិនិច្ឆ័យ។ ក៏ប៉ុន្តែច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានចែងថាការសម្រេចអំពីការលែងលះគ្នា ជាសមត្ថកិច្ចរបស់តុលាការប្រជាជនខេត្តក្រុងខាងលំនៅឋានចុងចម្លើយ។[67]

ក្នុងករណីមួយដែលទំនាក់ទំនងរវាងដើមចោទ និងចុងចម្លើយ គឺការរស់នៅជាមួយគ្នាបែបអនីតិសង្វាស។ ក្នុងសំអាងហេតុ តុលាការបានលើកឡើងថា បើពិនិត្យលើការដាក់ពាក្យបណ្ដឹងនេះ ជាបណ្ដឹងផ្ទុយនឹងច្បាប់

[66] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៧៨, កថាខណ្ឌ ទី២ និងទី៣។

[67] ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា៤១។

ដែលគប្បីតុលាការសម្រេចលើកចោល តាមបញ្ញត្តិមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ គូភាគីដែលរស់នៅតាមបែបអនីតិសង្វាស តាមផ្លូវច្បាប់ គឺមិនទទួលស្គាល់ថាជាប្តីប្រពន្ធនោះទេ។ បន្ថែមពីនេះដោយសារតែដើមចោទ និងចុងចម្លើយមិនមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។ ដូចនេះដើមចោទ និងចុងចម្លើយមានសិទ្ធិពេញលេញនៅក្នុងការរៀបអាពាហ៍ពិពាហ៍តាមឆន្ទៈរបស់ខ្លួនរៀងៗខ្លួន ដោយមិនមានការជំទាស់ពីភាគីម្ខាងណាឡើយ។ ហេតុដូច្នេះតុលាការបានសម្រេច លើចោលពាក្យបណ្តឹង។[68]

ក្នុងករណីដូចគ្នានេះដែរ គូភាគីបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋានឃុំដែលខ្លួនរស់នៅឡើយ។ ប៉ុន្តែតុលាការបានទទួលស្គាល់ចំណងអាពាហ៍ពិពាហ៍នោះថាត្រឹមត្រូវតាមច្បាប់ និងបានលើកយកសំណុំរឿងនោះមកវិនិច្ឆ័យ។ ដោយហេតុថាតាមការអះអាងរបស់ភាគីសុំលែងលះនេះគឺបណ្តាលមកពី ការរស់នៅបែកគ្នាអស់រយៈពេល៣ទៅ៤ឆ្នាំ ដែលជាហេតុធ្វើឱ្យអស់មនោសញ្ចេតនាមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបាន តាមការអះអាងខាងលើពិតជាស្តែងឱ្យឃើញថា ចំណងអាពាហ៍ពិពាហ៍របស់គូភាគីពិតជាឈានដល់ចំណុចត្រូវបែកបាក់ហើយគ្មានសង្ឃឹមថានឹងអាចបដិទានបានឡើយ ទោះបីជាតុលាការបានព្យាយាមធ្វើការផ្សះផ្សាយ៉ាងណាក៏ដោយក៏ភាគីដើមចោទមិនអាចសះជាបានឡើយ ដូច្នេះគប្បីតុលាការពិចារណាដោយផ្អែកតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី។ ដូចនេះសេចក្តីសម្រេចបញ្ចប់ តុលាការបានបង្គាប់ឱ្យដាច់អនីតិសង្វាសពីគ្នាជាប្តីប្រពន្ធ និងធ្វើការបែងចែកការទាមទារផ្សេងៗតាមធម្មតា។[69]

ភាគច្រើននៃករណីដែលពុំមានសំបុត្រអាពាហ៍ពិពាហ៍ តុលាការនឹងធ្វើការលើកចោល ដោយគ្រាន់តែបញ្ជាក់ថាភាគីមានសិទ្ធិពេញលេញនៅក្នុងការរៀបអាពាហ៍ពិពាហ៍តាមឆន្ទៈរៀងៗខ្លួន ដោយមិនមានការជំទាស់ពីភាគីម្ខាងណាឡើយ។ ចំពោះករណីដែលសហព័ទ្ធមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ក្រោយការពិនិត្យនូវពាក្យបណ្តឹង ឬ ពាក្យសុំ ឃើញថាពិតជាត្រឹមត្រូវតាមច្បាប់ តុលាការនឹងធ្វើការទទួលស្គាល់ថាភាគីមានជាប់ចំណងអាពាហ៍ពិពាហ៍នឹងគ្នាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការ សម្រេចឱ្យដើមចោទ និងចុងចម្លើយលែងលះគ្នា។

## ២. ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ

ពាក់ព័ន្ធនឹងប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ នៅកាលសម័យបុរាណស្ត្រីជាប្រពន្ធពុំសូវមានទ្រព្យសម្បត្តិផ្ទាល់ខ្លួនឡើយ ព្រោះវាហាក់បីដូចជាមានភាពលំបាកសម្រាប់ស្ត្រីក្នុងការចុះកិច្ចសន្យានានា ដោយសាររាល់ការចុះកិច្ចសន្យាត្រូវមានការអនុញ្ញាតពីប្តី ទោះបីមានការអនុញ្ញាតឱ្យស្ត្រីប្តឹងតុលាការសាលារដ្ឋប្បវេណីក្នុង

[68] សាលក្រមសាលាដំបូងខេត្តកំពង់ស្ពឺ, សំណុំរឿងរដ្ឋប្បវេណី, ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២ ។

[69] សាលក្រមសាលាដំបូងព្រៃវែង, សំណុំរឿងរដ្ឋប្បវេណី, បណ្តឹងចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩។

ករណីដែលប្តីមិនអនុញ្ញាតក៏តុលាការត្រូវសួរប្តីដដែល។ [70] ក្រោយមានការផ្លាស់ប្តូរទើបស្ត្រីទទួលបានសិទ្ធិពេញលេញក្នុងការធ្វើជាម្ចាស់កម្មសិទ្ធិ ក៏ដូចជាមានឈ្មោះជាកម្មសិទ្ធិករក្នុងទ្រព្យសម្បត្តិរួម។ ដូចនេះបច្ចុប្បន្ននៅពេលមានការលែងលះ គឺមានការបែងចែកទ្រព្យសម្បត្តិដូចគ្នា ដែលការបែងចែកនេះធ្វើឡើងជាពីររបៀប គឺការបែងចែកដោយការព្រមព្រៀងគ្នា និងការបែងចែកដោយតុលាការ។

### ២.១ ការបែងចែកទ្រព្យដោយការព្រមព្រៀងគ្នា

ការបែងចែកទ្រព្យដោយការព្រមព្រៀង គឺធ្វើការបែងចែកទ្រព្យសម្បត្តិដោយឡែក ឬ ទ្រព្យរួមរបស់សហព័ទ្ធ ដែលកើតមានក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍។ គួរបញ្ជាក់ផងដែរថា ពាក់ព័ន្ធនឹងករណីការបែងចែកទ្រព្យដោយការព្រមព្រៀងដែលអាចធ្វើឡើងជាពីរវិធី៖

#### ២.១.១ ការបែងចែកតាមកិច្ចសន្យា

ការបែងចែកទៅតាម ខ ចែងនៅក្នុងកិច្ចសន្យាដែលបានចុះកិច្ចព្រមព្រៀងជាមួយគ្នា នៅមុនពេល ឬ ក្រោយពេលរៀបអាពាហ៍ពិពាហ៍ ដែលជាទូទៅស្គាល់ថាជាកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ ករណីនេះ បានអនុវត្តនៅជាច្រើនប្រទេសដូចជាប្រទេសជប៉ុនជាដើម បើទោះបីជាក្រមរដ្ឋប្បវេណីខ្មែរបានទទួលឥទ្ធិពលពីក្រមរដ្ឋប្បវេណីរបស់ប្រទេសជប៉ុនក៏ដោយ ប៉ុន្តែនៅមិនទាន់មានគ្រួសារខ្មែរណាបានចុះកិច្ចសន្យានេះនៅឡើយទេ បើតាមការអះអាងរបស់ថ្នាក់ដឹកនាំនៃក្រសួងយុត្តិធម៌នៅត្រឹមខែធ្នូ ឆ្នាំ២០១២។[71] គួរបញ្ជាក់ផងដែលថា ករណីការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ បានបញ្ញត្តតាំងពីសម័យមុនមកម្លេះ ដោយក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ បានចែងពាក់ព័ន្ធនឹងករណីការចុះកិច្ចសន្យាបែងចែកទ្រព្យសម្បត្តិ ដោយបានបញ្ញត្តថាទ្រព្យរបស់ប្តីប្រពន្ធដែលលែងគ្នានោះត្រូវចែងតាមកិច្ចសន្យាមាតិកកណ្ឌដោយឡែក។[72] មានន័យតុលាការនឹងសម្រេចតាម ខ ចែងក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបើមាន។ ប្រសិនបើពុំមានកិច្ចសន្យាមាតិកកណ្ឌដោយឡែកទេ ក្រោយពេលលែងលះក្រៅពីប្រពន្ធទី១ ស្ត្រីដែលជាប្រពន្ធឯទៀតអនុញ្ញាតឱ្យយកតែទ្រព្យសម្បត្តិផ្ទាល់ខ្លួនតែប៉ុណ្ណោះ។

#### ២.១.២ ការពិភាក្សាបែងចែកទ្រព្យសម្បត្តិរបស់ភាគី

ការបែងចែកទៅតាមការព្រមព្រៀងរបស់ភាគី តាមការព្រមព្រៀងរបស់ភាគីនេះមានលក្ខណៈងាយស្រួលសម្រាប់ចៅក្រមក្នុងការសម្រេចសេចក្តី។ ក្នុងករណីមានលែងលះគ្នា ការបែងចែកទ្រព្យសម្បត្តិដោយការព្រមព្រៀងនេះ ពុំមានចែងក្នុងក្រមរដ្ឋប្បវេណីចាស់ឡើយ។ ក៏ប៉ុន្តែច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានចែងថា ក្នុងករណីមានការលែងលះគ្នា ទ្រព្យសម្បត្តិត្រូវបែងចែកដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់ភាគី

---

[70] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា២០១។

[71] សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍ភាគ២ ឆ្នាំ២០២៣, ទំព័រទី ៤, រៀបរៀងដោយ ឥត យឿន។

[72] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា២០១។

ទាំងសងខាង។[73] ហើយក្រមរដ្ឋប្បវេណីបច្ចុប្បន្នក៏បានបញ្ញត្តប្រហាក់ប្រហែលគ្នាថា ក្នុងករណីមានការលែងលះទ្រព្យសម្បត្តិត្រូវបែងចែកដោយយុត្តិធម៌ ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង នេះជាគោលការណ៍ដែលគោរពតាមការសម្រេចចិត្ត និងតាមស្មារតីរបស់ភាគី។[74]

ក្នុងករណីមួយភាគីបានរៀបអាពាហ៍ពិពាហ៍ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។ នៅពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធពួកគាត់មានទ្រព្យរួមមួយចំនួនដូចជា ដីលំនៅឋានចំនួន ០១កន្លែង ទំហំ ៥០០ម² ព្រមទាំងផ្ទះប្រក់ដំបូលក្បឿងចំនួន ០២ខ្នង ទំហំ ៦ម៉ែត្រ x ៨ម៉ែត្រ នៅលើដីនោះ ប៉ុន្តែពេលរស់នៅជាមួយគ្នាពួកគាត់តែងតែមានរឿងឈ្លោះប្រកែកគ្នា បណ្តាលឱ្យអស់មនោសញ្ចេតនាមិនអាចបន្តការរួមរស់ជាមួយគ្នាបានទៀត។ សហព័ទ្ធទាំងពីរបានសម្រេចព្រមព្រៀងគ្នាក្នុងការលែងលះ ព្រមទាំងបានព្រមព្រៀងគ្នាក្នុងការបែកចែកទ្រព្យសម្បត្តិរួម ដោយស្នើសុំឱ្យតុលាការលក់ដេញថ្លៃទ្រព្យរួម ហើយប្រគល់ប្រាក់លក់នោះម្នាក់ពាក់កណ្តាល។ នៅដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលផ្ទាល់មាត់ភាគីទាំងពីរនៅតែអះអាងក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួនដូចគ្នាថា សុំឱ្យតុលាការបង្គាប់ឱ្យលក់ដេញថ្លៃនូវទ្រព្យសម្បត្តិរួម។ តាមរយៈសំអាងហេតុរបស់តុលាការ បានលើកឡើងថាយោងតាមមាត្រា ៩៨០-១ នៃក្រមរដ្ឋប្បវេណី គប្បីតុលាការសម្រេចបែងចែកទ្រព្យសម្បត្តិរួមតាមការព្រមព្រៀងរបស់ដើមចោទ និងចុងចម្លើយ។[75]

យោងតាមការលើកឡើងករណីខាងលើ ចំពោះករណីព្រមព្រៀងនេះ គឺមានលក្ខណៈងាយស្រួលសម្រាប់តុលាការក្នុងការសម្រេចសេចក្តី ព្រោះក្នុងរឿងក្តីលែងលះតុលាការត្រូវសម្រេចតាមការពិភាក្សារបស់ភាគីជាគោល។

### ២.២ ការបែងចែកទ្រព្យសម្បត្តិដោយតុលាការ

ការបែងចែកទ្រព្យសម្បត្តិដោយតុលាការ គឺធ្វើឡើងដោយសារប្តីប្រពន្ធមិនអាចពិភាក្សាគ្នាបាន ឬពិភាក្សាគ្នាក្នុងការបែងចែកទ្រព្យដោយសន្តិវិធីពុំបានជោគជ័យ ដូចនេះតុលាការត្រូវបែងចែកដោយយុត្តិធម៌តាមគោលការណ៍នៃច្បាប់។ ដោយសហព័ទ្ធនីមួយៗត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន និងសិទ្ធិទទួលបាន ១ភាគ២ នៃទ្រព្យសម្បត្តិរួម និងការបែងចែករបស់តុលាការតាមឆន្ទានុសិទ្ធិ ទៅលើករណីពិសេស និងការទាមទាររបស់ប្តីប្រពន្ធណាម្ខាងៗ។[76]

---

[73] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា ៧០។

[74] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៨០, កថាខណ្ឌ១។

[75] សាលក្រមសាលាដំបូងខេត្តកំពង់ស្ពឺ, សំណុំរឿងរដ្ឋប្បវេណី, លេខ ៨៦ " ឆ " ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២។

[76] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៨០, កថាខណ្ឌ ៣ ។

**២.២.១ ទ្រព្យដោយឡែក**

សហព័ទ្ធនីមួយៗត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែកដែលខ្លួនមាន ឬ ទ្រព្យដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់ ដូចជាទ្រព្យសម្បត្តិដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ ក៏ដូចជាទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដែលបានលើកឡើងខាងដើម។[77]

ចំពោះការដែលទទួលបានទ្រព្យសម្បត្តិដោយឡែកនេះ គឺបានចែងតាំងពីក្រមរដ្ឋប្បវេណីឆ្នាំ១៩២០មកម្ល៉េះ ក្រមរដ្ឋប្បវេណីចាស់ និងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ព្រមទាំងក្រមរដ្ឋប្បវេណីបច្ចុប្បន្ន បានបញ្ញត្តប្រហាក់ប្រហែលគ្នាដោយក្រមរដ្ឋប្បវេណីចាស់ និងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ បានកំណត់ពាក់ព័ន្ធនឹងការទទួលបានទ្រព្យដោយឡែកច្បាស់ជាងក្រមរដ្ឋប្បវេណីបច្ចុប្បន្ន ដែលជាករណីពិសេសគឺចំពោះប្រពន្ធមានសិទ្ធិទទួលបានទ្រព្យដោយឡែករបស់ខ្លួន ក្រោយពេលលែងលះ ក៏ប៉ុន្តែករណីដែល ប្តីបានយកទ្រព្យដោយឡែករបស់ប្រពន្ធនោះប្រើប្រាស់អស់ ប្រពន្ធនោះមានសិទ្ធិឱ្យប្តីសងតម្លៃនៃទ្រព្យនោះ បើទ្រព្យរួមមិនអាចសងគ្រាន់ទេ ប្រពន្ធនឹងក្លាយជាម្ចាស់បំណុលរបស់ប្តី។ ក្រមរដ្ឋប្បវេណីចាស់ក៏បានបញ្ញត្តបន្ថែមពាក់ព័ន្ធនឹងប្រពន្ធទី២ ឬ ប្រពន្ធឯទៀត នៅពេលលែងលះក៏ទទួលបានទ្រព្យដោយឡែករបស់ខ្លួនវិញផងដែរ ប្តីនោះត្រូវសងតម្លៃរបស់ទាំងនោះមកវិញ ប្រសិនបើបានយកទ្រព្យរបស់នាងប្រើប្រាស់ តែពុំបានចែងករណីដែលប្តីសងមិនគ្រប់ត្រូវទុកថាប្តីជាកូនបំណុលឡើយ។ ចំពោះក្រមរដ្ឋប្បវេណីបច្ចុប្បន្នមិនបានចែងទាក់ទងនឹងករណីដែលប្តីត្រូវសងទ្រព្យដោយឡែកនោះ ក្នុងករណីដែលបានយកទ្រព្យដោយឡែករបស់ប្រពន្ធចាយវាយអស់នោះទេ។ គួរបញ្ជាក់ផងដែរថានៅពេលមានការលែងលះ ហើយមានការទាមទារក្នុងការបែងចែកទ្រព្យសម្បត្តិ តុលាការនឹងត្រូវធ្វើការចាត់ថ្នាក់ប្រភេទទ្រព្យសម្បត្តិដោយឡែក ឬ ជាទ្រព្យសម្បត្តិរួម ដើម្បីកុំឱ្យមានការសម្រេចខុស។

ក្នុងសំណុំរឿងលែងលះមួយដែលបានដាក់ពាក្យបណ្តឹងលែងលះទៅកាន់តុលាការ ដោយដើមចោទបានទាមទារគ្រប់គ្រងទ្រព្យសម្បត្តិដោយឡែក ពីចុងចម្លើយមានដូចជា ផ្ទះ និងដីដែលបានអះអាងក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ថាលោកជាអ្នកប្រគល់ប្រាក់ឱ្យចុងចម្លើយទិញ និងដាក់ឈ្មោះចុងចម្លើយ ជាម្ចាស់កម្មសិទ្ធិតែម្នាក់ ដើម្បីឱ្យចុងចម្លើយរស់នៅចុះក្នុងសង្គម និងដើម្បីរស់នៅជាមួយគ្នា បន្ទាប់ពីលែងលះដាច់ស្រេច ព្រមទាំងមានបំណងបិទបាំង និងពង្វាងទ្រព្យសម្បត្តិទាំងអស់នោះ ពីប្រពន្ធដើមរបស់ខ្លួនតែប៉ុណ្ណោះ មិនមែនជាប្រទានកម្មឱ្យចុងចម្លើយឡើយ។ ចំណែកឯចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ និងបង្ហាញភស្តុតាង ដែលចុងចម្លើយបានទិញតាំងពីឆ្នាំ២០១៣ មុនពេលដែលចុងចម្លើយរៀបអាពាហ៍ពិពាហ៍

[77] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៧២។

ជាមួយដើមចោទមកម្ដេះ។ ប៉ុន្តែចុងចម្លើយក៏បានទទួលស្គាល់ថាប្រាក់ទាំងនោះជាប្រាក់របស់ដើមចោទពិតប្រាកដមែន តែជាជំនួនមុនពេលរៀបអាពាហ៍ពិពាហ៍ ការដាក់ឈ្មោះតែម្នាក់ឯងទើបប្រពន្ធដើមមិនអាចមករករឿងបាន ព្រោះប្រពន្ធដើមរបស់ដើមចោទ បានដេកនៅសង្កាត់ ដើម្បីបញ្ជាក់ថាមានឈ្មោះដើមចោទដែរ ឬអត់។ ក្រោយពីបានស្ដាប់ការថ្លែងការណ៍របស់ភាគី តុលាការក៏បានចេញសាលក្រមសម្រេចប្រគល់ ដី និងផ្ទះឱ្យទៅចុងចម្លើយ ជាអ្នកគ្រប់គ្រង ដោយសំអាងថាតាមរយៈសេចក្ដីថ្លែងការណ៍របស់ដើមចោទថា ការទិញផ្ទះ និងដីដើម្បីឱ្យចុងចម្លើយរស់នៅចុះក្នុងសង្គម និងសម្រួលដល់ការរស់នៅ ដូចនេះតុលាការយល់ឃើញថា ដើមចោទឱ្យប្រាក់ទៅចុងចម្លើយ ដោយមានបំណងទិញផ្ទះ និងដីដែលជាកម្មវត្ថុនេះ ដើម្បីឱ្យចុងចម្លើយរស់នៅចុះក្នុងសង្គម និងទុកជាកម្មសិទ្ធិរបស់ចុងចម្លើយតែម្នាក់ឯង។ [78]

តាមរយៈសំណុំរឿងនេះ បានបញ្ជាក់ឱ្យឃើញថាការកំណត់ទ្រព្យដោយឡែកនេះពិតជាសំខាន់ បើពុំដូច្នេះទេ ការសម្រេចរបស់តុលាការនឹងមានភាពអយុត្តិធម៌ ព្រមទាំងបាត់បង់ផលប្រយោជន៍ភាគីម្ខាងទៀត។

### ២.២.២ ទ្រព្យរួម

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយដែលប្ដីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបានអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលបានកំណត់ថាជាទ្រព្យដោយឡែក។[79] ចំពោះទ្រព្យរួមនេះពុំមានអានុភាពក្នុងករណីអនីតិសង្វាសទេ ដោយហេតុថាគ្មានអាពាហ៍ពិពាហ៍ គឺគ្មានរបបមាតិកភណ្ឌ មានន័យថាគ្មានប្រព័ន្ធទ្រព្យសម្បត្តិរួមប្ដីប្រពន្ធ និងគ្មានប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាឡើយ ដែលកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ មិនអាចតាក់តែង និងចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ដែលច្បាប់ទទួលស្គាល់ដែលមានខ្លឹមសារកំណត់អំពីទ្រព្យសម្បត្តិរួម និងទ្រព្យដោយឡែកឱ្យមានភាពច្បាស់លាស់ស្របទៅតាមឆន្ទៈរបស់ប្ដីប្រពន្ធឡើយ។[80] វិធានស្ដីពីទ្រព្យសម្បត្តិរួម មានមូលដ្ឋានលើគំនិតដែល ថាអាពាហ៍ពិពាហ៍ជាការរួមដៃគ្នាទាំងប្ដីទាំងប្រពន្ធត្រូវធ្វើវិភាគទានស្មើគ្នា ដូច្នេះនៅពេលលែងលះប្រពន្ធមានសិទ្ធិទទួលបានចំណែកនៃទ្រព្យសម្បត្តិរួមស្មើនឹងចំណែករបស់ប្ដី។ ចំពោះក្រមរដ្ឋប្បវេណីចាស់ការបែងចែកទ្រព្យរួមមានតែប្រពន្ធទី១ទេ ដែលមានសិទ្ធិទទួលបានចំណែកពាក់កណ្ដាលនៃទ្រព្យ ដែលរកបានជាមួយគ្នាក្នុងពេលដែលនៅមូលគ្នាគឺទ្រព្យដែលរកបានដោយសារធ្វើការងារ និងគ្រប់គ្រងទ្រព្យសម្បត្តិក្នុងគ្រួសារ ឬ រកបានដោយសារបណ្ដាក់ទុនយកការ យកផលទុនដែលជាទុនរបស់ប្ដី ឬ របស់ប្រពន្ធ។[81] ប៉ុន្តែចំពោះក្រមរដ្ឋប្បវេណីបច្ចុប្បន្ន ព្រមទាំងច្បាប់ស្ដីពី

---

[78] សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ២៧១២ “ ធ ”, ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧ ។

[79] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៧៣។

[80] អត្ថបទផលវិបាកនៃការមិនចុះបញ្ជីអាពាហ៍ពិពាហ៍ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១ របស់មន្ទីរសារការី អេស ខេ វ៉ាយ។

[81] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ២៥២។

អាពាហ៍ពិពាហ៍ និងគ្រួសារ គឺបានកំណត់ឱ្យសហព័ទ្ធត្រូវទទួលបានទ្រព្យសម្បត្តិរួមម្នាក់ពាក់កណ្តាលដោយយុត្តិធម៌ លើកឡើងតែករណីចាំបាច់ ឬ មានការទាមទារពីភាគីណាមួយ។

ផ្អែកតាមស្ថានភាពជាក់ស្តែងមួយ ក្នុងការរួមរស់នៅជាមួយគ្នាជាគូស្វាមី ដើមចោទបានផ្ញើប្រាក់ចំនួន USD ៧,២០០ ឱ្យម្តាយក្មេក តាមការស្នើសុំរបស់ចុងចម្លើយ ហើយនៅឆ្នាំ២០១៧ ពួកគាត់ទាំងពីរទទួលបានកូនប្រុសម្នាក់ និងមានទ្រព្យសម្បត្តិរួមជាប្រាក់ចំនួន USD ៤៦,៣៦០។ ដោយសារការមិនពេញចិត្តរបស់គ្រួសារដើមចោទ បានធ្វើឱ្យប៉ះពាល់ដល់ទំនាក់ទំនងប្តីប្រពន្ធ ក៏បានធ្វើឱ្យចំណងអាពាហ៍ពិពាហ៍នោះឈានដល់ការលែងលះ ដូច្នេះដើមចោទបានដាក់ពាក្យបណ្តឹងលែងលះ ដោយសុំប្រគល់ប្រាក់ដែលជាទ្រព្យសម្បត្តិរួមចំនួន USD ១៥,៩៨០ ដោយកាត់កងជាមួយនឹងប្រាក់ចំនួន USD ៧,២០០ ដែលដើមចោទបានផ្ញើឱ្យម្តាយក្មេក ថែមទាំងសុំសិទ្ធិអំណាចមេបាលើកូនដោយពុំទាមទារប្រាក់អាហារកាតព្វកិច្ចឡើយ។ ក៏ប៉ុន្តែតុលាការបានសម្រេចបែងចែកទ្រព្យរួមដែលជាប្រាក់ចំនួន USD ៤៦,៣៦០ ប្រគល់ឱ្យម្នាក់ USD ២៣,១៨០ ដោយច្រានចោលនូវការទាមទាររបស់ដើមចោទ ក្នុងការប្រគល់ឱ្យចុងចម្លើយតែចំនួន USD ១៥,៩៨០ ដោយផ្អែកតាមមាត្រា ៩៧៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់ឱ្យប្តីប្រពន្ធមានសិទ្ធិប្រើប្រាស់ និងគ្រប់គ្រងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធបាន។ ដូចនេះការចាត់ចែងប្រាក់ចំនួន USD ៧,២០០ មិនមែនជាការចាត់ចែង ដែលខុសច្បាប់ និងអាចជាហេតុដែលនាំឱ្យមានការទាមទារត្រឡប់បានឡើយ។[82]

គួរបញ្ជាក់ផងដែរថាទ្រព្យរួមមិនសំដៅតែលើទ្រព្យដែលរកបានមកពីខាងក្រៅតែប៉ុណ្ណោះទេ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងក្រមរដ្ឋប្បវេណីបច្ចុប្បន្នបានចាត់ទុក *ការងារនៃគេហកិច្ចត្រូវចាត់ថាមានតម្លៃស្មើនឹងការងារក្រៅផ្ទះដែរ* បើទោះបីជាប្រពន្ធនោះជាស្ត្រីមេផ្ទះ ក៏ត្រូវតែទទួលបានចំណែកស្មើនឹងប្តីដែរ ។

យោងតាមស្មារតីនៃច្បាប់នេះ ក្នុងសំណុំរឿងលែងលះមួយដែលដើមចោទបានប្តឹងទាមទារបែងចែកទ្រព្យរួម ដែលមានដូចជារថយន្តមួយគ្រឿង និងមាសមួយតំឡឹង ព្រមទាំងទ្រព្យសម្បត្តិផ្ទាល់ខ្លួនគឺដីធ្លីមួយកន្លែងដែលដើមចោទបានអះអាងថាបានគ្រប់គ្រងតាំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៦ ជាមួយអតីតភរិយារបស់ដើមចោទដែលបានទទួលមរណៈនៅឆ្នាំ ១៩៨៦។ ក្រោយប្រពន្ធមុនរបស់ដើមចោទបានទទួលមរណៈ ដើមចោទបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយនៅក្នុងឆ្នាំ១៩៩៥ និងបានចុះសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍នៅក្នុងឆ្នាំ ២០០៥ ដើម្បីដាក់ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីមួយកន្លែង ចាប់តាំងពីចុងចម្លើយបានរួមរស់ជាមួយដើមចោទ ចុងចម្លើយបានជួយបង្កបង្កើនផលលើដីនោះផងដែរ។ ចុងចម្លើយបានស្នើសុំបែងចែកទាំងផ្ទះ និងដីដែលដើមចោទអះអាងថាជាទ្រព្យផ្ទាល់ខ្លួនផងដែរ ដោយយកពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីមកសំអាងថាផ្ទះនោះក៏ជាទ្រព្យរួម ហើយបានលើកឡើងថាខ្លួនបានចំណាយកម្លាំងកាយចិត្តក្នុងការជួយមើលថែផ្ទះ

[82] សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ៩០៩, ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨។

នោះក្នុងនាមជាម្ចាស់ផ្ទះ។ ក្រោយពីវិនិច្ឆ័យតុលាការបានសម្រេចប្រគល់ផ្ទះដីនោះឱ្យដើមចោទ ដោយសំអាងថាដើមចោទមានផ្ទះនោះ មុនពេលរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយ ដូចនេះតុលាការយល់ឃើញថា ដីនិងផ្ទះនោះជាទ្រព្យផ្ទាល់របស់ដើមចោទ។ រីឯរថយន្ត និងមាសមួយតំឡឹង ប្រគល់ឱ្យចុងចម្លើយ ជាថ្នូរសម្រាប់ការងារដែលចុងចម្លើយបានធ្វើនៅលើផ្ទះដែលជាទ្រព្យសម្បត្តិផ្ទាល់របស់ដើមចោទ។[83]

ចំពោះករណីនេះ ដើមចោទបានប្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងការប្រគល់ទ្រព្យរួមទៅឱ្យចុងចម្លើយ តែត្រូវបានតុលាការធ្វើការច្រានចោលបណ្តឹងឧទ្ធរណ៍របស់ដើមចោទ និងតម្កល់សាលាក្រមរបស់សាលាដំបូងទុកជាបានការ។ ក្នុងន័យនេះបានបញ្ជាក់ឱ្យឃើញថា បើទោះបីជាការងារផ្ទះក៏ត្រូវទទួលបានទ្រព្យរួមយ៉ាងសមរម្យសម្រាប់ការចំណាយកម្លាំងកាយចិត្តក្នុងការមើលថែការងារក្នុងផ្ទះនោះដែរ។

## ៣. ការបែងចែកកាតព្វកិច្ចក្រោយពេលលែងលះ

ក្នុងករណីដែលមានបំណុល ការបែងចែកកាតព្វកិច្ចក្រោយពេលលែងលះនឹងត្រូវចាប់ផ្តើមនីតិវិធីក្នុងការវិភាគ វិនិច្ឆ័យ កំណត់សម្គាល់ប្រភេទនៃបំណុលជាដើម ដែលការបែងចែកនេះ មិនខុសពីការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះប៉ុន្មានឡើយ ដោយបែងចែកជាពីររបៀប គឺការបែងចែកតាមការព្រមព្រៀងរបស់ភាគី និងការបែងចែកតាមរយៈសាលក្រមរបស់តុលាការ។

### ៣.១ ការបែងចែកតាមការព្រមព្រៀងរបស់ភាគី

ចំពោះការបែងចែកបំណុលតាមការព្រមព្រៀងរបស់ភាគី ភាគច្រើនកើតមានឡើងក្នុងករណីដែលការលែងលះនោះជាការលែងលះដោយមានការព្រមព្រៀង ភាគីអាចធ្វើការបែងចែកដោយចុះកិច្ចសន្យាព្រមព្រៀងគ្នាកំណត់កាតព្វកិច្ចបំណុលរបស់ភាគីដោយគ្មានការបង្ខិតបង្ខំ ការចុះកិច្ចព្រមព្រៀងនេះភាគច្រើន ភាគីតែងធ្វើមុនពេលដាក់ពាក្យស្នើសុំលែងលះទៅកាន់តុលាការ ដើម្បីជួយសម្រួលដល់ការសម្រេចសេចក្តីរបស់តុលាការ និងជម្រុញដល់នីតិវិធីឱ្យបញ្ចប់បានលឿន។ ប៉ុន្តែក្នុងករណីការលែងលះដោយពុំមានការព្រមព្រៀង ក៏មានករណីដែលមានការបែកចែងដោយមានការព្រមព្រៀងផងដែរ ដោយហេតុថានៅពេលដែលដាក់ពាក្យបណ្តឹងលែងលះទៅកាន់តុលាការជាការទាមទារ ក្រោយពីមានការផ្សះផ្សារបស់តុលាការ គូភាគីក៏បានប្តូរចិត្តពីការទាមទារ មកជាការព្រមព្រៀងវិញ ឬ ក្នុងករណីខ្លះទៀតគូភាគីជ្រើសរើស ការបែងចែកក្រៅប្រព័ន្ធតុលាការដោយពុំបានទាមទារឱ្យតុលាការសម្រេចក្នុងពាក្យបណ្តឹងឡើយ។

ជាក់ស្តែងក្នុងករណី ដែលគូភាគីបានដាក់ពាក្យបណ្តឹងលែងលះ ដោយក្នុងពាក្យបណ្តឹងដើមចោទបានទាមទារឱ្យតុលាការសម្រេចតែការសុំលែងលះពីប្តី ការសុំសិទ្ធិមានអំណាចមេបាលើកូន សុំសិទ្ធិគ្រប់គ្រងកាន់កាប់ប្រើប្រាស់ចាត់ចែង និងអាស្រ័យផលលើទ្រព្យសម្បត្តិរួមតែប៉ុណ្ណោះ ពុំមានការទាមទារតុលាការ

[83] សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ៤៣ “ ញ ”, ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ ។

សម្រេចលើបំណុលឡើយ។ ដោយសារក្នុងសំណុំរឿងលែងលះតុលាការមានសិទ្ធិសម្រេច តាមការទាមទាររបស់ភាគីប៉ុណ្ណោះ។ ក្រោយតុលាការបានចេញសាលក្រមលែងលះនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ ទើបគូភាគីចុះកិច្ចព្រមព្រៀងបែងចែកបំណុលនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៨។[84]

### ៣.២ ការចាត់ប្រភេទបំណុល

តុលាការនឹងធ្វើការចាត់ប្រភេទបំណុល នៅពេលដែលភាគីទាមទារលែងលះ ដោយសម្គាល់បំណុលជាមុនសិន ដើម្បីបង្កភាពងាយស្រួលក្នុងការបែងចែងបំណុលឱ្យមានភាពស្មើគ្នា និងសមរម្យតាមច្បាប់ ដោយសម្គាល់ថាបំណុលណាជាបំណុលរួម បំណុលណាជាបំណុលផ្ទាល់ខ្លួន ដោយពិនិត្យទៅលើភស្តុតាង និងការអះអាងរបស់ភាគី និងសាក្សី ថាតើអ្នកណាជាអ្នកជំពាក់បំណុល គោលបំណងនៃការជំពាក់បំណុល ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ផលប្រយោជន៍រួម តើបំណុលនោះជំពាក់តាំងពេលណា ដោយផ្ទៀងផ្ទាត់ជាមួយនឹងភស្តុតាងជាដើម។

#### ៣.២.១ បំណុលផ្ទាល់ខ្លួន

បំណុលផ្ទាល់ខ្លួន គឺជាបំណុលដែលសហព័ទ្ធម្នាក់បានជំពាក់មុនពេលរៀបអាពាហ៍ពិពាហ៍ រឺក៏ជាបំណុលដែលកើតក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ ដោយសហព័ទ្ធម្ខាងបានជំពាក់គេតែម្នាក់ឯងការខ្ចីបំណុលដើម្បីបំពេញនូវតម្រូវការផ្ទាល់ខ្លួន និងពុំបានឱ្យសហព័ទ្ធម្ខាងទៀតដឹងឮ បំណុលនោះមិនពាក់ព័ន្ធដល់ការទទួលខុសត្រូវរបស់សហព័ទ្ធម្ខាងទៀតទេ។ ករណីបំណុលផ្ទាល់ខ្លួននេះដែរ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ព្រមទាំងក្រមរដ្ឋប្បវេណី១៩២០ ពុំបានបញ្ញត្តឡើយ។

#### ៣.២.២ បំណុលរួម

ចំពោះការបែងចែកកាតព្វកិច្ចបំណុលក្រោយពេលលែងលះក្នុងករណីដែលជាបំណុលរួម ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក៏ដូចជាក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ព្រមទាំងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ពុំបានចែងយ៉ាងជាក់ច្បាស់ឡើយ ក៏ប៉ុន្តែដោយផ្អែកតាមស្មារតីសហព័ទ្ធម្នាក់ៗ មានសិទ្ធិត្រូវបានទ្រព្យរួមពាក់កណ្តាលម្នាក់ ដែលជាគោលការណ៍នៃការបែងចែកទ្រព្យសម្បត្តិរួម ដូចនេះតុលាការនឹងបែងចែកបំណុលរួមឱ្យសហព័ទ្ធទទួលកាតព្វកិច្ចម្នាក់ពាក់កណ្តាល។

ជាក់ស្តែងក្នុងករណីលែងលះមួយ ដែលដើមចោទបានទាមទារត្រឹមតែការបែងចែកទ្រព្យសម្បត្តិរួម ហើយព្យាយាមបដិសេធពាក់ព័ន្ធនឹងបំណុល ដែលបានខ្ចីគេយកមកព្យាបាលចុងចម្លើយក្នុងគោលបំណងឱ្យចុងចម្លើយចេញសងម្នាក់ឯង ដោយសារនោះជាថ្លៃព្យាបាលចុងចម្លើយ។ ប៉ុន្តែតុលាការបានសម្រេចថា បំណុល

[84] សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ១៦, ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨។

នៃការព្យាបាលជម្ងឺចុងចម្លើយ រួមគ្នាសងពាក់កណ្តាលម្នាក់ ដោយផ្អែកតាមមាត្រា៧០ ចំណុចពិសេសនៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។[85]

ក្នុងករណីខ្លះទៀតបំណុលរួមត្រូវប្តូរទៅជាបំណុលផ្ទាល់ខ្លួន មានន័យថា ប្រសិនបើមានការពិភាក្សាព្រមព្រៀងគ្នារបស់ភាគីទាំងសងខាង បំណុលរួមត្រូវបានភាគីម្ខាងណាព្រមទទួលបន្ទុកតែម្នាក់ឯងតាមលក្ខខណ្ឌពិសេស ដូចជាភាគីដែលត្រូវទទួលបន្ទុកលើបំណុលរួមតែម្នាក់ឯង នឹងទទួលបាននូវទ្រព្យសម្បត្តិរួមច្រើនជាងភាគីម្ខាងទៀត។ ករណីទាំងអស់អាចធ្វើទៅបានតាមការព្រមព្រៀងគ្នា ឬ តាមការទាមទារឱ្យតុលាការសម្រេចជាដើម។

ក្នុងសាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូងខេត្តត្បូងឃ្មុំ ត្រង់ចំណុចកម្មវត្ថុនៃបណ្តឹងត្រង់ចំណុចទី៣ដើមចោទបានប្តឹងសុំឱ្យតុលាការចេញសាលក្រម សុំបែងចែកទ្រព្យសម្បត្តិរួម និងបំណុលជាពីរចំណែកស្មើគ្នាក៏ប៉ុន្តែនៅពេលឈានដល់ការទាញហេតុផលដោយផ្ទាល់មាត់ចុងក្រោយ ភាគីខាងចុងចម្លើយបានថ្លែងការណ៍ថា ចំពោះរូបមន្តនៃការបែងចែកទ្រព្យសម្បត្តិរួម ខ្លួនសុំឱ្យដើមចោទទូទាត់ប្រាក់ឱ្យខ្លួនចំនួន ២០០.០០០ (ម្ភៃម៉ឺន) ដុល្លាអាមេរិក ដោយឱ្យដើមចោទទទួលបានទ្រព្យសម្បត្តិរួមទាំងអស់ និងត្រូវទទួលសងបំណុលដែលជំពាក់ធនាគារផងដែរ។ ដើមចោទក៏បានថ្លែងការណ៍ថា ចំពោះការបែងចែកទ្រព្យសម្បត្តិរួម ខ្លួនសុខចិត្តទទួលយកទ្រព្យសម្បត្តិទាំងអស់ និងសងបំណុលដែលជំពាក់ធនាគារតែម្នាក់ឯង និងយល់ព្រមប្រគល់ប្រាក់ឱ្យចុងចម្លើយចំនួន ២០០.០០០ (ម្ភៃម៉ឺន) ដុល្លាអាមេរិកសម្រាប់ការបែងចែកទ្រព្យសម្បត្តិរួម។[86]

### ៤. នាមត្រកូលសហព័ន្ធ

ចំពោះការប្តូរនាមត្រកូលក្រោយពេលលែងលះ ករណីនេះទើបតែមានការចែងក្នុងក្រមរដ្ឋប្បវេណីបច្ចុប្បន្នតែប៉ុណ្ណោះ ដែលបានបញ្ញត្តថាបើប្តីប្រពន្ធបានប្តូរនាមត្រកូលថ្មីទៅតាមប្តី ឬ ប្រពន្ធក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ក្រោយពេលលែងលះគ្នា អាចប្តូរយកនាមត្រកូលដើម ដែលធ្លាប់បានប្រើប្រាស់នៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន ឬ សម្រេចយកត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន។[87] តាមសង្គមជាក់ស្តែង ស្ត្រីមួយចំនួនបានបន្ថែមនាមត្រកូលរបស់ស្វាមីខ្លួននៅពីក្រោយនាមត្រកូលរបស់ខ្លួន ដូចនេះប្រសិនបើចង់ប្តូរភាគីអាចបញ្ជាក់ការទាមទារក្នុងពាក្យបណ្តឹងលែងលះបាន។ ចំពោះការប្តូរនាមត្រកូលតាមប្តី ឬ ប្រពន្ធ នៅពេលមានចំណងអាពាហ៍ពិពាហ៍នេះ គឺបានទទួលឥទ្ធិពលពីបរទេស ដោយក្នុងប្រទេសកម្ពុជាពុំសូវមានករណីប្តូរនាមត្រកូលតាមប្តី ឬ ប្រពន្ធនៅពេលមានចំណងអាពាហ៍ពិពាហ៍ឡើយ។

[85] សាលក្រមចំពោះមុខភាគី, លេខ ២២ (ក), ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តតាកែវ។
[86] សាលក្រមសាលាដំបូងខេត្តត្បូងឃ្មុំ, សំណុំរឿងរដ្ឋប្បវេណី, ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ។
[87] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៨១។

## ៥. អំណាចមេបា

នៅអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ ឪពុកម្តាយត្រូវរួមគ្នាក្នុងការទទួលខុសត្រូវចំពោះកូនរបស់ខ្លួន លុះដល់ពេលលែងលះឪពុកម្តាយត្រូវតែចែកគ្នាក្នុងការទទួលខុសត្រូវទាំងអស់ ដែលច្បាប់ហៅអំណាចមេបា។ អំណាចមេបា សំដៅលើអ្នកដែលមានអំណាចមេបាមានសិទ្ធិ និងករណីយកិច្ចត្រូវបីបាច់រក្សារូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។[88]

### ៥.១ ការបែងចែកអំណាចមេបា

ការកំណត់អំណាចមេបាត្រូវកំណត់តាមការពិភាក្សាព្រមព្រៀងរបស់ឪពុកម្តាយ បើការពិភាក្សារបស់ឪពុកម្តាយមិនបានសម្រេច តុលាការត្រូវកំណត់អ្នកមានអំណាចមេបាដោយពិចារណាលើផលប្រយោជន៍កូនជាធំ។ ផ្ទុយទៅវិញបើឪពុកម្តាយបានលែងលះគ្នាមុនកំណើតរបស់កូន នោះម្តាយជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតនោះ។ ហើយឪពុកម្តាយអាចធ្វើការពិភាក្សាគ្នា ប្រសិនបើគាត់ធ្វើការលែងលះក្រោយកំណើតរបស់កូន ដោយកំណត់យកឪពុកជាអ្នកមានអំណាចមេបា។[89] ចំពោះច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារវិញមិនបានកំណត់អំពីការលែងលះគ្នាមុនកំណើតកូននោះទេ។ បើក្រឡេកទៅមើលក្រមរដ្ឋប្បវេណីចាស់វិញ ត្រង់ចំណុចនេះផងដែរក៏មិនត្រូវបានគេលើកយកមកបញ្ញត្តិដូចគ្នាផងដែរ ដោយគ្រាន់តែលើកអំពីការប្រាស្រ័យទាក់ទង ឬ សាហ៊ុយអប់រំកូននៅពេលលែងលះតែប៉ុណ្ណោះ។

#### ៥.១.១ ការបែងចែកអំណាចមេបាដោយការព្រមព្រៀង

ការបែងចែកអំណាចមេបាដោយការព្រមព្រៀងនេះពុំមានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ពោលគឺតម្រូវឱ្យសាលក្រមដែលកាត់ឱ្យប្តីប្រពន្ធដាច់នោះត្រូវសម្រេចអំពីអំណាចមេបាដែលត្រូវប្រគល់ទៅឱ្យឪពុក ឬឱ្យទៅម្តាយ ហើយនឹងត្រូវសម្រេចអំពីការប្រាស្រ័យទាក់ទងរវាងឪពុកម្តាយ និងកូននោះ។[90] ប៉ុន្តែច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានបញ្ញត្តថា ដើម្បីផលប្រយោជន៍របស់កូន ការឱ្យភាគីណាមួយរក្សាកូន ត្រូវសម្រេចតាមការយល់ព្រមនៃប្តីប្រពន្ធដែលលែងលះគ្នានោះ។ តាមគោលការណ៍ កូនដែលនៅបៅដោះត្រូវបានទៅម្តាយរក្សា។[91] ចំណែកឯក្រមរដ្ឋប្បវេណីបច្ចុប្បន្នក៏បានចែកមិនខុសពីច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារឡើយ។ ដោយបានបញ្ញត្តថា បើឪពុកម្តាយលែងលះគ្នា ត្រូវកំណត់យកឪពុក ឬ ម្តាយណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ។[92] ការពិភាក្សាអាចជាការព្រមព្រៀង ឬ ការសម្រេចផ្តល់សិទ្ធិ

[88] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា១០៣៤។

[89] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា១០៣៧ កថាខណ្ឌទី១។

[90] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ២៤៦។

[91] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា ៧៣។

[92] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា១០៣៧ កថាខណ្ឌទី១។

ពីភាគីណាមួយ។ មានន័យថាភាគីបានព្រមព្រៀងគ្នាក្នុងការសម្រេចអំណាចមេបា តាមកិច្ចព្រមព្រៀងលែងលះ ឬ ភាគីបានឯកភាពតាមការទាមទាររបស់អ្នកដាក់ពាក្យសុំ។

ជាក់ស្តែកករណីដែលលែងលះដោយការព្រមព្រៀង ភាគីបានចុះកិច្ចព្រមព្រៀងលែងលះមុនពេលដាក់ពាក្យសុំទៅកាន់តុលាការ ក្នុងកិច្ចព្រមព្រៀងលែងលះនោះភាគីក៏បានកំណត់អ្នកមានអំណាចមេបា ដោយអ្នកដាក់ពាក្យសុំផ្តល់សិទ្ធិអំណាចមេបាដល់ភាគីម្ខាងទៀត។ ក្នុងសំអាងហេតុ តុលាការយល់ឃើញថាការព្រមព្រៀងនោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ហេតុដូច្នេះតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី ស្របតាមមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី។ ចំពោះសេចក្តីសម្រេចបញ្ចប់របស់តុលាការវិញ ក៏បានកំណត់តាមការទាមទារផងដែរ។[93]

ប៉ុន្តែក៏មានករណីខ្លះទៀតដែលការលែងលះនោះពុំមែនជាការព្រមព្រៀង ក្រោយពីមានការពិភាក្សាភាគីបានឯកភាពតាមការទាមទារ។ ជាក់ស្តែងក្នុងពាក្យបណ្តឹងលែងលះមួយ ភាគីដើមចោទបានធ្វើការទាមទារសុំសិទ្ធិអំណាចមេបាលើកូនប្រុសស្រី។ ក្រោយមានការពិភាក្សាភាគីចុងចម្លើយបានឯកភាពលើការសុំទាមទារ ដោយសុខចិត្តប្រគល់សិទ្ធិអំណាចមេបាឱ្យទៅដើមចោទ។ តុលាការបានអះអាងថា ការព្រមព្រៀងដែលចុងចម្លើយបានឯកភាព និងយល់ព្រមមានលក្ខណៈសមស្របតាមមាត្រា ១០៣៧ ចំណុចទី ១ នៃក្រមរដ្ឋប្បវេណី។ ដូចនេះតុលាការបានសម្រេចកំណត់ឱ្យដើមចោទជាអ្នកមានអំណាចមេបាលើកូនប្រុសស្រី។[94]

### ៥.១.២ ការបែងចែកអំណាចមេបាដោយតុលាការ

ប្រសិនបើករណីពុំអាចសម្រេច ឬ ពុំអាចពិភាក្សាបានទេ ច្បាប់បានធ្វើការផ្តល់អំណាចឆន្ទានុសិទ្ធិទៅតុលាការដើម្បីកំណត់អ្នកមានអំណាចមេបាក្នុងការអប់រំថែរក្សា ដោយគិតដល់ផលប្រយោជន៍របស់កូន មានន័យថា បើតុលាការស៊ើបអង្កេតឃើញថាសហព័ទ្ធម្ខាងមានជីវភាពធូរធារ ដែលមានលទ្ធភាពក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនបានល្អដោយមិនឱ្យខូចប្រយោជន៍របស់កូន នោះតុលាការមានឆន្ទានុសិទ្ធិក្នុងការប្រគល់កូនឱ្យសហព័ទ្ធនោះជាអ្នកថែរក្សា។[95] បើយោងតាមក្រមរដ្ឋប្បវេណីថ្មី បានលើកឡើងថា ស្ត្រីដែលបានសម្រាលកូនគឺជាម្តាយរបស់កូន។[96] យ៉ាងណាមិញច្បាប់អាពាហ៍ពិពាហ៍ នឹងគ្រួសារវិញ សម្រាប់ការបញ្ញត្តិមានលក្ខណៈប្រហាក់ប្រហែលនឹងក្រមថ្មី ដែលជាគោលការណ៍កូនដែលនៅបៅដោះនៅពេលដែលឪពុកម្តាយលែងលះគ្នាត្រូវបានទៅខាងម្តាយដែលជាអ្នកថែរក្សា ពីព្រោះថាម្តាយជាអ្នកមានទឹកដោះដើម្បីចិញ្ចឹមកូន និងមានភាព

[93] ដីកាសម្រេចសាលាដំបូងខេត្តបន្ទាយមានជ័យ, លេខ ៥៥០ ពស.មប “ ញ ”/២២, ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២ ។

[94] សាលក្រមសាលាដំបូងរាជធានីភ្នំពេញម, លេខ ៥៣ “ ង១ ” ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣។

[95] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា១០៣៧ កថាខណ្ឌទី៣។

[96] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ៩៨៧។

ស្ទាត់ជំនាញខាងថែរក្សាទារកជាងបុរសដែលជាឪពុក។[97] ចំពោះកូនដែលលែងបៅដោះក៏មិនអាចកំណត់បានថា បានទៅខាងឪពុកជាអ្នកគ្រប់គ្រងដែរ វាជាឆន្ទានុសិទ្ធិរបស់តុលាការជាអ្នកដែលសម្រេចលើបញ្ហានេះ។ ចំពោះក្រមរដ្ឋប្បវេណីចាស់វិញ មានភាពខុសស្រឡះទាំងស្រុងពីច្បាប់ទាំងពីរខាងលើ ដោយក្រមចាស់បានលើកឡើងថា បើឪពុក និងម្ដាយមិនស្រុះស្រួលគ្នាក្នុងការទទួលបីបាច់ថែរក្សាកូនទេ ចៅក្រមត្រូវឱ្យម្ដាយរក្សាកូនតូចៗ ដែលមានអាយុមិនដល់៥ឆ្នាំប្រសិនបើគ្មានហេតុអ្វីមកជំទាស់ទេ។ លុះដល់កូននោះមានអាយុលើសពី៥ឆ្នាំ កូនស្រីត្រូវនៅជាមួយម្ដាយ និងកូនប្រុសត្រូវនៅជាមួយឪពុក។[98] ដោយឡែកចំពោះកូនដែលទើបនឹងធំដឹងក្ដី(អាយុ១៦)ឆ្នាំនៅពេលដែលឪពុកម្ដាយលែងលះគ្នា តុលាការអាចសួរទៅកូននោះថា តើចង់ទៅរស់នៅជាមួយឪពុក ឬ ម្ដាយ ហើយតុលាការមានសិទ្ធិសម្រេចតាមការសម្រេចចិត្តរបស់កូន។[99] ញាតិនៅក្នុងថ្នាក់ទី៤របស់កូនសហព័ទ្ធអាចធ្វើការទាមទារតុលាការឱ្យមានការផ្លាស់ប្ដូរអំណាចមេបាបាន ប្រសិនបើតុលាការទទួលស្គាល់ថាជាការចាំបាច់ដើម្បីផលប្រយោជន៍កូន។

ទោះបីជាចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធទាំងពីរបានកាត់ផ្ដាច់មែន ក៏ប៉ុន្តែចំណងឪពុកម្ដាយជាមួយកូន មិនអាចកាត់ផ្ដាច់បានឡើយ។ សហព័ទ្ធដែលមើលថែរក្សាកូនត្រូវតែផ្ដល់លទ្ធភាពឱ្យទៅភាគីម្ខាងទៀតបានមកសួរសុខទុកកូនគ្រប់ពេលវេលាដោយមិនធ្វើឱ្យមានភាពស្មុគស្មាញ ឬរារាំងដល់សហព័ទ្ធម្ខាងទៀតមិនឱ្យប្រាស្រ័យទាក់ទងជាមួយកូនឡើយ និងមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។[100] បើសិនជាការចូលជួបកូនមិនបានសម្រេច តុលាការត្រូវកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទង និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីថែរក្សាកូនតាមការទាមទាររបស់ឪពុកម្ដាយ។[101] យោងតាមសេចក្ដីសម្រេចរបស់តុលាការ កូនដែលមានអាយុក្រោម៦ឆ្នាំច្រើនប្រគល់ឱ្យទៅរស់នៅខាងម្ដាយ។

ដោយឆ្លងកាត់តាមការសិក្សាអំពីសំណុំរឿង ក៏ដូចជាសាលក្រមជាច្រើនមក ការបែងចែកអំណាចមេបាភាគច្រើនបានទៅលើម្ដាយ។ ដោយសារតែគេជឿថាកូនមានទំនាក់ទំនងល្អជាមួយម្ដាយជាងឪពុក ម្ដាយអាចយល់ពីកូនច្រើនជាងឪពុក ព្រោះកូនភាគច្រើនមានភាពស្និតស្នាលជាមួយម្ដាយ។ មួយវិញទៀត ទោះបីឪពុកមានការងារធ្វើមានប្រាក់ចំណូលខ្ពស់ តែចំពោះការមើលថែកូនគឺនៅមិនទាន់បានល្អដូចការដែលម្ដាយមើលថែកូនឡើយ។ ការបែងចែកអំណាចមេបាលើកូននេះផងដែរ ត្រូវសិក្សាអំពីផលប្រយោជន៍របស់កូនជាធំ។

[97] ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រាមាត្រា ៧៣។
[98] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ២៤៨។
[99] ក្រមរដ្ឋប្បវេណីចាស់, ២៥ កុម្ភៈ ១៩២០, មាត្រា ២៤៩។
[100] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ១០៤០ កថាខណ្ឌទី ១។
[101] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ១០៤០ កថាខណ្ឌទី ៤។

ក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍គូភាគីមានកូនចំនួន០៣នាក់។ ហើយកូនទាំង០៣នាក់នេះ គូភាគីទាមទារសិទ្ធិគ្រប់គ្រងរៀងៗខ្លួន។ ដើមចោទបានអះអាងថា ខ្លួនសុំសិទ្ធិគ្រប់គ្រងជាអំណាចមេបាដោយសារកូនរស់នៅជាមួយខ្លួន ខ្លួនមានមុខរបរច្បាស់លាស់ រីឯចុងចម្លើយគ្មានទំនួលខុសត្រូវ។ ចុងចម្លើយក៏បានសុំសិទ្ធិគ្រប់គ្រប់ជាអំណាចមេបាលើកូនៗផងដែរ ដោយលើកឡើងថាខ្លួនមានសមត្ថភាពអាចមើលថែ និងចិញ្ចឹមកូនបាន។ តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ និងចុងចម្លើយ តុលាការយល់ឃើញថា ការដែលប្រគល់កូនឱ្យទៅដើមចោទ ជាអ្នកមានអំណាចមេបា គឺផ្តល់ផលប្រយោជន៍ដល់កូនច្រើនជាង ដោយផ្អែកលើមូលដ្ឋានដូចជា កូនៗកំពុងរស់នៅជុំគ្នាជាមួយដើមចោទ ហើយការបំបែកកូនៗចេញពីម្តាយមិនមែនជាជម្រើសល្អទេ ព្រោះងាយប៉ះពាល់ដល់មនោសញ្ចេតនា និងអារម្មណ៍របស់ក្មេងដែលមិនគួរបំបែកចេញ ឬ ផ្លាស់ប្តូរស្ថានភាពបច្ចុប្បន្ននេះទេ ដូច្នេះគប្បីកំណត់យកដើមចោទជាអ្នកមានអំណាចមេបាជាករណីសមស្រប។ មួយវិញទៀតផ្អែកតាមស្ថានភាពដើមចោទ មានផ្ទះសម្តែងជាទីលំនៅ និងមានមុខរបរច្បាស់លាស់ អាចរ៉ាប់រងសម្រាប់ការចំណាយក្នុងការថែរក្សាកូន គឺមានភាពល្អប្រសើរ ទាំងការរស់នៅ និងការអប់រំ ដែលអាចផ្តល់ភាពកក់ក្តៅ និងផលប្រយោជន៍ដ៏ទៃទៀតដល់កូន។ លើសពីនេះទៅទៀតបន្ទាប់ពីការលែងលះនេះទៅ ចុងចម្លើយមិនទាន់មានទីលំនៅច្បាស់លាស់ ដែលមិនមានភាពកក់ក្តៅសម្រាប់ការរស់នៅ និងការអប់រំកូនឱ្យបានល្អនោះទេ។ យោងតាមសំអាងហេតុ តុលាការបានសម្រេចកំណត់យកដើមចោទ អ្នកមានអំណាចមេបាលើកូនទាំងបីនាក់ដោយផ្អែលលើផលប្រយោជន៍កូន ស្របតាមមាត្រា១០៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី។[102]

## ៥.២ ការព្យួរ ការដកហូត និងការផ្លាស់ប្តូរអំណាចមេបា

ក្រោយពីមានការសម្រេចសេចក្តីពីតុលាការក្នុងការកំណត់អ្នកដែលមានអំណាចមេបា មិនមែនមានន័យថាអ្នកដែលមានសិទ្ធិអំណាចមេបារួចហើយនោះ អាចអនុវត្តសិទ្ធិរបស់ខ្លួនតាមអំពើចិត្តនោះទេ ប្រសិនបើប្តី ឬ ប្រពន្ធ ឬ អ្នកដែលមានសិទ្ធិស្របច្បាប់ក្នុងការទាមទារសិទ្ធិអំណាចមេបា បានដឹងអំពីការមិនអនុវត្តកាតព្វកិច្ចរបស់អ្នកដែលមានសិទ្ធិអំណាចមេបាឱ្យបានត្រឹមត្រូវទេ គេអាចប្តឹងឱ្យដកហូត ឬ ព្យួរអំណាចមេបាបាន។ ដោយយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពីអ្នកមានអំណាចមេបាមានសិទ្ធិ និងករណីយកិច្ចអប់រំកូន ពោលគឺជំរុញការអភិវឌ្ឍខាងបញ្ញារបស់កូន ផ្តល់ឱ្យកូនទទួលបានចំណេះដឹង និងជំនាញដែលចាំបាច់សម្រាប់ជីវិតនៅក្នុងសង្គមរបស់ខ្លួន។

ការដកហូត ឬ ការប្រកាសព្យួរអំណាចមេបា គឺជាការដកសិទ្ធិទាំងស្រុង ឬ បណ្តោះអាសន្នក្នុងការគ្រប់គ្រងកូនដែលជាអនីតិជន ទៅតាមការស្នើសុំរបស់អ្នកដែលមានសិទ្ធិក្នុងការស្នើសុំ ប្រសិនបើអ្នកដែលមានអំណាចមេបា មិនបានបំពេញកាតព្វកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា។

[102] សាលក្រមសាលាដំបូងខេត្តត្បូងឃ្មុំ, សំណុំរឿងរដ្ឋប្បវេណី, ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ។

បើក្រឡេកមកមើលអំពីការវិវត្តនៃក្រមទាំងបី ចំពោះករណីដែលសិទ្ធិនៃអំណាចមេបាត្រូវបានដកហូត ឬ ព្យួរ ឬ ផ្លាស់ប្តូរសិទ្ធិនេះក្រមរដ្ឋប្បវេណីចាស់ពុំបានបញ្ញត្តឡើយ។ ក្រោយមកទើបមានការបែងអំពីករណីនេះក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដោយបានលើកឡើងថា ការដែលអាចនឹងត្រូវដកហូតអំណាចមេបាហើយប្រគល់ទៅឱ្យអង្គការណាមួយ ឬ ញាតិលោហិតណាមួយចំពោះឪពុក ម្តាយដែលមានកំហុសដូចខាងក្រោម ៖

- ឪពុក-ម្តាយ មានការខ្វះខាតក្នុងការអប់រំ
- ឪពុក-ម្តាយ ប្រើអំណាចដោយរំលោភទៅលើកូនដោយប្រើអុបាយកលផ្សេងៗដើម្បីបង្ខំកូនឱ្យប្រព្រឹត្តបទល្មើស ឬ អំពើណាមួយប៉ះពាល់ដល់សង្គម។
- ឪពុក-ម្តាយ វាយធ្វើបាបកូនឥតត្រាប្រណី
- ឪពុក-ម្តាយ ប្រព្រឹត្តផ្ទុយពីសីលធម៌បណ្តាលឱ្យមានឥទ្ធិពលអាក្រក់ដល់កូន ។[103]

យ៉ាងណាក៏ដោយតុលាការប្រជាជនអាចនឹងសម្រេចដកហូតអំណាចមេបាពីឪពុកម្តាយ ដែលមានកំហុសបានលុះត្រាតែមានពាក្យបណ្តឹងសុំរបស់អង្គការរដ្ឋ អង្គការមហាជន រដ្ឋអាជ្ញាអមតុលាការប្រជាជន រឺ ញាតិលោហិតណាមួយនៃឪពុកនោះ។ [104] ការដកហូតអំណាចមេបាបណ្តាលឱ្យឪពុកម្តាយលែងមានសិទ្ធិដែលខ្លួនធ្លាប់មានពីមុនមកចំពោះកូនរបស់ខ្លួន ប៉ុន្តែនៅមានកាតព្វកិច្ចចិញ្ចឹមកូនតទៅទៀត រហូតដល់កូននោះចូលនីតិភាព។[105]

រីឯក្រមរដ្ឋប្បវេណីថ្មីវិញដែលបានកំណត់ថា ឪពុក ឬ ម្តាយដែលអនុវត្តអំណាចមេបា បានបំពានសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា ឬ បានធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា តុលាការអាចប្រកាសព្យួរ ឬ ដកហូតអំណាចមេបា តាមការទាមទាររបស់ញាតិក្នុង ៤ ថ្នាក់របស់កូន មេឃុំ ចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬតំណាងអយ្យការបាន។[106] ប្រសិនបើមានការប្រកាសព្យួរ ឬ ការដកហូតអំណាចមេបា ហើយកូនធ្លាក់ទៅក្នុងស្ថានភាពដែលពុំមានអ្នកមានអំណាចមេបា ដោយអ្នកនោះត្រូវបានប្រកាសការព្យួរ ឬ ការដកហូតអំណាចមេបា ឬ បានលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា តុលាការអាចយកឪពុក ឬ ម្តាយដែលពុំមានអំណាចមេបាមកធ្វើជាអ្នកមានអំណាចមេបារបស់កូនបាន។ មួយវិញទៀតក្នុងករណីប្រសិនបើអ្នកដែលមានអំណាចមេបាទទួលមរណភាព ដូច្នេះ

[103] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា ១១៩។
[104] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា ១២០។
[105] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា ១២១។
[106] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ១០៤៨។

ចំណុចខាងលើក៏ត្រូវបានយកមកអនុវត្តផងដែរ។[107] ក្រោយពីការប្រកាសព្យួរ ឬ ការដកហូតអំណាចមេបា ត្រូវបានបញ្ចប់ តុលាការអាចលុបចោលការប្រកាសព្យួរ ឬ ការដកហូតសិទ្ធិក្នុងនាមជាអ្នកមានអំណាចមេបា តាមការទាមទាររបស់សាមីជនដែលទទួលបានការប្រកាសព្យួរ ឬ ការដកហូតអំណាចមេបា ឬ ញាតិ៤ថ្នាក់របស់ជននោះ។ ប៉ុន្តែករណីដែលកូនធ្លាក់ទៅក្នុងស្ថានភាពដែលគ្មានអ្នកមានអំណាចមេបា មានន័យថា (កូនកំព្រាដែលគ្មានឪពុកម្ដាយគ្រប់គ្រង) នោះអាណាព្យាបាលសម្រាប់អនីតិជនត្រូវចាប់ផ្ដើម (អ្នកគ្រប់គ្រងកូននោះដែលមិនមែនជាឪពុកម្ដាយបង្កើត) គឺតុលាការត្រូវធ្វើការជ្រើសរើសអាណាព្យាបាលសម្រាប់អនីតិជនតាមឆន្ទានុសិទ្ធិរបស់ខ្លួន ឬតាមការស្នើសុំពីញាតិ ៤ថ្នាក់របស់កូននោះ ឬ មេឃុំ ចៅសង្កាត់ នៃលំនៅឋានរស់នៅចុងក្រោយបង្អស់ ឬ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន។

សរុបមក ក្នុងករណីអ្នកដែលមានសិទ្ធិអំណាចមេបាមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនពេញលេញ នោះអាចនឹងត្រូវរងនូវប្រកាសព្យួរ ឬដកហូតអំណាចមេបាពីតុលាការបាន ។ ការដកហូត និងការព្យួរអំណាចមេបា គឺធ្វើឡើងក្នុងគោលបំណងដើម្បីធានាឱ្យកូនទទួលបាននូវសិទ្ធិពេញលេញឡើងវិញ ដែលបណ្ដាលមកពីការធ្វេសប្រហែស ឬការបំពានរបស់អ្នកមានអំណាចមេបា។

## ៦. អាហារកាតព្វកិច្ច

អាហារកាតព្វកិច្ច តាមក្រមរដ្ឋប្បវេណីបច្ចុប្បន្នបានបញ្ញត្តថា ជាកិច្ចដែលត្រូវបំពេញតាមច្បាប់ ឬ តាមសេចក្ដីសម្រេចរបស់តុលាការដែលតម្រូវឱ្យបុគ្គលម្នាក់ ឬ ច្រើននាក់ផ្ដល់នូវប្រាក់ ឬ ទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងញាតិនឹងគ្នា។ មានន័យថាជាប្រាក់ជំនួសផ្នែកហិរញ្ញវត្ថុដែលអាចជាប្រាក់ ឬជាទ្រព្យសម្បត្តិដល់បុគ្គលដែលមិនអាចទ្រទ្រង់ជីវភាពដោយសមត្ថភាពខ្លួនឯងបាន។

អាហារកាតព្វកិច្ចអាចសម្រេចតាមការព្រមព្រៀងរបស់ភាគី ឬ តាមការសម្រេចរបស់តុលាការ ដោយផ្អែកតាមការទាមទារ និងពិចារណាទៅលើសេចក្ដីត្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច លទ្ធភាពទ្រព្យធនរបស់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច និងស្ថានភាពផ្សេងទៀតទាំងអស់។

### ៦.១ ការផ្គត់ផ្គង់សហព័ទ្ធ

គួរបញ្ជាក់ផងដែរថាការផ្គត់ផ្គង់សហព័ទ្ធ កាលពីអតីតកាល ពោលគឺក្នុងក្រមរដ្ឋប្បវេណីចាស់ពាក្យនេះត្រូវបានច្បាប់កំណត់ថា ជាសោធនអាហារណើយ ក្រោយមកក្នុងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានកំណត់ពាក្យនេះថា អាហារកាតួកិច្ចវិញ។ ការផ្គត់ផ្គង់សហព័ទ្ធ សំដៅលើការជួយទ្រទ្រង់សហព័ទ្ធដែលពុំមានសមត្ថភាពចិញ្ចឹមខ្លួនបានក្រោយពេលលែងលះ។ ជាប្រពៃណីនៅក្នុងប្រទេសជាច្រើន ប្ដីមានករណីយកិច្ចផ្គត់

[107] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ១០៥១។

ផ្តង់ប្រពន្ធ ប៉ុន្តែប្រពន្ធមិនមានករណីយកិច្ចផ្គត់ផ្គង់ប្តីទេ ហើយកាលពីអតីតកាលនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាប្រទេសជាច្រើនបានអនុវត្តតាមគោលការណ៍នេះ ដើម្បីផ្គត់ផ្គង់សហព័ទ្ធ។ ជាក់ស្តែងក្រមរដ្ឋប្បវេណី១៩២០ បានបញ្ញត្តថា ប្រពន្ធទាំងនោះ ត្រូវបានសោធនអាហារណើយ តែក្នុងករណីដែលការលែងលះនោះមិនមែនជាកំហុសរបស់ខ្លួន។ ករណីពិសេសចំពោះប្រពន្ធទី១ ប្រសិនបើទ្រព្យរួមកាលបើចែកគ្នាទៅមិនអាចចិញ្ចឹមនាងបានទេ នាងត្រូវបានសោធនអាហារណើយទៀត តែចំពោះតែករណីដែលការលែងលះនោះមិនមែនជាកំហុសខ្លួន។ ចំពោះការផ្គត់ផ្គង់សហព័ទ្ធ ក្រមរដ្ឋប្បវេណីបច្ចុប្បន្នមិនបានចែងឡើយថាកាតព្វកិច្ចត្រូវបញ្ចប់នៅពេលណាឡើយ ប៉ុន្តែច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីបានបញ្ញត្តថាច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារត្រូវបានបាត់បង់អនុភាព លើកលែងតែបញ្ញត្តិមាត្រា៧៦ និងមាត្រា៧៧ នៃច្បាប់នោះនៅតែមានអនុភាព។[108] ដោយបញ្ញត្តិនៃមាត្រានេះសំដៅលើការការពារបុគ្គលសុចរិត ដូចនេះយោងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែលមានមាត្រានៅជាធរមានចែងថា ការផ្គត់ផ្គង់សហព័ទ្ធនឹងត្រូវចប់ កាលបើភាគីទទួលបានការរៀបអាពាហ៍ពិពាហ៍ថ្មី។[109] ជាក់ស្តែងនាពេលបច្ចុប្បន្នករណីដែលផ្គត់ផ្គង់សហព័ទ្ធនេះពុំសូវកើនមានឡើង ព្រោះនៅពេលសហព័ទ្ធសម្រេចថាចង់លែងលះ មានន័យថា ភាគីបានអស់មនោសញ្ចេតនានឹងគ្នា និងមិនចង់មានទំនាក់ទំនងបន្តទៀតឡើយ ការដែលនៅតែបន្តការផ្គត់ផ្គង់ដល់សហព័ទ្ធក្រោយពេលលែងលះបែបនេះ នៅតែមានទំនាក់ទំនងនឹងគ្នាមិនដាច់ស្រឡះ។

ករណីដែលត្រូវផ្តល់អាហារកាតព្វកិច្ចនៅតែបន្តអនុវត្តដល់ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ និងបានកែប្រែនូវចំណុចខ្លះ ដើម្បីធ្វើឱ្យមានការគាំទ្រគ្នាទៅវិញទៅមក ចំពោះប្តី ឬ ប្រពន្ធដែលមានការខ្វះខាតជីវភាព។ ក្នុងករណីលែងលះគ្នា ភាគីដែលគ្មានកំហុស ហើយខ្វះខាតអាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន។ ភាគីខាងក្រោយនេះត្រូវតែជួយឧបត្ថម្ភទៅតាមលទ្ធភាពរបស់ខ្លួន។ ចំពោះច្បាប់នេះគឺបានផ្តោតលើភាពស្មើគ្នាជាធំ ដូចនេះការផ្គត់ផ្គង់សហព័ទ្ធ គឺមិនបានចែងជាក់ច្បាស់ ឬតម្រូវឱ្យប្តីត្រូវតែជាអ្នកទ្រទ្រង់ប្រពន្ធដូចច្បាប់ចាស់ឡើយ។

ក្នុងករណីសុំផ្តាច់នីតិសង្វាសមួយ ដោយហេតុថាចុងចម្លើយ មានជំងឺប្រចាំកាយ ចុងចម្លើយក៏បានធ្វើការស្នើសុំអាហារកិច្ចបន្ថែម ដោយផ្អែកតាមមាត្រា ៧៦ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ តុលាការក៏បង្គាប់ឱ្យភាគីពិភាក្សាគ្នា។ ក្រោយពិភាក្សាគ្នា ដើមចោទបានផ្តល់សិទ្ធិឱ្យចុងចម្លើយ យកផ្ទះដែលតុលាការកាត់មកឱ្យខ្លួនដាក់ជួលដើម្បីយកប្រាក់ចិញ្ចឹមជីវិត។[110]

[108] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា ៧៨។
[109] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ២៦ កក្កដា ១៩៨៩, មាត្រា ៧៦។
[110] សាលក្រមសាលាដំបូងខេត្តកណ្តាល, សំណុំរឿងរដ្ឋប្បវេណី, លេខ ២៦(ប), ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១២។

### ៦.២ ការផ្គត់ផ្គង់កូន

ឪពុកម្តាយមានការទទួលខុសត្រូវក្នុងការផ្តល់ឱ្យកូននូវសេចក្តីត្រូវការជាមូលដ្ឋានរហូតដល់កូននោះពេញវ័យ។ កាលណាមានការលែងលះគ្នា ឪពុកម្តាយដែលលែងលះគ្នានោះនៅតែបន្តការទទួលខុសត្រូវតាមច្បាប់ដើម្បីផ្គត់ផ្គង់កូនតទៅទៀត។ ចំពោះការផ្គត់ផ្គង់កូនក្រោយពេលលែងលះ ជាយន្តការដែលឪពុកម្តាយដែលមិនរស់នៅជាមួយកូន ត្រូវបំពេញករណីយកិច្ចផ្គត់ផ្គង់កូនរបស់ខ្លួន។

ឪពុក ឬ ម្តាយដែលពុំមានអំណាចមេបាក្រោយពេលលែងលះគ្នាមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។ ឪពុកម្តាយដែលលែងលះគ្នាត្រូវជួយផ្គត់ផ្គង់ជួយបីបាច់រក្សា ជួយផ្តល់សោហ៊ុយអប់រំ និងរៀនសូត្រដល់កូនតាមលទ្ធភាពរបស់ខ្លួន។ ចំពោះការកម្រិតអាហារកិច្ច ក្រមរដ្ឋប្បវេណីចាស់បានបញ្ញត្តថាឪពុកម្តាយណាដែលសាលក្រមមិនបានឱ្យរក្សាកូនទេ ឪពុក ឬ ម្តាយនោះត្រូវជួយចិញ្ចឹម ជួយបីបាច់រក្សា ជួយចេញសោហ៊ុយអប់រំ និងរៀនសូត្ររបស់កូននោះតាមសមគួរដល់ធនធានរបស់ខ្លួនផង។ ការបញ្ញត្តិរបស់ក្រមរដ្ឋប្បវេណី១៩២០ មានលក្ខណៈងាយស្រួល ដោយមិនបានតម្រូវឱ្យប្តី ឬ ប្រពន្ធដែលមិនមានអំណាចមេបា ត្រូវតែជាអ្នកផ្គត់ផ្គង់កូនដូចច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ព្រមទាំងក្រមរដ្ឋប្បវេណីបច្ចុប្បន្នទេ។ ដោយច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានចែងថាអាហារកិច្ចត្រូវផ្តល់ឱ្យកូនរហូតដល់កូនមាននីតិភាព។[111] ប៉ុន្តែនៅក្នុងក្រមរដ្ឋប្បវេណីបច្ចុប្បន្ន មិនបានចែងកំណត់អំពីរយៈពេលនៃការផ្តល់អាហារកាតព្វកិច្ចឱ្យកូនរហូតដល់កូនមានអាយុប៉ុន្មានឡើយ។

ច្បាប់បានផ្តល់នូវនីតិវិធីខុសគ្នាពីរ គឺកំណត់ការផ្គត់ផ្គង់កូនដោយឈរលើការព្រមព្រៀងរបស់ភាគី និងដោយសេចក្តីសម្រេចរបស់តុលាការ។ មានន័យថាប្តីប្រពន្ធអាចកំណត់អ្នកមានអំណាចមេបា និងអ្នកពុំមានអំណាចមេបាដោយការពិភាក្សាគ្នាបាន បើភាគីទាំងពីរពុំអាចធ្វើការពិភាក្សាបានទេ តុលាការត្រូវកំណត់អំពីរបៀបចូលជួបប្រាស្រ័យទាក់ទង និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូនតាមការទាមទាររបស់ឪពុក ឬ ម្តាយ។[112] តុលាការក៏នៅតែត្រូវកំណត់ ដោយគិតពិចារណាទៅលើសេចក្តីត្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច លទ្ធភាពទ្រព្យធនរបស់ជនដែលមានករណីយកិច្ច ត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច និងស្ថានភាពផ្សេងទៀតទាំងអស់របស់ឪពុកម្តាយ។

យោងតាមករណីមួយដែលដើមចោទបានប្តឹងលែងលះពីចុងចម្លើយ នៅពេលលែងលះដើមចោទ បានទាមទារសិទ្ធិអំណាចមេបា និងទាមទារប្រាក់អាហារកាតព្វកិច្ចចំនួន USD ៦,០០០ ក្នុងមួយឆ្នាំ ដោយប្រគល់

[111] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩, មាត្រា ៧៤។

[112] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ១០៤០ កថាខណ្ឌទី ៥។

ទ្រព្យរួម និងបំណុលរួមទាំងអស់ឱ្យចុងចម្លើយ ជាអ្នកទទួលខុសត្រូវទាំងស្រុង ដោយសារទ្រព្យរួមទាំងនោះ គឺចុងចម្លើយកំពុងធ្វើការបង់រំលោះម្នាក់ឯងតាំងពីដើម។ ក៏ប៉ុន្តែចុងចម្លើយបានអះអាងថាមុនពេលដាក់ពាក្យប្តឹងលែងលះ លោកបានលក់ផ្ទះមួយកន្លែងតម្លៃ USD ៧,០០០,០០០ រួចក៏បានប្រគល់ប្រាក់ទាំងនោះឱ្យទៅ ដើមចោទទាំងអស់ជាថ្លៃចិញ្ចឹមកូន និងទិញផ្ទះសម្រាប់ឱ្យកូនរស់នៅ។ ដើមចោទក៏បានទទួលស្គាល់ថាពិតជាបានទទួលប្រាក់នោះពិតប្រាកដមែន។ ក្រោយតុលាការបានវិនិច្ឆ័យ ក៏សម្រេចឱ្យចុងចម្លើយ ផ្តល់ប្រាក់អាហារកាតព្វកិច្ចចំនួន USD ៣,០០០ ក្នុងមួយឆ្នាំ។ ដោយហេតុថា តុលាការបានសម្រេចប្រគល់ទ្រព្យសម្បត្តិ និងបំណុលរួមទាំងអស់ឱ្យចុងចម្លើយ ជាអ្នកទទួលខុសត្រូវបង់រំលោះបន្ត តាមស្ថានភាពចុងចម្លើយ មានបន្ទុកជាច្រើន ក្នុងការរកប្រាក់ចំណូលដើម្បីដោះស្រាយបំណុល ដូចនេះចុងចម្លើយពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់អាហារកាតព្វកិច្ចចំនួន USD ៦,០០០ ក្នុងមួយឆ្នាំតាមការទាមទាររបស់ដើមចោទឡើយ។[113]

តាមទិដ្ឋភាពក្នុងសង្គមជាក់ស្តែងដើម្បីទទួលបានសិទ្ធិលើអំណាចមេបា ភាគីតែងតែបោះបង់ចោលនូវការទាមទារប្រាក់អាហារកាតព្វកិច្ចពីភាគីម្ខាងទៀត។ ស្ថិតក្នុងស្ថានភាពបែបនេះ តុលាការនឹងធ្វើការសម្រេចតាមឆន្ទានុសិទ្ធិរបស់ខ្លួន ដោយពិចារណាលើផលប្រយោជន៍របស់កូននោះជាចម្បង។[114]

ជាក់ស្តែងក្នុងសំណុំរឿងលែងលះដោយពុំមានការព្រមព្រៀង ភាគីទាំងសងខាងបានទាមទារសិទ្ធិអំណាចមេបាលើកូន ៣នាក់ ដោយបញ្ជាក់ថាខ្លួននឹងពុំទាមទារប្រាក់អាហារកាតព្វកិច្ចពីភាគីដែលពុំមានសិទ្ធិលើអំណាចមេបាឡើយ។ ក៏ប៉ុន្តែតុលាការបានសម្រេចឱ្យឪពុកដែលមិនមានសិទ្ធិអំណាចមេបាមានកាតព្វកិច្ចជួយផ្តល់នូវសោហ៊ុយចាំបាច់ ដើម្បីគ្រប់គ្រង ថែរក្សាកូនទៅតាមលទ្ធភាព ដោយផ្អែកតាមបញ្ញត្តិមាត្រា ១០៤០ កថាខណ្ឌ ១ នៃក្រមរដ្ឋប្បវេណី ២០០៧ ។ ដោយតុលាការយល់ឃើញថានេះជាករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ ដើម្បីថែរក្សាកូនរបស់ឪពុក ឬម្តាយដែលពុំមានអំណាចមេបា និងផ្អែកតាមបញ្ញត្តិមាត្រា ៤៧ នៃរដ្ឋធម្មនុញ្ញ ដែលបានបញ្ញត្តថាកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អរបស់មាតាបិតា។ រីឯករណីដូចគ្នានេះដែរ ដែលកើតឡើងនៅខេត្តកណ្តាល ភាគីក៏បានទាមទារសិទ្ធិអំណាចមេបាលើកូនដោយបញ្ជាក់ថាខ្លួននឹងពុំទាមទារប្រាក់អាហារកាតព្វកិច្ចពីភាគីដែលពុំមានសិទ្ធិលើអំណាចមេបាដូចគ្នា។

ករណីនេះតុលាការសាលាដំបូងខេត្តកណ្តាលបានបញ្ជាក់ក្នុងសំអាងហេតុថា ដើមចោទបានទាមទារសិទ្ធិគ្រប់គ្រងកូន ដោយមិនទាមទារអាហារកាតព្វកិច្ចចិញ្ចឹមកូនទេ ហេតុនេះតុលាការពុំចាំបាច់លើកយកបញ្ហានេះមកពិចារណាឡើយ។

---

113 សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ៥៣ “ ង១ ”, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣។

114 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧, មាត្រា ១០៣៧ កថាខណ្ឌទី ៣។

# សេចក្តីសន្និដ្ឋាន

ការវិវត្តនៃការលែងលះនៅកម្ពុជានាពេលបច្ចុប្បន្នបានបង្ហាញអំពីភាពខុសគ្នារវាងការលែងលះកាលពីសម័យដើម ដែលមានភាពស្មុគស្មាញ ព្រមទាំងមានការដាក់បន្ទុក ហើយការលែងលះបច្ចុប្បន្ន ដែលមានលក្ខណៈងាយស្រួល ធ្វើឱ្យសហព័ទ្ធជាច្រើនយល់ថាការលែងលះជារឿងមួយដែលធម្មតា។ ដូចជាករណីការលែងលះដោយការព្រមព្រៀងតុលាការបានចេញដីកាសម្រេចដោយពុំបានធ្វើនីតិវិធីអ្វីទាំងអស់ សូម្បីការសាកសួរភាគីក៏ពុំមានការសាកសួរឡើយ ដែលនេះអាចបណ្តាលឱ្យភាគីសម្រេចលែងលះតាមតែអំពើចិត្ត ហើយប្រសិនបើករណីលែងលះនេះមានវិការៈវិញ នោះនឹងធ្វើឱ្យភាគីម្ខាងទៀតបាត់បង់ផលប្រយោជន៍មិនខាន។

បច្ចុប្បន្នការលែងលះនៅកម្ពុជាមានភាពធូររលុង ដោយសារការអនុវត្តច្បាប់មិនបានត្រឹមត្រូវ។ ជាក់ស្តែងក្នុងសំណុំរឿងដែលបានយកមកធ្វើការសិក្សាលើប្រធានបទនេះ នៅមានចន្លោះខ្វះខាតដែលមានភាពស្រពេចស្រពិល ដោយសារអ្នកអនុវត្តច្បាប់ពុំបានគោរពតាមបញ្ញត្តិច្បាប់ទាំងស្រុង ដូចជាការលែងលះដោយពាក្យបណ្តឹង តែក្រោយមានការពិភាក្សាគ្នាភាគីបានលែងលះដោយព្រមព្រៀងវិញ តែតុលាការនៅតែសម្រេចចេញជាសាលក្រមធម្មតា ដែលមិនមែនជាដីកាសម្រេច។ លើសពីនេះទៅទៀត ពាក់ព័ន្ធនឹងដំណើរការនៃនីតិវិធីមានភាពយឺតយ៉ាវ តួយ៉ាងក្នុងសំណុំរឿងលែងលះដែលបណ្តាលមកពីការប្រើប្រាស់អំពើហិង្សា ឃើញថាចាប់ពីថ្ងៃដាក់ពាក្យបណ្តឹងរហូតដល់ថ្ងៃសម្រេចសេចក្តីគឺប្រើពេលដល់ទៅ៣ឆ្នាំ។

ការវិវត្តនៃច្បាប់ បានផ្តល់ឱ្យស្ត្រីទទួលបានឯករាជ្យពេញលេញ មិនត្រូវការពឹងផ្អែកតែលើបុរសទាំងស្រុងឡើយ ដែលបណ្តាលឱ្យស្ត្រីមានភាពរឹងមាំ ក្នុងការដើរចេញដោយមិនខ្វល់ពីបញ្ហាអ្វីឡើយ។ ជាក់ស្តែងតាមរយៈពាក្យបណ្តឹងដែលបានយកមកសិក្សា ឃើញថាភាគច្រើនគឺស្ត្រីជាអ្នកដាក់ពាក្យបណ្តឹង។

ក្នុងការវិវត្តច្បាប់នៃការលែងលះនេះ ចំពោះភាគីមានផលវិជ្ជមាន ដោយសារបុគ្គលគ្រប់រូបមានសេរីភាពក្នុងការជ្រើសរើសជីវភាពដែលខ្លួនឯងចង់បាន មនុស្សគ្រប់គ្នាគប្បីរស់នៅប្រកបដោយការគោរព ការស្រលាញ់ ការយកចិត្តទុកដាក់ពីមនុស្សដែលខ្លួនស្រលាញ់ ការប្រគល់ឱ្យ គប្បីទទួលបានមកវិញនៅការតបស្នងវិញដ៏សមគួរ។ ប្រសិនបើមានកាផិតក្បត់ ការប្រើប្រាស់អំពើហិង្សា ឬ ការប្រព្រឹត្តិទង្វើមិនសមគួរ និងករណីផ្សេងៗទៀតដែលធ្វើឱ្យភាគីអស់មនោសញ្ចេតនា មិនអាចបន្តទៅមុខបានទេ ភាគីគប្បីសម្រេចដើរចេញ ដើម្បីសេចក្តីសុខរបស់ខ្លួននេះជាករណីដែលសមគួរ។ ក៏ប៉ុន្តែចំពោះសង្គមវិញការលែងលះមិនមែនជាជម្រើសល្អឡើយ ព្រោះរាល់ការលែងលះសុទ្ធតែបណ្តាលឱ្យមានផលប៉ះពាល់ដល់កូនៗ ជាពិសេសគឺការប៉ះពាល់ដល់ផ្លូវអារម្មណ៍របស់កូន។ ក្រោយពេលលែងលះឪពុក ឬ ម្តាយដែលមិនទទួលបានសិទ្ធិគ្រប់គ្រងកូន មិនអាចបំពេញតួនាទីរបស់ខ្លួនចំពោះកូនដូចមុន អាចនឹងបណ្តាលឱ្យមានបញ្ហាមនោសញ្ចេតនារវាងឪពុកម្តាយនឹងកូន។ បញ្ហាផ្លូវចិត្តរបស់កូន ក៏អាចបណ្តាលឱ្យមានផលប៉ះពាល់ដល់អនាគតរបស់កូនៗ ដែលជាធនធានមនុស្សរបស់សង្គមជាតិ។

# អនុសាសន៍

បន្ទាប់ពីឆ្លងកាត់ការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី «ការវិវត្តនៃការលែងលះនៅកម្ពុជា» ខាងលើរួចមក ឃើញថាការអនុវត្តច្បាប់ទាក់ទងនឹងការលែងលះនៅកម្ពុជា និងដំណោះស្រាយក្នុងការលែងលះនៅមានភាពខ្វះចន្លោះនៅឡើយ ដូចនេះសូមអនុញ្ញាតសំណូមពរ និងផ្តល់មតិយោបល់ផ្ទាល់ខ្លួន ក្នុងការរួមគំនិតដើម្បីលើកស្ទួយវិស័យយុត្តិធម៌ឱ្យកាន់តែល្អប្រសើរ។

- តុលាការដែលទទួលបានសមត្ថកិច្ចក្នុងការដោះស្រាយក្នុងសំណុំរឿងលែងលះ គប្បីព្យាយាមផ្សះផ្សាគូភាគីឱ្យអស់ពីលទ្ធភាព ជាក់ស្តែងចំពោះការផ្សះផ្សាបច្ចុប្បន្នមានភាពធូររលុង បើធៀបទៅនឹងក្រមរដ្ឋប្បវេណីចាស់។
- ចំពោះករណីការលែងលះដោយមានការព្រមព្រៀង គប្បីមានការត្រួតពិនិត្យឱ្យបានច្រើនជាងនេះ ដើម្បីជៀសវាងការលែងលះដែលមានវិការៈ។
- ចំពោះដំណើរការនៃនីតិវិធីលែងលះ ក្នុងករណីខ្លះគប្បីពន្លឿននីតិវិធីក្នុងការដោះស្រាយ ដូចជាការលែងលះបណ្តាលមកពីការប្រើអំពើហិង្សា ឬ ករណីផិតក្បត់ ជាកត្តាមួយធ្វើឱ្យមានផលប៉ះពាល់ដល់ភាគីម្ខាងទៀត។ តុលាការគប្បីពន្លឿននីតិវិធីក្នុងការដោះស្រាយ ដើម្បីជៀសវាងពីការធ្វើទុកបុកម្នេញទៅលើភាគីដើមបណ្តឹង។
- ហើយករណីខ្លះទៀតគប្បីបន្ថែមដំណើរការនីតិវិធីមុនការសម្រេចឱ្យភាគីលែងលះ ដូចជាករណីបែកលំនៅសង្វាសរយៈពេលមួយឆ្នាំ ដោយនៅពេលដែលមានការជូនដំណឹងពាក់ព័ន្ធនឹងការដែលសហព័ទ្ធម្ខាងទៀតបានចាកចេញពីលំនៅឋានទៅកាន់ក្រុមប្រឹក្សាឃុំសង្កាត់ដែលខ្លួនរស់នៅ ក្រុមប្រឹក្សាឃុំសង្កាត់គប្បីកោះហៅភាគីដែលបានចាកចេញពីលំនៅសង្វាសមកសួរនាំ ហើយព្យាយាមផ្សះផ្សាភាគីឱ្យត្រឡប់មករួមរស់ជាមួយគ្នាក្នុងនាមជាប្តីប្រពន្ធវិញ។

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។
- ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, លេខ នស/រកម/០៧២៣/ ០០៩, ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣។
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ចុះថ្ងៃទី ២៥ ខែមិថុនា ២០១០។
- ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០។
- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។
- ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦។
- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ, លេខ នស/រកម/១០០៥/០៣១, ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៥។

## ២. បទដ្ឋានគតិយុត្តដែលនិរាករណ៍

- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩។
- ក្រមរដ្ឋប្បវេណីចាស់, ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០។

## ៣. សេចក្តីសម្រេច

- ដីកាសម្រេចសាលាដំបូងខេត្តបន្ទាយមានជ័យ, សំណុំរឿងរដ្ឋប្បវេណី, លេខ ៥៥០ ពស.មប “ ញ ”/ ២២, ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២។
- ដីកាសម្រេចសាលាដំបូងខេត្តកណ្តាល, សំណុំរឿងរដ្ឋប្បវេណី, លេខ ១១៨ (ល), ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៣។
- សាលក្រមសាលាដំបូងខេត្តព្រៃវែង, សំណុំរឿងរដ្ឋប្បវេណី, បណ្តឹងចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩។
- សាលក្រមសាលាដំបូងខេត្តកំពង់ស្ពឺ, សំណុំរឿងរដ្ឋប្បវេណី, លេខ ៨៦ “ ឆ ” , ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២។
- សាលក្រមសាលាដំបូងខេត្តកំពង់ស្ពឺ, សំណុំរឿងរដ្ឋប្បវេណី, ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២។
- សាលក្រមសាលាដំបូងខេត្តកណ្តាល, សំណុំរឿងរដ្ឋប្បវេណី, លេខ ២៦(ប), ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០១២ ។

- សាលាក្រមសាលាដំបូងខេត្តបាត់ដំបង, សំណុំរឿងរដ្ឋប្បវេណី, លេខ ២៧ “ ញ ”, ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ ។
- សាលក្រមចំពោះមុខភាគីរបស់សាលាដំបូងខេត្តតាកែវ, សំណុំរឿងរដ្ឋប្បវេណី, លេខ ២២ (ក), ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៩ ។
- សាលក្រមសាលាដំបូងខេត្តត្បូងឃ្មុំ, សំណុំរឿងរដ្ឋប្បវេណី,  ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ។
- សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ៥៣ “ ង១ ”, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣ ។
- សាលក្រមសាលាដំបូងរាជធានៅភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ។
- សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ១០៤៣ “ ដ ”, ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ ។
- សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ៩០៩, ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០១៨ ។
- សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ១៦, ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ ២០១៨ ។
- សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ១៩១ “ ញ ”, ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨ ។
- សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ២៧១២ “ ធ ”, ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧ ។
- សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, សំណុំរឿងរដ្ឋប្បវេណី, លេខ ៤៣ “ ញ ”, ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០១០ ។

## ៤. សៀវភៅ និងស្នាដៃនិពន្ធផ្សេងៗ

- ក្រសួងយុត្តិធម៌,    សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង.  ភ្នំពេញ, ២០១១។
- ក្រសួងយុត្តិធម៌, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល,  ភ្នំពេញ, ២០១១។
- គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី   និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីពន្យល់នៃក្រមរដ្ឋប្បវេណី, ភាគ៥, គន្លីទី៧, ក្រសួងយុត្តិធម៌, ២០១០។
- ជ័យ រិទ្ធី, អត្ថបទ ការលែងលះ។

- ផុន វណ្ណា, អត្ថបទសាកល្បងស្ដីពី លក្ខខណ្ឌនៃការលែងលះដោយការពរមព្រៀង។
- មន្ទីរសារការី អេស ខេ វ៉ាយ, អត្ថបទផលវិបាកនៃការមិនចុះបញ្ជីអាពាហ៍ពិពាហ៍ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១។
- មេធាវី កែវ វ៉ាន្នី, សៀវភៅច្បាប់នីតិវិធីរដ្ឋប្បវេណី, ផ្នែកទី១ នីតិវិធីបណ្ដឹង។
- អៀង សំណាង, សៀវភៅសំណួរ-ចម្លើយ នីតិគ្រួសារ។
- ឥន យឿន, សៀវភៅនីតិគ្រួសារ និងអាពាហ៍ពិពាហ៍, ភាគ២, ឆ្នាំ២០១៣។
- CEIC | Cambodia Population Distribution : Divorced | Economic Indicators ( ២០២១ ) https://www.ceicdata.com/en/cambodia/population-cambodia-socioeconomic-survey-cses/population-distribution-divorced ( ថ្ងៃចូលមើល ១១/០៧/២០២៣ )

## ឧបសម្ព័ន្ធ

## ទម្រង់លិខិតបទដ្ឋានពាក់ព័ន្ធនឹងការលែងលះ

- កិច្ចព្រមព្រៀងលែងលះ
- កិច្ចព្រមព្រៀងបែងចែកបំណុល
- ពាក្យសុំលែងលះ
- ដីកាសម្រេចលែងលះ
- ពាក្យបណ្ដឹងលែងលះ
- សាលក្រមលែងលះ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងលែងលះ

**ភាគី"ក"** ឈ្មោះ ភេទប្រុស ថ្ងៃខែឆ្នាំកំណើត០១ មករា ១៩៨៦ ជនជាតិខ្មែរ មានអាសយដ្ឋានរស់នៅ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ត្រូវជាប្ដី។ និង

**ភាគី"ខ"** ឈ្មោះ ភេទស្រី ថ្ងៃខែឆ្នាំកំណើត១៦ សីហា ១៩៩២ ជនជាតិខ្មែរ មានអាសយដ្ឋានរស់នៅ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ត្រូវជាប្រពន្ធ។

## បុព្វកថា

**ដោយហេតុថា** ភាគី(ក) និងភាគី(ខ) មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់នឹងគ្នាតាមរយៈសំបុត្រអាពាហ៍ពិពាហ៍លេខ៣៨ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានស
សិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ រហូតមកទល់ពេលនេះ គូភាគីទទួលស្គាល់ថា មានកូនជាមួយគ្នា ចំនួន ០១នាក់ ។

**ដោយហេតុថា** ភាគី(ក) និងភាគី(ខ) មានភាពរកាំរកូសនឹងគ្នា រហូតឈានដល់អស់មនោសញ្ចេតនា នៃការរស់នៅជាប្ដីប្រពន្ធនឹងគ្នាតទៅទៀតហើយ។

**ដោយហេតុថា** ភាគី(ក) និងភាគី(ខ) មានបំណងបង្ហាញឆន្ទៈផ្ដាច់ ចំណងអាពាហ៍ពិពាហ៍ទៅតាមផ្លូវច្បាប់ ចាប់ពីពេលនេះតទៅ។

## ក្រោយពីបានពិភាក្សា គូភាគីឯកភាពព្រមព្រៀងគ្នា ដែលមានខ្លឹមសារដូចខាងក្រោម÷

**ប្រការ១** ភាគី(ក) និងភាគី(ខ) ព្រមព្រៀងលែងលះ ដោយស្ម័គ្រចិត្តពុំមានការបង្ខិតបង្ខំពីភាគីណាមួយទេ ព្រមទាំងសន្យាថាផ្ដល់សេរីភាពដល់ភាគីទាំងសងខាងក្នុងការស្វែងរកគូរស្រករថ្មី និងមិនរករឿងបង្ក ទំនាស់អ្វីដល់គ្នាទាំងសងខាង ចាប់ពីថ្ងៃផ្ដិតស្នាមមេដៃ នេះតទៅ។

**ប្រការ២** ភាគី(ក) ផ្ដល់សិទ្ធិអំណាចមេបាដល់ភាគី(ខ) ក្នុងការគ្រប់គ្រងចិញ្ចឹមបីបាច់លើកូនស្រី ចំនួន ០១នាក់ ឈ្មោះ ថ្ងៃខែឆ្នាំកំណើត១៦ តុលា ២០១៧ ដែលមានសំបុត្របញ្ជាក់កំណើតលេ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ ភាគី(ខ) ទទួលបន្ទុកកាតព្វកិច្ចក្នុងការផ្ដល់អាហារកិច្ចចិញ្ចឹមកូន ហើយភាគី(ក) មានសិទ្ធិប្រាស្រ័យទាក់ទង និងជួបសួរសុខទុក្ខកូន បានគ្រប់ពេលវេលា។

**ប្រការ៣** ភាគីទាំងពីរទទួលស្គាល់ថាចាប់តាំងពីរៀបអាពាហ៍ពិពាហ៍ រហូតមកដល់បច្ចុប្បន្ន ភាគីទាំងពីរពុំមានទ្រព្យសម្បត្តិរួម ឬបំណុលរួមគ្នាណាមួយ សម្រាប់ធ្វើការបែងចែកក្នុងកិច្ចព្រមព្រៀងនេះនោះទេ។

**ប្រការ៤** ភាគី(ក) និងភាគី(ខ) ឯកភាពរៀបចំដាក់ពាក្យសុំលែងលះទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីបញ្ចប់ចំណងអាពាហ៍ពិពាហ៍នេះ តាមផ្លូវច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៥** ភាគីទាំងពីរព្រមព្រៀងអនុវត្តកិច្ចព្រមព្រៀងដោយស្ម័គ្រចិត្ត និងយល់ព្រមផ្តិតមេដៃទុកជា ភស្តុតាង។ កិច្ចព្រមព្រៀងនេះ មានអានុភាពអនុវត្តចាប់តាំងពីថ្ងៃដែលភាគីទាំងសងខាងផ្តិតមេដៃ។ កិច្ចព្រមព្រៀងនេះធ្វើឡើងចំនួន០៥ច្បាប់ ដែលមានខ្លឹមសារដូចគ្នា។ ចំនួន០២ច្បាប់សម្រាប់ភាគី"ក" និងភាគី"ខ", ០១ច្បាប់តំកល់ទុកនៅរដ្ឋបាលសង្កាត់កំពង់ស្វាយ, ០១ច្បាប់តំកល់ទុកនៅការិយាល័យមេធាវីប្រថាប់ត្រា និង ០១ច្បាប់ទៀតសម្រាប់ភ្ជាប់ជាឯកសារ ជូនតុលាការ។

សង្កាត់កំពង់ស្វាយ, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២

**សាក្សី**

**ហត្ថលេខា និងត្រា**

**ស្នាមមេដៃស្តាំ និងឈ្មោះ**

**ភាគី"ក"** **ភាគី"ខ"**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

បណ្ដឹង/ពាក្យសុំ.....

លេខ .....ចុះថ្ងៃទី.....ខែ.....ឆ្នាំ.....

ទៅក្រុមទទួលបន្ទុក.....

# ពាក្យសុំដីកាសម្រេច

**អ្នកដាក់ពាក្យសុំ÷** ឈ្មោះ ភេទស្រី ថ្ងៃខែឆ្នាំកំណើត១៦ សីហា ១៩៩២ ជនជាតិខ្មែរ មានអាសយដ្ឋានរស់នៅ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ត្រូវជា ប្រពន្ធ។ ***និង***

**ភាគីម្ខាងទៀត÷** ឈ្មោះ ភេទប្រុស ថ្ងៃខែឆ្នាំកំណើត០១ មករា ១៩៨៦ ជនជាតិខ្មែរ មានអាសយដ្ឋានរស់នៅភូមិ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ត្រូវជា ប្តី។

## សូមគោរពចូលមក

## ឯកឧត្តមប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ

*សូមទានជ្រាប។*

**កម្មវត្ថុ÷** ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារឱ្យតុលាការចេញ÷

១. ឱ្យអ្នកដាក់ពាក្យសុំឈ្មោះ និងភាគីម្ខាងទៀតឈ្មោះ លែងលះគ្នាតាមការព្រមព្រៀង ចាប់ពីពេលនេះតទៅ។

២. ឱ្យអ្នកដាក់ពាក្យសុំឈ្មោះ មានអំណាចមេបាលើកូនស្រីឈ្មោះ ថ្ងៃខែឆ្នាំកំណើត១៦ តុលា ២០១៧ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់កំពង់ស្វាយ។

**យោង÷** - ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា

- ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំមានកិត្តិយសសូមជម្រាបជូនលោក **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា÷ យើងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវស្របច្បាប់ជាមួយគ្នា នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

ក្នុងរយៈពេលជាងមួយឆ្នាំមកនេះ យើងខ្ញុំមានការរស់នៅមិនចុះសម្រុងនឹងគ្នា ដោយសារបញ្ហារកាំរកូសជាច្រើនក្នុងគ្រួសារ ដែលធ្វើឱ្យយើងខ្ញុំសម្រេចចិត្តបែកគ្នា ។

ដោយសារអសមនោសញ្ចេតនា មិនអាចវិលត្រឡប់រួមរស់ជាមួយគ្នាឡើងវិញ ទើបនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ យើងខ្ញុំក៏ស្ម័គ្រចិត្តបង្ហាញឆន្ទៈ យល់ព្រមលែងលះដោយការព្រមព្រៀង ដោយមានផ្តិតស្នាមមេដៃលើកិច្ចព្រមព្រៀងលែងលះជាភស្តុតាង ចំពោះមុខសាក្សី។

ដូចនេះហើយ យើងខ្ញុំសម្រេចចិត្តដាក់ពាក្យសុំលែងលះដោយស្ម័គ្រចិត្តមកតុលាការ ដើម្បីផ្តាច់ចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាជ្រាបពិនិត្យ និងសម្រេចតាមការស្នើសុំដូចក្នុងកម្មវត្ថុខាងលើ របស់យើងខ្ញុំដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

បន្ទាយមានជ័យ, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២

| | | |
|---|---|---|
| **បានឃើញស្នាមមេដៃ** | **បានឃើញ និងយល់ព្រម** | **ស្នាមម្រាមដៃស្តាំអ្នកដាក់ពាក្យសុំ** |
| **មន្ត្រីលេខា និងត្រា** | **ភាគីម្ខាងទៀត** | |

AVO ATT KINGDOM OF C

មេធាវី.

**ជូនភ្ជាប់មកជាមួយនូវឯកសារ÷**

-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ (ច្បាប់សេចក្តីចម្លង)

-សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៨ (ច្បាប់សេចក្តីចម្លង)

-កិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ (ច្បាប់ដើម)

លេខទំនាក់ទំនង មេធាវី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបន្ទាយមានជ័យ

******

សំណុំរឿងរដ្ឋប្បវេណី
ដែលមិនមែនជាបណ្តឹងលេខ:
ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២

# ដីកាសម្រេច

លេខ: ២ យើង ចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ

- បានឃើញ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។

- បានឃើញ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ ។

- បានឃើញ សំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងលេខ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានភាគី៖

<u>-អ្នកដាក់ពាក្យសុំ</u> : ឈ្មោះ ភេទស្រី កើតឆ្នាំ១៩៩២ សញ្ជាតិខ្មែរ ។
អាសយដ្ឋាន សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

<u>-ភាគីម្ខាងទៀត</u> : ឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៨៦ សញ្ជាតិខ្មែរ ។
អាសយដ្ឋាន សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

<u>-អ្នកតំណាងដោយអាណត្តិ</u>: លោកមេធាវី អត្តលេខ
មានការិយាល័យមេធាវី ស្ថិតនៅផ្ទះលេខ ៥៧+៥៩ ផ្លូវបេតុង ភូមិត្រា៤ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

<u>-ខ្លឹមសារនៃដីកាសម្រេចដែលទាមទារដោយអ្នកដាក់ពាក្យសុំ:</u>

១.លែងលះគ្នារវាងអ្នកដាក់ពាក្យសុំឈ្មោះ និងភាគីម្ខាងទៀតឈ្មោះ *តាមការព្រមព្រៀង*។

២.កំណត់ថា អ្នកដាក់ពាក្យសុំឈ្មោះ ជាម្តាយ មានអំណាចមេបាលើកូនឈ្មោះ ភេទស្រី កើតថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ សញ្ជាតិខ្មែរ ។

*<u>អង្គហេតុដែលជាមូលហេតុនៃការទាមទារ:</u>*

កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ភាគីអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀត បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានសង្កាត់

កំពង់ស្វាយ ។ ក្នុងរយៈពេលមួយឆ្នាំជាងនេះ គូភាគីបានរស់នៅមិនចុះសម្រុងនឹងគ្នា មានបញ្ហារការកូសជាមួយគ្នា ហើយបានរស់បែកគ្នាជិតមួយឆ្នាំមកហើយ ។ ដោយសារតែអស់មនោសញ្ចេតនានឹងគ្នា មិនអាចវិលត្រឡប់មករស់នៅជាមួយគ្នាជាប្ដីប្រពន្ធទៀតបាន ទើបនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ គូភាគីបានបង្ហាញឆន្ទៈព្រមព្រៀងលែងលះគ្នា ដោយបានផ្ដិតមេដៃលើកិច្ចព្រមព្រៀងលែងលះគ្នា ដោយមានសាក្សីដឹងលឺផងដែរ ។

***ភស្តុតាងបញ្ជាក់ និងភ្ជាប់មកជាមួយ៖***

-កិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ ។

-សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ។

-សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ។

## សំអាងហេតុ

១-ពាក្យសុំដីកាសម្រេច ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ របស់អ្នកដាក់ពាក្យសុំឈ្មោះ និងភាគីម្ខាងទៀតឈ្មោះ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវ តាមមាត្រា ៣, មាត្រា ៤ និងមាត្រា ២៦ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ។

២-តាមសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់កំពង់ស្វាយ បញ្ជាក់បានថា គូភាគីមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។

៣-ពាក្យសុំដីកាសម្រេច ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២, កិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ និងការអះអាងរបស់គូភាគី បញ្ជាក់បានថា:

ក.ទំនាក់ទំនងអាពាហ៍ពិពាហ៍របស់គូភាគីត្រូវបានបែកបាក់ ហើយភាគីទាំងសងខាងមានបំណងពិតប្រាកដ រំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ហើយបានព្រមព្រៀងលែងលះគ្នា ស្របតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ។

ខ.គូភាគីបានពិភាក្សាគ្នាអំពីអំណាចមេបាលើកូន ដោយបានព្រមព្រៀងគ្នាកំណត់ថា អ្នកដាក់ពាក្យសុំឈ្មោះ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ ភេទស្រី កើតថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ សញ្ជាតិខ្មែរ ។

ការព្រមព្រៀងរបស់គូភាគីនេះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ហេតុដូច្នេះតុលាការគប្បីសម្រេចតាមការព្រមព្រៀងរបស់គូភាគី ស្របតាមមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី ។

៤-គប្បីឱ្យភាគីអ្នកដាក់ពាក្យសុំជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី យោងតាមមាត្រា ២២ និងមាត្រា ២៣ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង និងមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្ដីសម្រេចបញ្ចប់

១.លែងលះគ្នារវាងអ្នកដាក់ពាក្យសុំឈ្មោះ និងភាគីម្ខាងទៀតនៃពាក្យសុំឈ្មោះ *តាមការព្រមព្រៀង* ។

២.កំណត់ថា អ្នកដាក់ពាក្យសុំឈ្មោះ ជាម្ដាយ អ្នកមានអំណាចមេបាលើកូនឈ្មោះ

ភេទស្រី កើតថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ សញ្ជាតិខ្មែរ ។

៣.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីអ្នកដាក់ពាក្យសុំ ។

ថ្ងៃសុក្រ ៨កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

បន្ទាយមានជ័យ, ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២

ហត្ថលេខា និងត្រា: **ចៅក្រម**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ៨កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

បន្ទាយមានជ័យ, ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២

បានឃើញ

**ចៅក្រម**

**ក្រឡាបញ្ជី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តបន្ទាយមានជ័យ**

លេខ: [redacted]

# លិខិតបញ្ជាក់ការចូលជាស្ថាពរ

**យើង [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តបន្ទាយមានជ័យ**

បានឃើញ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ ។

បានឃើញ សំណុំរឿងដែលមិនមែនជាបណ្តឹងលេខ [redacted] ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

បានឃើញ ដីកាសម្រេចលេខ [redacted] ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

បានឃើញ របាយការណ៍អំពីការបញ្ជូន ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២ ឱ្យទៅអ្នកដាក់ពាក្យសុំ ។

បានឃើញ របាយការណ៍អំពីការបញ្ជូន ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២ ឱ្យទៅភាគីម្ខាងទៀតនៃពាក្យសុំ ។

បានឃើញ ពាក្យសុំលិខិតបញ្ជាក់ការចូលជាស្ថាពរនៃដីកាសម្រេច ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ របស់ [redacted] ។

បានឃើញ បង្កាន់ដៃបង់ប្រាក់លេខ [redacted] ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

**សូមបញ្ជាក់ថា**

១.ដីកាសម្រេចលេខ [redacted] ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ បានចូលជាស្ថាពរមានអនុភាពអនុវត្ត ចាប់ពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ រួចហើយ ។

២.លិខិតបញ្ជាក់ការចូលស្ថាពរនេះ ចេញឱ្យសាមីខ្លួនដើម្បីយកទៅប្រើប្រាស់តាមផ្លូវច្បាប់ ។

ថ្ងៃពុធ ៥កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

បន្ទាយមានជ័យ, ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

សាលាដំបូងខេត្តកណ្ដាល

ចូល

សំណុំរឿងរដ្ឋប្បវេណី

លេខ... ..................

ថ្ងៃទី.០៦..ខែ..៩...ឆ្នាំ២០

បង់ពន្ធរួច

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្ដឹង

នាងខ្ញុំឈ្មោះ ភេទ ស្រី អាយុ ៣២ ឆ្នាំ ជនជាតិ ខ្មែរ មុខរបរ មេផ្ទះ មានទីលំនៅបច្ចុប្បន្ន ភូមិព្រែកហូរខាងកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ។

**សូមគោរពចូលមក**
**លោកប្រធានតុលាការដំបូងខេត្តកណ្ដាល**

*សូមទានជ្រាប*។

**កម្មវត្ថុ** : សុំប្ដឹងផ្ដាច់អនិតិសង្វាសពីប្ដីឈ្មោះ ហៅ ភេទ ប្រុស អាយុ ៣៩ ឆ្នាំ មុខរបរ ធ្វើអាជីវកម្ម មានទីលំនៅភូមិព្រែកហូរខាងកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ។

**ការទាមទារ** : -សុំប្ដឹងឈប់រស់នៅ និង ផ្ដាច់អនិតិសង្វាសពីឈ្មោះ ហៅ ។
-សុំសិទ្ធគ្រប់គ្រងកូនចំនួន ០៣នាក់ ស្រី០២នាក់ ប្រុស០១នាក់ ។
-សុំប្រាក់ចិញ្ចឹមកូនចំនួន ៥ម៉ឺនដុល្លា និង ផ្ទះល្វែងមួយកន្លែង ។

**អង្គហេតុ** : នាងខ្ញុំ និង ឈ្មោះ ហៅ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាំងពីថ្ងៃទី............ខែ.............ឆ្នាំ១៩៩៦ រហូតមកម្ល៉េះដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ ទៅតាមច្បាប់ នៅឡើយទេ រហូតបានកូន ចំនួន០៣នាក់ រស់នៅក្នុងបន្ទុក ការរស់នៅកន្លងមកនេះពុំសូវចុះសម្រុងនឹងគ្នាទេ គឺគាត់បែកគំនិតទៅមានស្រី រហូតដល់នាងខ្ញុំទ្រាំលែងបាន រហូតនាងខ្ញុំទៅទាន់មានការវាយតប់គ្នាជាមួយស្រីគាត់ទៀតផង ហើយនៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១០ នោះឈ្មោះ បានចុះចោលផ្ទះអស់រយៈពេលមួយខែ ពេលចូលមកផ្ទះម្ដងៗរករឿងវាយប្រពន្ធកូន ចាប់នាងខ្ញុំបោចសក់ក្របួច និង ទះកំភ្លៀងទៀតផង គាត់ភ័យប្រមូលឯកសារលិខិតស្នាមរបស់នាងខ្ញុំ និង កូនទៅបាត់អស់ទៀត។ ប៉ុន្តែនៅយប់ថ្ងៃ ទី៣១ ខែ សីហា ឆ្នាំ ២០១០ បានមករករឿងនាងខ្ញុំ ហើយបានវាយផ្ទះសំបែងខ្ទិចខីអស់មិនដឹងមានមូលហេតុអ្វី ដោយនាងខ្ញុំ ស៊ូទ្រាំយូរមកហើយ នៅពេលនេះនាងខ្ញុំដាច់ចិត្តសុំប្ដឹងផ្ដាច់អនីតិសង្វាស ពីឈ្មោះ ចាប់ពីពេលនេះតទៅ ។

**តស្តុតាង** : -មានសៀវភៅស្នាក់នៅ
-សំបុត្របញ្ជាក់កំណើត
-រូបថតអាពាហ៍ពិពាហ៍មួយចំនួន

អាស្រ័យដូចបានជម្រាបជូនខាងលើសូម លោកប្រធានមេត្តាជួយទទួលដោះស្រាយឱ្យនាងខ្ញុំដោយក្ដីអនុគ្រោះ ។

សូមលោកមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

ធ្វើនៅកណ្ដាល.ថ្ងៃទី..០៦...ខែ...កញ្ញា......ឆ្នាំ ២០១០

**ស្នាមមេដៃស្ដាំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

-*-

បង់ពន្ធរួច

**<u>ពាក្យសុំបញ្ចូលសំណុំរឿង</u>**

ខ្ញុំបាទឈ្មោះ ភេទប្រុស អាយុ ៣២ ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ។

**សូមគោរពជូនមក**

**លោកប្រធានសាលាដំបូងខេត្តកណ្ដាល**

**<u>សូមជ្រាប</u>** ។

**<u>កម្មវត្ថុ</u> : សុំបញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី ០៩-២០១០ មក**

**សំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី ០៦-២០១០ វិញ ។**

តាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបជូនលោកប្រធានមេត្តាជ្រាបថា : សំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី ០១០ ដែលមានចៅក្រមលោក កំពុងចាត់ការបានដំណើរការនីតិវិធីត្រៀមចំនួនពីរលើកហើយដែលសំណុំរឿងរដ្ឋប្បវេណីលេខ១៩២ ចុះថ្ងៃទី -២០១០ បានចុះបញ្ជីមុនសំណុំរឿងរដ្ឋប្បវេណីលេខ. ចុះថ្ងៃទី ២០១០ ដែលនៅលោកចៅក្រម កំពុងចាត់ការដែរ ។

ម្យ៉ាងវិញទៀតសំណុំរឿងទាំងពីរនេះ ជាសំណុំរឿងដែលមានកម្មវត្ថុ : សុំ<u>លែងលះ និងបែងចែកទ្រព្យដូចគ្នា</u> ខ្ញុំបាទស្នើសុំលោកប្រធានមេត្តាចាត់បញ្ចូលសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី ០៧-០៩-២០១០ ក្រោយនេះ មកសំណុំរឿងរដ្ឋប្បវេណីលេខ: ុះថ្ងៃទី ២៣-០៦-២០១០ មុនដែលមានលោកចៅក្រម កំពុងចាត់ការតាមនីតិវិធី ។

សូមលោក **ប្រធាន** ពិនិត្យ និងបញ្ចូលដោយក្ដីអនុគ្រោះ ។

-ក្រែងពុំពិតខ្ញុំបាទ-សូមផ្ដិតមេដៃស្ដាំទុកជាភស្ដុតាង ។

ធ្វើនៅ*កណ្ដាល*. ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១០

ស្នាមមេដៃស្ដាំ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

# ដីកាសម្រេច

ដីកាសម្រេចលេខ: (ល)

ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ **យើង** ចៅក្រមសាលាដំបូងខេត្តកណ្តាល។

- បានឃើញ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ: ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៧។
- បានឃើញ មាត្រា៩៥០, មាត្រា៩៧២, មាត្រា៩៧៣, មាត្រា៩៧៤,មាត្រា៩៧៦, មាត្រា៩៧៩, មាត្រា៩៨០, មាត្រា ១០៤១ និងមាត្រា១០៤២ នៃក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ: ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧។
- បានឃើញ មាត្រា២២, មាត្រា២៦ និងមាត្រា៣៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ: ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០។
- បានឃើញ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ: ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។
- បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១០ ។
- បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១០ ។
- បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១០ របស់ឈ្មោះ (ដើមចោទ)។
- បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១០ របស់ឈ្មោះ (ដើមចោទ)។
- បានឃើញ សេចក្តីសម្រេចបញ្ចូលរឿងក្តីលេខ:០៧ ដកសបចុះថ្ងៃទី២០ ខែ០១ ឆ្នាំ២០១១ របស់ចៅក្រម ។
- បានឃើញ លិខិតបញ្ជាក់លេខ: ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ របស់មេឃុំព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ។
- បានឃើញ កិច្ចសន្យាលែងលះគ្នារបស់គូភាគី ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០១៣ ។
- បានឃើញ កំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ ២០១០ និងចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០ របស់ចៅក្រម ។
- បានឃើញ កំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ និងចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣។
- បានឃើញ ការសំណូមពររបស់ឈ្មោះ ភេទប្រុស អាយុ៣២ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ ព្រែកហូរ ... ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល និងចុងចម្លើយឈ្មោះ ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិព្រែកហូរ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ព្រែកហូរ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១៣ ។

<u>កម្មវត្ថុ:</u> ប្តឹងសុំលែងលះប្រពន្ធ

## សំអាងហេតុ:

១. យល់ឃើញថា ពាក្យបណ្តឹងសុំលែងលះ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១០ និងចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១០ របស់គូភាគីមានលក្ខណៈត្រឹមត្រូវតាមមាត្រា ២៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីដែលមិនមែនជាបណ្តឹង។

២. យល់ឃើញថា លិខិតបញ្ជាក់លេខ: ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ របស់ចៅសង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ឃើញថា:ឈ្មោះ ភេទប្រុស អាយុ ៣២ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ៣១ឆ្នាំ គឺជាសហព័ន្ធនឹងគ្នាដែលបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។

៣. យល់ឃើញថា លិខិតសំណូមពរ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ របស់គូភាគីឈ្មោះ និងឈ្មោះ ដែលស្នើសុំឲ្យតុលាការសម្រេចលែងលះតាមការព្រមព្រៀងរបស់គូភាគីមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៤. យល់ឃើញថា តាមការអះអាងរបស់ដើមចោទឈ្មោះ ថាខ្លួននិងឈ្មោះ ពិតជាបានរៀបការនឹងគ្នាជាប្តីប្រពន្ធតាំងពីឆ្នាំ១៩៨៦ មកម្លេះ ក្រោយពីបានរៀបអាពាហ៍ពិពាហ៍និងគ្នាមកការរស់នៅមិនចុះសម្រុងនិងគ្នា គឺតែងតែមានទំនាស់នឹងគ្នាជាញឹកញ៉ាប់ និងមិនទុកចិត្តគ្នាទៅវិញទៅមកទើបធ្វើឲ្យពួកខ្លួនអស់មនោសញ្ចេតនានិងគ្នា។ លុះដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣ ក៏បានឯកភាពធ្វើកិច្ចសន្យាលែងលះនិងចែកទ្រព្យសម្បត្តិតាមការព្រមព្រៀងគ្នាដោយពុំមានអ្នកណាបង្ខិតបង្ខំឡើយ។

៥. យល់ឃើញថា តាមការអះអាងរបស់គូភាគីឃើញថា: មានកូនចំនួន ០៣ នាក់ គឺ១.ឈ្មោះ ភេទស្រី កើតឆ្នាំ១៩៨៧ កូនទី២ ភេទស្រីកើតឆ្នាំ១៩៨៨ និងទី៣.ឈ្មោះ ភេទប្រុសកើតឆ្នាំ២០០២ ស្របទៅនឹងសំបុត្របញ្ជាក់កំណើតរបស់មន្ត្រីអត្រានុកូលដ្ឋាន សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ដែលចំណុចនេះអាចឲ្យតុលាការជឿរបាន។

៦. យល់ឃើញថា ពេលរស់នៅជាមួយគ្នាគូភាគីមានកូនចំនួន០៣នាក់គឺ កូនទី១.ឈ្មោះ ភេទស្រី កើតឆ្នាំ១៩៨៧ កូនទី២ .ឈ្មោះ ភេទស្រីកើតឆ្នាំ១៩៨៨ និងទី៣.ឈ្មោះ ភេទប្រុសកើតឆ្នាំ២០០២ ដោយគូភាគីបានព្រមព្រៀងគ្នាគឺឈ្មោះ ទទួលយកកូនចំនួន០២នាក់ កូនទី១.ឈ្មោះ ភេទស្រីកើតឆ្នាំ១៩៨៧ កូនទី២.ឈ្មោះ ភេទស្រីកើតឆ្នាំ១៩៨៨ រីឯភាគីចុងចម្លើយឈ្មោះ ព្រមទទួលយកកូន១នាក់គឺឈ្មោះ ភេទប្រុសកើតឆ្នាំ២០០២ ដើម្បីគ្រប់គ្រងនឹងថែរក្សា អប់រំរៀងៗខ្លួនតាមការព្រមព្រៀង។សំបុត្រ

៧. យល់ឃើញថា ភាគីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ ប៉ុន្តែគូភាគីមានសៀវភៅគ្រួសារលេខ ចុះហត្ថលេខាដោយលោកស្នងការខេត្តកណ្តាល ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១២ ដែលបញ្ជាក់ថា ជាមេគ្រួសារ ឈ្មោះ ជាប្រពន្ធ និងមានកូន០៣ នាក់ គឺឈ្មោះ ភេទស្រី អាយុ១៥ឆ្នាំ ,ឈ្មោះ ភេទស្រី អាយុ១៤ឆ្នាំ និងឈ្មោះ ភេទប្រុស អាយុ១១ឆ្នាំ ដែលនេះបង្ហាញថា គូភាគីបានរស់នៅជាមួយគ្នាជាប្តី-ប្រពន្ធដោយអទីតិសង្វាស ដូច្នេះតុលាការពិចារណាតាមច្បាប់។

៨. យល់ឃើញថា តាមការអះអាងរបស់គូភាគី ទ្រព្យសម្បត្តិរួមដែលមានទាំងអស់ ដែលគូភាគីបានបែងចែកគ្នាអស់ហើយ និងបានសំណូមពរដល់តុលាការមិនបាច់ឲ្យលើកយកមកសម្រេចទៀតទេ គឺទទួលតាមការព្រមព្រៀងអស់ហើយ ដែលចំណុចនេះតុលាការមិនលើកមកសម្រេចទេ។

៩. យល់ឃើញថា តាមកំណត់ហេតុត្រៀមទាញហេតុផល ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣ មកឃើញថា: ភាគីដើមចោទឈ្មោះ និងភាគីចុងចម្លើយឈ្មោះ បានព្រមព្រៀងលែងលះគ្នានឹងបែងចែកកូន និងទ្រព្យសម្បត្តិ ដោយស្ម័គ្រចិត្ត ពុំមានអ្នកណាបង្ខំអ្នកណាឡើយ ដែលចំណុចនេះតុលាការ និងសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

១០. បានឃើញ មាត្រា ៩៥០ , មាត្រា ៩៧២ , មាត្រា ៩៧៣ , មាត្រា ៩៧៤ ,មាត្រា ៩៧៨ ,មាត្រា ៩៧៩ និង មាត្រា ៩០៨ នៃក្រមរដ្ឋប្បវេណី និងមាត្រា ០៣ , មាត្រា ៣៥ , មាត្រា ៣៦ និងមាត្រា ៤០ នៃនីតិវិធីរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង។

## <u>ហេតុដូច្នេះសម្រេច</u>

១. ឲ្យដើមចោទឈ្មោ ដាច់អនីតិសង្វាសពីចុងចម្លើយឈ្មោះ តាមការព្រមព្រៀងរបស់គូភាគី គិតពីថ្ងៃដីកាសម្រេចនេះចូលជាស្ថាពរតទៅ។

២. ប្រគល់កូនឈ្មោះ

- ភេទស្រី ១៥ឆ្នាំ
- ភេទស្រី ភេទស្រី ១៤ឆ្នាំ

ឲ្យដើមចោទឈ្មោះ គ្រប់គ្រងបីបាច់ថែរក្សានឹងអប់រំ។

- ប្រគល់កូនឈ្មោះ ភេទប្រុស អាយុ១១ឆ្នាំ ឲ្យចុងចម្លើយឈ្មោះ គ្រប់គ្រងបីបាច់ថែរក្សានឹងអប់រំ។

គូភាគីត្រូវបង្ករលក្ខណៈងាយស្រួលក្នុងការចូលសួរសុខទុក្ខ និងឧបត្ថមដល់កូនបានគ្រប់ពេលវេលា។

៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមចោទឈ្មោះ ។

-បើកផ្លូវប្តឹងជំទាស់ នឹងដីកាសម្រេចនេះក្នុងរយះពេល ២សប្តាហ៍ គិតពីថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេចនេះ។/.

**ចៅក្រម**

**ហត្ថលេខា និងត្រា**

(បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម)។

កណ្តាលថ្ងៃទី០៣ខែឧសភា ឆ្នាំ២០១៣

**ក្រឡាបញ្ជី**

**បានឃើញ**

កណ្តាលថ្ងៃទី.០៣.ខែឧសភា ឆ្នាំ២០១៣

**ចៅក្រម**

ចៅក្រម.

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

*******

**ក្នុងនាមប្រជារាស្ត្រខ្មែរ**

សាលាដំបូងខេត្តកណ្ដាល បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់

នៅថ្ងៃទី ដោយមានសមាសភាពដូចខាងក្រោម :

សំណុំរឿងរដ្ឋប្បវេណីលេខ

**ចៅក្រម**

-កាលបរិច្ឆេទប្រកាសសាលក្រម -លោក ចៅក្រមសាលាដំបូង ខេត្តកណ្ដាល

**ក្រឡាបញ្ជី**

-សាលក្រមលេខ -លោក ក្រឡាបញ្ជីសាលាដំបូង ខេត្តកណ្ដាល

**- ដើមចោទ** : ឈ្មោះ ភេទស្រីថ្ងៃខែឆ្នាំកំណើត០៦-០២-១៩៥២ ជាតិខ្មែរ សាសនា ព្រះពុទ្ធ កើតនៅ ខេត្តកណ្ដាល របររកស៊ីដេរប៉ាក់ មានទីលំនៅសព្វថ្ងៃ ខេត្តកណ្ដាល ទោសពីមុនគ្មាន។ ប្ដីឈ្មោះ (រ) មានកូន ០១ នាក់ ឪពុកឈ្មោះ (រ) ម្ដាយឈ្មោះ (រ)។

-អ្នកតំណាងដោយអណត្តិ (គ្មាន)។

**-ចុងចម្លើយ** : ឈ្មោះ ភេទប្រុសថ្ងៃខែឆ្នាំកំណើត២៨-១០-១៩៨០ ជាតិខ្មែរ សាសនាព្រះពុទ្ធ កើតនៅ ង ខេត្តពោធិសាត់ មុខរបរបុគ្គលិកអង្គការវីសិនហ្វាន់ មានទីលំនៅសព្វថ្ងៃ ខេត្តកណ្ដាល ទោសពីមុនគ្មាន ។ ប្រពន្ធឈ្មោះ (រ) មានក០១នាក់ឪពុក ឈ្មោះ (រ) ម្ដាយឈ្មោះ (រ)។

-អ្នកតំណាងដោយអណត្តិ (គ្មាន)។

**<u>អង្គហេតុ</u>**

តាមពាក្យបណ្ដឹងចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០១០ របស់ដើមចោទឈ្មោះ បានបញ្ជាក់ថា : ខ្លួនប្ដឹងសុំឱ្យតុលាការចេញសាលក្រមឱ្យខ្លួនបានលែងលះពីប្ដីឈ្មោះ . សុំសិទ្ធិបីបាច់ថែរក្សាកូនឈ្មោះ ភេទប្រុសថ្ងៃខែឆ្នាំកំណើត១០-០៣-២០០៩ និងសុំនិងសុំបែងចែកទ្រព្យសម្បត្តិរួមតាមច្បាប់។ ដោយហេតុថាក្នុង រយៈពេលរួមរស់ជាមួយគ្នា ខ្លួននិងប្ដីឈ្មោះ រស់នៅមិនចុះសម្រុងនិងគ្នាទេ ដោយមាន ការឈ្លោះទាស់ទែងគ្នាជាញឹកញាប់ ម្យ៉ាងទៀតប្ដីខ្លួនមិនគោរពឪពុកម្ដាយខ្លួនធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាមិនអាចរស់នៅជាប្ដីប្រពន្ធតទៅទៀតបានឡើយ។

ខ្លួននិងប្ដីបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី០៦ ខែ០១ឆ្នាំ២០០៨ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។ ក្នុងរយៈពេលរួមរស់ជាប្ដីប្រពន្ធ ពួកខ្លួនមានកូន០១នាក់ឈ្មោះ ភេទប្រុសថ្ងៃខែឆ្នាំកំណើត១០-០៣-២០០៩ សព្វថ្ងៃខ្លួនជាអ្នកគ្រប់គ្រងបីបាច់ថែរក្សា ឯទ្រព្យសម្បត្តិរួមមាន : ដីពីរកន្លែង ។មួយកន្លែង មានទំហំ០៥ម x ១៧ម ស្ថិតនៅភូមិទួលក្រសាំង ឃុំរការខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល ជាប្រភេទដីឡូត៍លំនៅដ្ឋាន (ទិញក្នុងតំលៃ៣០០០ដុល្លាអាមេរិក) មួយកន្លែង

ទៀតទំហំ ស្ថិត ។ ខេត្តកណ្តាល ជាប្រភេទដីស្រែ (ទិញតំលៃ ១៣០០ ដុល្លាអាមេរិក) ។

**<u>ចំណុចវិវាទ</u>**

**.ការទាមទារដោយដើមចោទ :** ប្តឹងសុំឱ្យតុលាការចេញសាលក្រម ដូចខាងក្រោម :

.ឱ្យតុលាការសម្រេចឱ្យខ្លួនបានលែងលះពីប្តីឈ្មោះ តាមច្បាប់ ។

- សុំសិទ្ធិបីបាច់ថែរក្សាកូនឈ្មោះ ភេទប្រុសថ្ងៃខែឆ្នាំកំណើត១០-០៣-២០០៩។

-សុំបែងចែកទ្រព្យសម្បត្តិរួមតាមច្បាប់ ។

**<u>ដំណាក់កាលទាញហេតុផលដោយផ្ទាល់មាត់</u>**

**.ការពន្យល់ព្រួសៗអំពីរឿងក្តី :**

**.ការពន្យល់ព្រួសៗរបស់ដើមចោទឈ្មោះ** : ខ្លួននៅតែប្តឹងសុំលែងលះប្តីដដែល ដោយហេតុថាការរួមរស់ជាមួយគ្នាមិនចុះសម្រុងនឹងគ្នាទេ ដោយមានការឈ្លោះទាស់ទែងគ្នាជាញឹកញាប់ ម្យ៉ាងទៀតប្តីខ្លួនមិនគោរពឪពុកម្តាយខ្លួន ធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាក្នុងការរស់នៅជាប្តីប្រពន្ធតទៅទៀត ។

ខ្លួននិងប្តីបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី០៦ខែ០១ ឆ្នាំ២០០៨ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។

ក្នុងរយ:ពេលរួមរស់ជាប្តីប្រពន្ធ ពួកខ្លួនមានកូន០១នាក់ឈ្មោះ ភេទប្រុសថ្ងៃខែឆ្នាំកំណើត១០-០៣-២០០៩ សព្វថ្ងៃខ្លួនជាអ្នកគ្រប់គ្រងបីបាច់ថែរក្សា ។

ចំពោះកូន ខ្លួនសុំឱ្យតុលាការសម្រេចប្រគល់សិទ្ធិបីបាច់ថែរក្សា ដោយមិនទាមទារអាហារកិច្ចចិញ្ចឹមកូនឡើយ ព្រោះខ្លួនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំ អោយកូនមានអនាគតល្អ ។ សព្វថ្ងៃខ្លួនមានមុខរបរជាជាងដេរបាក់បើករកស៊ីនៅផ្ទះខ្លួនផ្ទាល់មាន ចំណូលនិងពេលវេលាគ្រប់គ្រាន់ អាចចិញ្ចឹមនិងមើលថែកូនបានយ៉ាងជិតដល់ ឯចុងចម្លើយ មានទីលំនៅឯខេត្តពោធិ៍សាត់ហើយមកធ្វើការនៅឆ្ងាយឯខេត្តតាកែវ មិនអាចមានពេលវេលាគ្រប់គ្រាន់មើលថែរក្សាកូនបានឡើយ ។

ទ្រព្យសម្បត្តិរួមមាន : ដីពីរកន្លែង ។មួយកន្លែងមានទំហំ

ខេត្តកណ្តាល ជាប្រភេទដីឡូត៍លំនៅដ្ឋាន(ទិញក្នុងតំលៃ៣០០០ដុល្លាអាមេរិក)មួយកន្លែងទៀតទំហំ០

ខេត្តកណ្តាល ជាប្រភេទដីស្រែ (ទិញតំលៃ ១៣០០ ដុល្លាអាមេរិក) ។ ឯបំណុលគ្មានទេ

ទ្រព្យសម្បត្តិដើមក៏គ្មានទេ ។

ក្នុងរឿងនេះខ្លួនមានសំនូមពរ សុំឱ្យតុលាការចេញសាលក្រមឱ្យខ្លួន បានលែងលះពីប្តីឈ្មោះ តាមច្បាប់. សុំសិទ្ធិគ្រប់គ្រងបីបាច់ថែរក្សាកូនឈ្មោះ ភេទប្រុសថ្ងៃខែឆ្នាំកំណើត១០-០៣-២០០៩ ដោយមិនទាមទារអាហារកាតព្វកិច្ចចិញ្ចឹមកូន និងសុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើរគ្នា គឺដីពីរកន្លែង។ មួយកន្លែង

ខេត្តកណ្តាល ជាប្រភេទដីឡូត៍លំនៅដ្ឋាន (ទិញក្នុងតំលៃ៣០០០ ដុល្លាអាមេរិក) មួយកន្លែងទៀត ទាំភូមិ ។ ខេត្តកណ្តាល ជាប្រភេទដីស្រែ(ទិញតំលៃ ១៣០០ ដុល្លាអាមេរិក) ។

ស្តីពីការអះអាងរបស់ខ្លួនខាងលើ ខ្លួនមានភស្តុតាងជូនតុលាការពិនិត្យដូចខាងក្រោម :

-សំបុត្រអាពាហ៍ពិពាហ៍លេខ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០០៨។

-សំបុត្រកំណើតកូនលេខ ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ២០០៥។

-សំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ ២០០៤។

- សំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៥។

-កិច្ចសន្យាលក់ផ្ដាច់ដីចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៨។

-កិច្ចសន្យាលក់ផ្ដាច់ដីចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ២០០៨ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ ២០០៨។

**.តាមចម្លើយរបស់ចុងចម្លើយឈ្មោះ ក្នុងនីតិវិធីត្រៀមទាញហេតុផលលើកទី១ និងលើកទី២ បាន ឆ្លើយថា:** ក្នុងរឿងនេះខ្លួនមិនឯកភាពលែងលះតាមការ ប្ដឹងសុំរបស់ ប្រពន្ធខ្លួនទេ ដោយហេតុថា ខ្លួននៅតែស្រឡាញ់ប្រពន្ធ កូនខ្លួនដដែល ។ ម៉្យាងទៀតមូលហេតុដែលដើមចោទ បានលើកឡើងខ្លួន មិនអាចទទួលយកបានទេ។

ការរស់នៅជាមួយគ្នានាពេលកន្លងមកមានជម្លោះជាមួយគ្នាម្ដងម្កាលមែន ។ក្នុងរយៈពេលរួមរស់ជាមួយគ្នាពីរឆ្នាំនេះមាន ជម្លោះជាមួយគ្នាប្រហែលប្រាំដងដោយពាក្យសម្ដីតែប៉ុណ្ណោះ ពុំមានអំពើហិង្សាទេ។

ចំពោះកូនខ្លួនមិនឯកភាពតាមការទាមទាររបស់ដើមចោទទេ ព្រោះខ្លួនក៏ទាមទារសិទ្ធិគ្រប់គ្រងបីបាច់ថែរក្សាកូនដែរ ដោយខ្លួនមិនទាមទារអាហារកាតព្វកិច្ចចិញ្ចឹមកូនឡើយហើយខ្លួនសុខចិត្តប្រគល់ទ្រព្យសម្បត្តិរួមទាំងអស់ឱ្យដើមចោទទៀតផង បើដើមចោទសុខចិត្តប្រគល់កូនឱ្យខ្លួនគ្រប់គ្រងបីបាច់ថែរក្សាកូន។

ខ្លួនគ្មានភស្តុតាងដាក់ជូនតុលាការពិនិត្យទេ។

*-ក្រោយពីបានស្ដាប់សេចក្ដីថ្លែងការណ៍របស់ដើមចោទ*

*-ក្រោយពីបានស្ដាប់សេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ*

**ក្រោយពីបានពិនិត្យភស្តុតាងនិងឯកសារនានា និង ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**<u>សាលាដំបូងខេត្តកណ្ដាល</u>**

**<u>យល់ឃើញថា</u> :**

តាមលទ្ធផល នៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងក្នុងនីតិវិធី ត្រៀមទាញហេតុផល ឃើញថា:

-ពាក្យបណ្ដឹងចុះថ្ងៃ ) និងសំណូមពរនៅចំពោះមុខសវនាការ របស់ដើមចោទឈ្មោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់។

-ដើមចោទបានសំណូមពរប្ដឹងសុំដាច់សមគ្គសង្វាសពីប្ដីឈ្មោះ នោះគប្បីសាលាដំបូងខេត្តកណ្ដាល ពិចារណា សម្រេច លើកយកបណ្ដឹងនេះមកធ្វើការទាញហេតុផលដោយផ្ទាល់មាត់បានស្របតាមមាត្រា៤១ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

-គូភាគីពិតជាបានរៀបអាពាហ៍ពិពាហ៍ ត្រឹមត្រូវតាមច្បាប់និងប្រពៃណីជាតិដូចមានសំបុត្រអាពាហ៍ពិពាហ៍លេខ សៀវភៅអាពាហ៍ពិពាហ៍លេខ ដែលបញ្ជាក់ឱ្យឃើញថា គូភាគីពិតជាប្ដីប្រពន្ធមាន នីតិសង្វាសដែលអាច ឱ្យតុលាការពិចារណាលើកយកបណ្ដឹងសុំលែងលះមកធ្វើការទាញហេតុផល បានតាមមាត្រា៣៨ ច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ។

-ចម្លើយរបស់ដើមចោទឈ្មោះ ខ្លួននៅតែប្តឹងសុំលែងលះប្តីឈ្មោះ ដដែល ដោយហេតុថាការរួមរស់ជាមួយគ្នាមិនចុះសម្រុងទេ ដោយមានការឈ្លោះទាស់ទែងគ្នាជាញឹកញាប់ ម្យ៉ាងទៀតប្តីខ្លួនមិនគោរពឪពុកម្តាយ ខ្លួន ធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាក្នុងការរស់នៅជាប្តីប្រពន្ធតទៅទៀត នោះគប្បីតុលាករពិនិត្យ ពិចារណាសម្រេចតាមច្បាប់ ។

-តាមចម្លើយចុងចម្លើយឈ្មោះ បានបញ្ជាក់ថា : ការប្តឹងសុំលែងលះរបស់ប្រពន្ធខ្លួននោះខ្លួនមិន ឯកភាពតាមការប្តឹងសុំទេ ដោយហេតុថាខ្លួននៅតែស្រឡាញ់ប្រពន្ធនិងកូនដូចដើម តែខ្លួនទទួលស្គាល់ថា ការរស់នៅពិតជាមិនចុះ សម្រុងនិងគ្នាប្រាកដមែន ដោយមានជម្លោះដោយពាក្យសំដីជាមួយគ្នាប្រហែលប្រាំដងប៉ុណ្ណោះ ចម្លើយនេះមានលក្ខណៈស៊ីសង្វាក់ទៅនឹងចម្លើយដើមចោទដែលបានអះអាងថាខ្លួនប្តឹងលែងលះពីប្តីដោយរស់នៅមិនចុះសម្រុង និង អស់មនោសញ្ចេតនា ក្នុងការរស់នៅជាប្តីប្រពន្ធជាមួយគ្នាតទៅទៀត នោះឃើញថាគូភាគីមិនអាចរួមរស់ជាមួយគ្នា ដោយមានអនាគតល្អបានឡើយ ។

-ចំណងអាពាហ៍ពិពាហ៍របស់គូភាគីលែងបានសម្រេចហើយ ដោយគូភាគីអស់មនោសញ្ចេតនានិងគ្នា ហើយបានសុំលែងលះដោយពិតប្រាកដ គ្មានការបង្ខិតបង្ខំពីភាគីឬពីតតីយជនណាមួយឡើយ នោះគប្បីតុលាការពិចារណាសម្រេចតាមមាត្រា ៤០ និង មាត្រា ៩៨ នៃច្បាប់អាពាហ៍ ពិពាហ៍ និងគ្រួសារ ។

-ក្នុងចំណងអាពាហ៍ពិពាហ៍ សហព័ទ្ធទាំងពីរមានកូន០១នាក់ឈ្មោះ ភេទប្រុសថ្ងៃខែឆ្នាំកំណើត ១០-០៣-២០០៩ ដើមចោទឈ្មោះ បានទាមទារសិទ្ធិគ្រប់គ្រងបីបាច់ថែរក្សា ដោយមិនទាមទារអាហារកាតព្វកិច្ចចិញ្ចឹមកូនពីប្តីទេ ឯចុងចម្លើយឈ្មោះ ក៏បានទាមទារសិទ្ធិគ្រប់គ្រងបីបាច់ថែរក្សាកូនដែរ ដោយខ្លួនមិនទាមទារអាហារកាតព្វកិច្ចចិញ្ចឹមកូនឡើយ ហើយខ្លួនសុខចិត្តប្រគល់ទ្រព្យសម្បត្តិរួមទាំងអស់ ឱ្យដើមចោទទៀតផងចំនុចនេះ តុលាការយល់ឃើញថា កូនឈ្មោះ ភេទប្រុសថ្ងៃខែឆ្នាំ កំណើត ១០-០៣-២០០៩ ជាកុមារដែលមានវ័យ ក្មេងអាយុទើបតែបាន០១ឆ្នាំ ០៤ខែ កំពុងបៅដោះនៅឡើយ ដែលត្រូវការបីបាច់ថែរក្សាជាចាំបាច់ពីសំណាក់ម្តាយ ហេតុនេះគប្បីតុលាការពិចារណាសម្រេចប្រគល់សិទ្ធិឱ្យដើមចោទឈ្មោះ ជាអ្នកគ្រប់គ្រងបីបាច់ថែរក្សាកូនតទៅតាមមាត្រា៧៣ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ ។

-ចុងចម្លើយជាភាគីមិនបានសិទ្ធិរក្សាកូន គប្បីតុលាការពិចារណាសំរេចទុកសិទ្ធិក្នុងការប្រាស្រ័យទាក់ទង និង សួរសុខ ទុក្ខកូន ។ ភាគីដើមចោទដែលទទួលបានសិទ្ធិរក្សាកូនត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីចុងចម្លើយ តាមមាត្រា៧៥ វាក្យខ័ណ្ឌ១ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

-ដើមចោទឈ្មោះ បានទាមទារសិទ្ធិគ្រប់គ្រងបីបាច់ថែរក្សាកូន ដោយមិនទាមទារអាហារ កាតព្វកិច្ចចិញ្ចឹមកូន ទេ ហេតុនេះតុលាការពុំចាំបាច់លើកយកបញ្ហានេះមកពិចារណាឡើយ ។

-ដើមចោទឈ្មោះ មានវ័យ១៨ឆ្នាំ ដែលជាស្ត្រីនៅមានវ័យក្មេងអាចមានលទ្ធភាពក្នុងការ មានកូនបាន ហេតុនេះគប្បីតុលាការពិចារណាសម្រេច ទុករយៈពេលវិធវភាព(ភាពមេម៉ាយ)រយៈពេល៣០០ថ្ងៃតាម មាត្រា៩នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

-តាមចម្លើយរបស់ដើមចោទក៏ដូចជាចម្លើយរបស់ចុងចម្លើយបានបញ្ជាក់ថា ក្នុងចំណងអាពាហ៍ពិពាហ៍ពួក ខ្លួនទិញបានដីពីរកន្លែង។ មួយកន្លែងមានទំហំ ... ត្ត កណ្តាល ជាប្រភេទដីឡូត៍លំនៅដ្ឋាន (ទិញក្នុងតំលៃ៣០០០ដុល្លាអាមេរិក) មួយកន្លែងទៀតទំហំ ... រ ស្ថិតនៅភូមិកោះខ្នុរ ឃុំព្រែករកា

ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ជាប្រភេទដីស្រែ (ទិញតំលៃ ១៣០០ដុល្លាអាមេរិក) នោះឃើញថាដីទាំងពីរកន្លែងនេះជាទ្រព្យសម្បត្តិរួមរបស់គូភាគី គប្បីតុលាការពិចារណាសម្រេចបែងចែកជាពីរ ចំណែកពាក់កណ្តាលស្មើគ្នាទៅឱ្យដើមចោទ និង ចុងចម្លើយ តាមមាត្រា ៧០ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

-ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ភាគីចុងចម្លើយ ។

## **<u>សេចក្តីសម្រេចបញ្ចប់</u>**

១ ឱ្យដើមចោទឈ្មោះ និងចុងចម្លើយឈ្មោះ ដាច់សមគ្គសង្វាសពីគ្នាចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរតទៅតាមមាត្រា ៤០ និងមាត្រា ៥៨ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

២.ឱ្យឈ្មោះ ស្ថិតនៅក្នុងវិធវភាព (ភាពមេម៉ាយ) ចំនួន៣០០ថ្ងៃគិតចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរតទៅ អនុលោមតាមមាត្រា០៩ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៣.កូនឈ្មោះ ភេទប្រុសថ្ងៃខែឆ្នាំ កំណើត១០-០៣-២០០៩ ត្រូវប្រគល់ឱ្យដើមចោទឈ្មោះ គ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សា គិតចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរតទៅតាមមាត្រា ៧២ និង មាត្រា៧៣ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

-ទុកសិទ្ធឱ្យភាគីចុងចម្លើយឈ្មោះ ដែលជាភាគីមិនបានសិទ្ធិរក្សាកូនក្នុងការប្រាស្រ័យទាក់ទង និង សួរសុខទុក្ខកូន តាមមាត្រា៧៥ វាក្យខ័ណ្ឌ១ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៤.ទ្រព្យសម្បត្តិរួមមាន: ដីពីរកន្លែង មួយកន្លែងមានទំហំ ស្ថិតនៅភូ
ខេត្តកណ្តាល ជាប្រភេទដីឡូត៍លំនៅដ្ឋានមួយកន្លែងទៀតទំហំ ស្ថិតនៅភូ
ខេត្តកណ្តាល ជាប្រភេទដីស្រែ ត្រូវបែងចែកជាពីរចំណែកពាក់កណ្តាលស្មើគ្នា ឱ្យទៅដើមចោទឈ្មោះ និងចុងចម្លើយឈ្មោះ គ្រប់គ្រងកាន់កាប់ជាកម្មសិទ្ធិ គិតចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរតទៅ អនុលោមតាមមាត្រា៧០ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ ។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ ។

៦.សាលក្រមនេះធ្វើការទាញហេតុផលដោយផ្ទាល់មាត់និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ តែចាត់ទុកជាចំពោះមុខនៅថ្ងៃទី១៥ខែកក្កដា ឆ្នាំ២០១០ ។

-ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា

---

បានឃើញ

**ចៅក្រម**

អនុសារៈសាលក្រមនេះមានអានុភាពដូចសាលក្រមដើមដែរ ។

កណ្តាល ថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០១០

**ក្រឡាបញ្ជី**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមរដ្ឋប្បវេណី

លេខ:

ចុះថ្ងៃទី ខែ ឆ្នាំ២០១៩

សំណុំរឿងរដ្ឋប្បវេណីលេខ

ចុះថ្ងៃទី ខែ ឆ្នាំ២០១៨

## គោរពនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី ខែ ឆ្នាំ ២០១៩ វេលាម៉ោង ៩ ព្រឹក នៅសាលសវនាការទី៤ លើសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០១៨ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

-លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

-លោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-ដើមចោទឈ្មោះ: ភេទស្រី កើតឆ្នាំ ១៩៩១ ជាតិខ្មែរ មានអាសយដ្ឋានស្នាក់នៅភូមិ ខេត្តក្រចេះ ប្ដីឈ្មោះ មានកូនម្នាក់ ។

អ្នកតំណាងដោយអាណត្តិ "ដើមចោទ" ៖ លោកមេធាវី អត្តលេខ

-ចុងចម្លើយឈ្មោះ: ភេទប្រុស កើតឆ្នាំ ១៩៨៣ មុខរបរមន្ត្រីរាជការ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ មានកូនម្នាក់ ។

## I.អង្គហេតុ និងចំណុចវិវាទ:

**១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ**

ដើមចោទបានទាមទារឲ្យសាលាដំបូងរាជធានីភ្នំពេញចេញសាលក្រមដូចតទៅ៖

ក/ឈប់រស់នៅជាអនីតិសង្វាសជាមួយចុងចម្លើយ

ខ/សុំប្រគល់សិទ្ធិគ្រប់គ្រងបីបាច់ថែរក្សាកូនប្រុសឈ្មោះ កើតថ្ងៃទី២១ ខែកក្កដា ឆ្នាំ ២០១៤ ឲ្យមកដើមចោទ ។

គ/បង្គាប់ឲ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រដាប់ក្តី ។

**២.ការពន្យល់ស្រួសៗអំពីរឿងក្តី**

• ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាតាមប្រពៃណី ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់នោះទេ ។ ដោយសារតែការរស់នៅមិនចុះសម្រុងនឹងគ្នា ជាហេតុធ្វើឲ្យគូភាគីអស់មនោសញ្ចេតនាមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ដោយចុងចម្លើយបានចាកចេញពីផ្ទះជាង ៣ ឆ្នាំមកហើយ ទុកឲ្យដើមចោទរស់នៅជាមួយកូន ។ ហេតុនេះដើមចោទបានដាក់ពាក្យប្តឹងសុំឈប់រស់នៅជាអនីតិសង្វាសពីចុងចម្លើយ និងសុំសិទ្ធិគ្រប់គ្រងកូន ។

**៣.អង្គហេតុដែលអះអាងដោយដើមចោទ**

-ដើមចោទឈ្មោះ: បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ ខ្លួននៅតែរក្សាសេចក្តីថ្លែងការណ៍ដូចមានក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទុកដដែល ។ ខ្លួនបានរៀបការ ជាមួយចុងចម្លើយកាលពីថ្ងៃទី១៦

មេសា ឆ្នាំ២០១២ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ ហើយបង្កើតបានកូនប្រុសម្នាក់ឈ្មោះ កើតថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤ ។ ក្រោយមកការរស់នៅជាមួយគ្នា ចាប់ផ្តើមមានភាពមិនចុះសម្រុងនឹងគ្នា ជាហេតុធ្វើឲ្យគូភាគីអស់មនោសញ្ចេតនាមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបាន ហើយបានឈានដល់ការរស់នៅបែកគ្នាអស់រយៈពេលជាង ៣ ឆ្នាំមកហើយ ដោយចុងចម្លើយបានចាកចេញពីផ្ទះទៅរស់នៅខាងក្រៅ ទុកឲ្យកូនប្រុសរស់នៅជាមួយខ្លួនរហូតដល់បច្ចុប្បន្ន ហេតុនេះទើបខ្លួនសុំសិទ្ធិគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សា ដោយមិនទាមទារអាហារកិច្ចចិញ្ចឹមកូនឡើយ ដូចមានក្នុងកិច្ចព្រមព្រៀងលែងលះចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨ ដែលបានដាក់ជូនលោកចៅក្រមរួចហើយ ។ ក្នុងអំឡុងពេលរួមរស់ជាមួយគ្នា ពួកខ្លួនមានទ្រព្យសម្បត្តិរួមដីចំការស្វាយចន្ទីមានទំហំ ៥០ ម៉ែត្រ គុណនឹង ១០០០ ម៉ែត្រ ស្ថិតនៅ ខេត្តក្រចេះ ពួកខ្លួនបានលក់បែងចែកប្រាក់គ្នាអស់ហើយ សុំលោកចៅក្រមមិនបាច់លើកយកមកពិចារណានោះទេ ។ ចំពោះបំណុលរួមគ្មានទេ ។ អាស្រ័យហេតុនេះ សូមលោកចៅក្រមមេត្តាចេញសាលក្រមតាមការប្តឹងសុំដោយក្តីអនុគ្រោះ ។

<u>៤.អង្គហេតុដែលអះអាងដោយចុងចម្លើយ</u>

-ចុងចម្លើយឈ្មោះ ៖ ខ្លួនឯកភាពតាមសេចក្តីរាយការណ៍របស់ភាគីដើមចោទគ្រប់ចំណុចមិនមានជំទាស់អ្វីឡើយ ។

<u>៥. ចំណុចវិវាទ</u> ៖ គ្មាន ។

## II. ការពិនិត្យភស្តុតាង

<u>ភស្តុតាងជាឯកសាររបស់ដើមចោទ</u>

-កិច្ចព្រមព្រៀងលែងលះចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨ រវាងដើមចោទ និងចុងចម្លើយ ។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា ៖

១. តាមការអះអាងរបស់ភាគីដើមចោទបានបញ្ជាក់ថា ភាគីដើមចោទ និងភាគីចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាកាលពីឆ្នាំ២០១២ ប៉ុន្តែគូភាគីពុំបានទៅចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នោះទេ ដូចនេះតាមមាត្រា ៩៥៨ នៃក្រមរដ្ឋប្បវេណីអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរត្រូវចាត់ទុកជាមោឃៈ។

២. ដើមចោទបានប្តឹងសុំឈប់រស់នៅជាអនីតិសង្វាសពីចុងចម្លើយ ដោយសំអាងថាការរស់នៅជាមួយគ្នាមួយរយៈក្រោយនេះ មិនចុះសម្រុងនឹងគ្នា ជាហេតុធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត ហើយចុងចម្លើយបានចាកចេញពីផ្ទះទៅរស់នៅខាងក្រៅ ទុកឲ្យកូនប្រុសរស់នៅជាមួយខ្លួនរហូតដល់បច្ចុប្បន្ន។ រីឯចុងចម្លើយក៏ឯកភាពចំពោះការប្តឹងសុំឈប់រស់នៅជាអនីតិសង្វាសរបស់ដើមចោទដែរ ប៉ុន្តែតាមច្បាប់បុគ្គលពីរនាក់ដែលបានរួមរស់ជាមួយគ្នាដូចជាប្តីប្រពន្ធ ដោយពុំបានចុះបញ្ជីអាពាហ៍ពិពាហ៍ ពុំមែនជាប្តីប្រពន្ធនឹងគ្នាតាមផ្លូវច្បាប់ទេ ។ ហេតុដូចនេះបណ្តឹងសុំឈប់រស់នៅជាអនីតិសង្វាសរបស់ដើមចោទ គឺជាបណ្តឹងមិនស្របច្បាប់ទេ ដែលតុលាការត្រូវលើកបណ្តឹងចោលតាមមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៣. ដើមចោទ និងចុងចម្លើយ មិនជាប់ចំណងអាពាហ៍ពិពាហ៍ជាមួយគ្នាទៀតទេ ហេតុដូច្នេះ គូភាគីមានសិទ្ធិពេញលេញក្នុងការរៀបអាពាហ៍ពិពាហ៍តាមឆន្ទៈរបស់ខ្លួន ហើយភាគីម្ខាងទៀតមិនមានសិទ្ធិជំទាស់ឡើយ។

៤. ក្នុងការរួមរស់ជាមួយគ្នាគូភាគីបានអះអាងថា មានកូនប្រុសម្នាក់ឈ្មោះ កើតថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤ ។ ចំពោះកូននេះ គូភាគីបានឯកភាពកំនត់យកម្តាយឈ្មោះ ជាអ្នកមានអំណាចមេបា ស្របតាមមាត្រា ១០៣៧ ចំណុចទី១ នៃក្រមរដ្ឋប្បវេណី ។

៤. ភាគីដើមចោទ មិនបានទាមទារប្រាក់អាហារកិច្ចនោះទេ ហេតុនេះតុលាការមិនពិចារណាចំពោះចំណុចនេះឡើយ ។

៥. ចំពោះទ្រព្យសម្បត្តិរួម និងបំណុលរួម គូភាគីអះអាងថា មិនមានទេ ។ ហេតុនេះតុលាការមិនលើកយកចំណុចនេះមកពិចារណាឡើយ។

-តាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់គូភាគីម្នាក់ពាក់កណ្តាល ។

## សេចក្តីសម្រេចបញ្ចប់

១. លើកចោលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨ ត្រង់ចំណុចប្តឹងសុំឈប់រស់នៅជាអនីតិសង្វាសពីចុងចម្លើយឈ្មោះ

២. កំណត់យកម្តាយឈ្មោះ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ កើតថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៤ ។

ភាគីដែលពុំមានអំណាចមេបា មានសិទ្ធចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីដែលមានអំណាចមេបា ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត ។

៣. ឲ្យភាគីចុងចម្លើយទទួលបន្ទុកអាហារកិច្ចតាមលទ្ធភាព ។

៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់គូភាគីម្នាក់ពាក់កណ្តាល ។

-សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនាថ្ងៃទី ខែ ឆ្នាំ២០១៩ នៅចំពោះមុខគូភាគី និងអ្នកតំណាងដោយអាណត្តិរបស់ភាគី ។

**ចៅក្រម**

ហត្ថលេខា និងត្រា:

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

**បានឃើញ**

**ចៅក្រម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
..........

សាលាដំបូងខេត្ត
ព្រៃវែង
សំណុំរឿងរដ្ឋប្បវេណីលេខ
ចុះថ្ងៃទី ខែ ឆ្នាំ២០១៩
សាលក្រមលេខ

## លិខិតសាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

ឆ្នាំ២០២០

## សាលាដំបូងខេត្តព្រៃវែង

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និង ប្រកាសសាលក្រមនៅថ្ងៃទី ឆ្នាំ២០២០ ដោយមានសមាសភាពចូលរួមដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក ជាប្រធានសាលាដំបូងខេត្តព្រៃវែង

**ក្រឡាបញ្ជីសវនាការ**

លោក ជាក្រឡាបញ្ជីសាលាដំបូងខេត្តព្រៃវែង

បានធ្វើទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ឆ្នាំ២០១៩ រវាង៖

**ភាគី:**

-ដើមចោទឈ្មោះ ភេទស្រី អាយុ២០ឆ្នាំ មុខរបរលក់ដូរ ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ន ជធានីភ្នំពេញ ឪពុកឈ្មោះ ម្តាយឈ្មោះ ប្តីឈ្មោះ មានកូនចំនួន ១នាក់ មេធាវីតំណាងដោយអាណត្តិ លោក

-ចុងចម្លើយឈ្មោះ ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងសំណង់ អាសយដ្ឋាន ខេត្តព្រៃវែង ឪពុកឈ្មោះ ម្តាយឈ្មោះ មានកូនចំនួន ១នាក់ មេធាវីតំណាង ដោយអាណត្តិ គ្មាន។

### ១.អង្គហេតុ និងចំណុចវិវាទ

១-១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

ដើមចោទបានប្តឹងទាមទារសុំឲ្យតុលាការសម្រេចតាមខ្លឹមសារដូចខាងក្រោម

១.សុំបញ្ជាក់នត្តិភាពនៃចំណងអាពាហ៍ពិពាហ៍រវាងដើមចោទនិងចុងចម្លើយ។

២.សុំផ្ដាច់អនីតិសង្វាសពីប្ដី ឈ្មោះ ។

៣.ប្រគល់សិទ្ធិគ្រប់គ្រងនិងកាន់កាប់ដីទំហំ ១ហិចតា ស្ថិតនៅភូ

ខេត្តព្រៃវែង ឲ្យទៅចុងចម្លើយឈ្មោះ

៤.សុំឲ្យភាគីចុងចម្លើយអ្នកទទួលបន្ទុកពន្ធប្រាក់ប្រដាប់ក្ដី។

១.២.អង្គហេតុចាំចាច់

ដើមចោទនិងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅភូមិ

ខេត្តព្រៃវែង តាមប្រពៃណី ប៉ុន្តែមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍នៅមន្ត្រីអាត្រានុកូលដ្ឋានឃុំកន្សោមអកនោះទេ។ រយៈពេលចុងក្រោយនៃការរួមរស់ក្នុងចំណងអាពាហ៍ពិពាហ៍គូភាគីមិនចុះសម្រុងនឹងគ្នា ប្រើប្រាស់អំពើហិង្សាមកលើខ្លួន និង រស់នៅបែកគ្នាអស់រយៈពេល៣ទៅ៤ឆ្នាំមកហើយ ដែលជាហេតុធ្វើឲ្យអស់មនោសញ្ចេតនាមិនអាចរួចរស់ជាមួយគ្នាតទៅទៀតបាន។

១.៣.ការពន្យល់ត្រួសៗអំពីរឿងក្ដី:

ដើមចោទនិងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅភូមិ

ខេត្តព្រៃវែង តាមប្រពៃណី ប៉ុន្តែមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍នៅមន្ត្រីអាត្រានុកូលដ្ឋានឃុំ នោះទេ។ការរួមរស់ជាមួយគ្នាកន្លងមករូបខ្លួនមានកូនចំនួន១នាក់ ឈ្មោះ ភេទស្រី កើត២៣ ខែមីនា ឆ្នាំ២០០០ និង មានទ្រព្យសម្បត្តិរួមមាន ដីទំហំ ១ហិចតា ស្ថិតនៅភូមិ ខេត្តព្រៃវែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ រយៈពេលចុងក្រោយនៃការ រួមរស់ក្នុងចំណងអាពាហ៍ពិពាហ៍គូភាគី មិនចុះសម្រុងនឹងគ្នា ប្រើប្រាស់អំពើហិង្សាមកលើខ្លួន និង រស់នៅបែកគ្នាអស់រយៈពេល៣ទៅ៤ឆ្នាំមកហើយ ដែលជាហេតុធ្វើឲ្យអស់មនោសញ្ចេតនាមិនអាច រួចរស់ជាមួយគ្នាតទៅទៀតបាន។

១.៤.សេចក្ដីថ្លែងការណ៍របស់គូភាគី:

ក.សេចក្ដីថ្លែងការណ៍របស់ដើមចោទ:

-ដើមចោទឈ្មោះ និង មានមេធាវីតំណាងដោយអាណត្តិ លោក បានធ្វើការអះអាងថា: កាលពីថ្ងៃខែមិនចាំ ឆ្នាំ១៩៩៧ រូបខ្លួនបានរៀបអាពាហ៍ពិពាហ៍ ជាមួយឈ្មោះ នៅភូមិ ខេត្តព្រៃវែង តាមប្រពៃណី ប៉ុន្តែមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍នៅមន្ត្រីអាត្រានុកូលដ្ឋានឃុំ នោះទេ។ ការរួមរស់ជាមួយគ្នាកន្លងមករូបខ្លួនមានកូនចំនួន១នាក់ ឈ្មោះ ភេទស្រី កើត២៣ ខែមីនា ឆ្នាំ២០០០ មានសំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៤ (ជានីតិជន) ។

ចំពោះទ្រព្យសម្បត្តិរួមមាន ដីទំហំ ១ហិចតា មានព្រំប្រទល់ ខាងកើតជាប់នឹងដីលេខ ខាងលិចជាប់នឹងដីលេខ ខាងជើងជាប់នឹងដីលេខ និង ខាងត្បូងជាប់នឹងដីលេខ ស្ថិតនៅភូមិ ខេត្តព្រៃវែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ ក្រៅពីនេះពុំមានអ្វីទៀតឡើយ។

ក្រោយពីរៀបអាពាហ៍ពិពាហ៍រួចការរួមរស់ជាមួយគ្នា មិនចុះសម្រុងនឹងគ្នា ប្រើប្រាស់អំពើហិង្សាមកលើខ្លួន និង រស់នៅបែកគ្នាអស់រយៈពេល៣ទៅ៤ឆ្នាំមកហើយ ដែលជាហេតុធ្វើឲ្យអស់មនោសញ្ចេតនាមិនអាចរួចរស់ជាមួយគ្នាតទៅទៀតបាន។

សំណូមពរ: ១.សុំបញ្ជាក់នត្ថិភាពនៃចំណងអាពាហ៍ពិពាហ៍រវាងដើមចោទនិងចុងចម្លើយ ។

២.សុំផ្តាច់អនីតិសង្វាសពីប្តី ឈ្មោះ

៣.ប្រគល់សិទ្ធិគ្រប់គ្រងនិងកាន់កាប់ដីទំហំ ១ហិចតា ស្ថិត ខេត្តព្រៃវែង ឲ្យទៅចុងចម្លើយឈ្មោះ

៤.សុំឲ្យភាគីចុងចម្លើយអ្នកទទួលបន្ទុកពន្ធប្រាក់ប្រដាប់ក្តី។

ខ.សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ:

ចុងចម្លើយឈ្មោះ បានធ្វើការអះអាងថា: រូបខ្លួនពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ នៅភូមិ ខេត្តព្រៃវែង តាមប្រពៃណី និងមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍នៅមន្ត្រីអាត្រានុកូលដ្ឋានឃុំកន្សោមអកប្រាកដមែន ការរួមរស់ជាមួយគ្នាកន្លងមក រូបខ្លួនពិតជាមាន កូនចំនួន ១នាក់ ឈ្មោះ ភេទស្រី កើតថ្ងៃទី២០ ខែមីនា ឆ្នាំ២០០០ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៤ (ជានីតិជន) និងមានទ្រព្យសម្បត្តិរួម មានដីទំហំ ១ហិចតា មានព្រំប្រទល់ ខាងកើតជាប់នឹងដីលេខ ខាងលិចជាប់នឹងដីលេខ ខាងជើងជាប់នឹងដីលេខ និង ខាងត្បូងជាប់នឹងដីលេខ ស្ថិតនៅ ខេត្តព្រៃវែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ ប្រាកដមែន ក្រៅពីនេះពុំមានអ្វីទៀតឡើយ ។

ក្រោយរៀបអាពាហ៍ពិពាហ៍រួចការរួមរស់ជាមួយគ្នា រូបខ្លួនមិនបានប្រើអំពើហិង្សាដូចដែលដើមចោទអះអាងនោះទេ ហើយការរស់នៅកន្លងមករវាងខ្លួននិងប្រពន្ធពិតជាបានបែកលំនៅដ្ឋានអស់រយៈពេល ៣ទៅ៤ឆ្នាំពិតប្រាកដមែន។

-ចំពោះការសុំលែងលះពីរូបខ្លួនពុំឯកភាពទេ។

-ចំពោះការប្រគល់សិទ្ធិគ្រប់គ្រងនិងកាន់កាប់ ដីទំហំ ១ហិចតា មានព្រំប្រទល់ ខាងកើតជាប់នឹងដីលេខ ខាងលិចជាប់នឹងដីលេខ ខាងជើងជាប់នឹងដីលេខ និង ខាងត្បូងជាប់នឹងដីលេខ ស្ថិតនៅ ខេត្តព្រៃវែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ រូបខ្លួនឯកភាព ។

១.៤. ចំណុចវិវាទ:

-តើការប្តឹងសុំផ្តាច់អនីតិសង្វាសរបស់ដើមចោទ ពិតជាមានមូលហេតុត្រឹមត្រូវដែរឬទេ?

## ២.ផ្នែកសំអាងហេតុ

ក.ចំណុចស្តីពីបណ្តឹងសុំផ្តាច់អនីតិសង្វាស

២.១. តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ ឃើញថា គូភាគីបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជាតិ ប៉ុន្តែមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍នៅមន្ត្រីអាត្រានុកូលដ្ឋានឃុំកន្សោមអកនោះទេ។ ដូចនេះ គូភាគីពិតជាមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ប្រាកដមែន។

២.២.តាមការអះអាងរបស់ភាគីដើមចោទថា មូលហេតុដែលខ្លួនប្តឹងសុំផ្តាច់អនីតិសង្វាសពីចុងចម្លើយ ដោយមូលហេតុថា រួមរស់ជាមួយគ្នា មិនចុះសម្រុងនឹងគ្នា ប្រើប្រាស់អំពើហិង្សាមកលើខ្លួន និងរស់នៅបែកគ្នាអស់រយៈពេល៣ទៅ៤ឆ្នាំមកហើយ ដែលជាហេតុធ្វើឲ្យអស់មនោសញ្ចេតនាមិនអាចរួចរស់ជាមួយគ្នាតទៅទៀតបាន។

២.៣. យោងតាមការអះអាងរបស់ដើមចោទខាងលើ ពិតជាស្តែងឲ្យឃើញថា ចំណងអាពាហ៍ពិពាហ៍របស់គូភាគីពិតជាឈានដល់ចំណុចត្រូវបែកបាក់ហើយគ្មានសង្ឃឹមថានឹងអាចបដិទានបានឡើយ ទោះបីជាតុលាការបានព្យាយាមធ្វើការផ្សះផ្សាយ៉ាងណាក៏ដោយក៏ភាគីដើមចោទមិនអាចសះជាបានឡើយ ដូច្នេះគប្បីតុលាការពិចារណាដោយផ្អែកតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី។

ខ.ចំណុចស្តីពីអំណាចមេបា:

២.៤.ដើមចោទនិងចុងចម្លើយបានរួមរស់ជាមួយគ្នាកន្លងមកមានកូនចំនួន១នាក់ ឈ្មោះ ភេទស្រី កើត២០ ខែមីនា ឆ្នាំ២០០០ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៤ ឃើញថាឈ្មោះ ភេទស្រី ជានីតិជន គប្បីតុលាការពុំលើកយកមកពិចារណា។

គ.ចំណុចស្តីអំពីការបែងចែកទ្រព្យសម្បត្តិ៖

២.៦. ដើមចោទបានសុំឱ្យតុលាការប្រគល់សិទ្ធិគ្រប់គ្រងនិងកាន់កាប់ដីទំហំ ១ហិចតា ស្ថិតនៅភូមិ ខេត្តព្រៃវែង ឲ្យទៅចុងចម្លើយឈ្មោះ គប្បីតុលាការយកមកពិចារណា ។

ឃ.សេចក្តីសន្និដ្ឋាន:

២.៧. រាល់ចំណុចដូចបានចង្អុលបង្ហាញខាងលើ បញ្ជាក់ឲ្យឃើញថា អង្គហេតុជាមូលដ្ឋាននៃការទាមទារ របស់ដើមចោទពិតជាមានអត្ថិភាពប្រាកដមែន ដូច្នេះគប្បីទទួលយកបណ្តឹងទាមទាររបស់ដើមចោទក្នុងចំណុចទី២ និងចំណុចទី៣ គប្បីលើកយកមកធ្វើការពិចារណា ។

ខ.អំពីប្រាក់ប្រដាក់ក្តី

២.៨. ចំពោះប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**៣.សេចក្តីសម្រេចបញ្ចប់**

៣.១.ទទួលស្គាល់ការទាមទាររបស់ដើមចោទឈ្មោះ តាមបណ្តឹងចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០១៩ ដោយបង្គាប់ថា ៖

ក.ចំណងអាពាហ៍ពិពាហ៍

បង្គាប់ឲ្យដាច់អនីតិសង្វាសពីគ្នាជាប្តីប្រពន្ធរវាងដើមចោទឈ្មោះ និងចុងចម្លើយ ឈ្មោះ

ខ.អំពីទ្រព្យសម្បត្តិរួម

ប្រគល់សិទ្ធិគ្រប់គ្រងនិងកាន់កាប់ដីទំហំ ១ហិចតា ដែលមានព្រំប្រទល់៖

-ខាងកើតជាប់នឹងដីលេខ -ខាងលិចជាប់នឹងដីលេខ

-ខាងជើងជាប់នឹងដីលេះ និង -ខាងត្បូងជាប់នឹងដីលេខ

ស្ថិតនៅភូ ខេត្តព្រៃវែង ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ ឲ្យទៅចុងចម្លើយឈ្មោះ តាមការព្រមព្រៀង និង តម្រូវឱ្យភាគីដើមចោទបំពេញកាតព្វកិច្ច កាត់ឈ្មោះចេញពីវិញ្ញាបនបត្រសម្គាល់អចលនវត្ថុដូចមានខាងលើវិញ។

៣.២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និង ថ្ងៃប្រកាសសាលក្រម នៅថ្ងៃ ថ្ងៃ ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី ខែ ឆ្នាំ២០២០ ចំពោះមុខគូភាគី បើកផ្លូវប្តឹងឧបាស្រ័យតាមកំណត់ច្បាប់។